Food and Agriculture Organization of the United Nations



គោលការណ៍ណែនាំ
សម្រាប់បង្ការ និងគ្រប់គ្រងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)
សម្រាប់ការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារនៅអាស៊ី

# ការអនុវត្តខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត សម្រាប់ជំងឺប៉េស្តជ្រូកអាហ្វ្រិកក្នុង ការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ

USAID
FROM THE AMERICAN PEOPLE

## គោលការណ៍ណែនាំ
## សម្រាប់ការបង្ការ និងគ្រប់គ្រងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)
## សម្រាប់ការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារនៅអាស៊ី

# ការអនុវត្តខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត សម្រាប់ជំងឺប៉េស្តជ្រូកអាហ្វ្រិកក្នុង ការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ


**Jeremy Ho**

នាយកដ្ឋានកសិកម្ម វារីវប្បកម្ម និងអភិរក្ស នៃប្រទេសចិនតំបន់រដ្ឋបាលពិសេសហុងកុង

**Andrew Bremang**

សាកលវិទ្យាល័យទីក្រុងហុងកុង នៃប្រទេសចិន តំបន់រដ្ឋបាលពិសេសហុងកុង

**Anne Conan**

សាកលវិទ្យាល័យទីក្រុងហុងកុង នៃប្រទេសចិន តំបន់រដ្ឋបាលពិសេសហុងកុង

**Hao Tang**

ការិយាល័យប្រចាំតំបន់របស់ FAO សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក

**Yooni Oh**

ការិយាល័យប្រចាំតំបន់របស់ FAO សម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក

**Dirk Pfeiffer**

សាកលវិទ្យាល័យទីក្រុងហុងកុង នៃប្រទេសចិន តំបន់រដ្ឋបាលពិសេសហុងកុង
សាកលវិទ្យាល័យវេជ្ជសាស្ត្រសត្វ
ចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង



**អង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ**
**ទីក្រុងភ្នំពេញ ឆ្នាំ ២០២៣**

Required citation:

**Ho, H.P.J., Bremang, A., Conan, A., Tang, H., Oh, Y. and Pfeiffer, D.U. 2023.** *គោលការណ៍ណែនាំសម្រាប់ការបង្ការ និងគ្រប់គ្រងជំងឺប៉េស្តជ្រូកអាហ្វ្រិក សម្រាប់ការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារនៅអាស៊ីៈ ការអនុវត្តខ្សែសង្វាក់ផ្គត់ផ្គង់ស្អាតសម្រាប់ជំងឺប៉េស្តជ្រូកអាហ្វ្រិកក្នុងការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ* ភ្នំពេញ ហ្វាវ។

The designations employed and the presentation of material in this information product do not imply the expression of any opinion whatsoever on the part of the Food and Agriculture Organization of the United Nations (FAO) concerning the legal or development status of any country, territory, city or area or of its authorities, or concerning the delimitation of its frontiers or boundaries. The mention of specific companies or products of manufacturers, whether or not these have been patented, does not imply that these have been endorsed or recommended by FAO in preference to others of a similar nature that are not mentioned.

The views expressed in this information product are those of the author(s) and do not necessarily reflect the views or policies of FAO.

**ISBN 978-92-5-137980-6**
**© FAO, 2023**

Some rights reserved. This work is made available under the Creative Commons Attribution-NonCommercial-ShareAlike 3.0 IGO licence (CC BY-NC-SA 3.0 IGO; https://creative commons.org/licenses/by-nc-sa/3.0/igo/legalcode).

Under the terms of this licence, this work may be copied, redistributed and adapted for non-commercial purposes, provided that the work is appropriately cited. In any use of this work, there should be no suggestion that FAO endorses any specific organization, products or services. The use of the FAO logo is not permitted. If the work is adapted, then it must be licensed under the same or equivalent Creative Commons licence. If a translation of this work is created, it must include the following disclaimer along with the required citation: "This translation was not created by the Food and Agriculture Organization of the United Nations (FAO). FAO is not responsible for the content or accuracy of this translation. The original [Language] edition shall be the authoritative edition."

Disputes arising under the licence that cannot be settled amicably will be resolved by mediation and arbitration as described in Article 8 of the licence except as otherwise provided herein. The applicable mediation rules will be the mediation rules of the World Intellectual Property Organization http://www.wipo.int/amc/en/mediation/rules and any arbitration will be conducted in accordance with the Arbitration Rules of the United Nations Commission on International Trade Law (UNCITRAL).

Third-party materials. Users wishing to reuse material from this work that is attributed to a third party, such as tables, figures or images, are responsible for determining whether permission is needed for that reuse and for obtaining permission from the copyright holder. The risk of claims resulting from infringement of any third-party-owned component in the work rests solely with the user.

Sales, rights and licensing. FAO information products are available on the FAO website (www.fao.org/publications) and can be purchased through publications-sales@fao.org. Requests for commercial use should be submitted via: www.fao.org/contact-us/licence-request. Queries regarding rights and licensing should be submitted to: copyright@fao.org.

This publication is made possible by the support of the American People through the United States Agency for International Development (USAID). The contents of this report are the sole responsibility of FAO and do not necessarily reflect the views of USAID or the United States of America Government.

Photo: ©ShutterStock/ccpixx photography

# មាតិកា


សេចក្ដីថ្លែងអំណរគុណ v
ពាក្យបំព្រួញ និងពាក្យកាត់ vi
សេចក្ដីសង្ខេបចំណុចសំខាន់ៗ viii
ផែនទីគំនិត xi

១. វិសាលភាព ១
២. សេចក្ដីផ្ដើម ៣
២.១. ASF នៅអាស៊ី និងប៉ាស៊ីហ្វិក ៣
២.២. ផលប៉ះពាល់នៃការផ្ទុះជំងឺ ASF មកលើការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ ៤
២.៣. ជម្រើសសម្រាប់ការបន្តពាណិជ្ជកម្ម និងប្រើប្រាស់ទីផ្សារសម្រាប់ម្ចាស់អាជីវកម្មលក្ខណៈគ្រួសារនៅក្នុងតំបន់ភូមិសាស្ត្រដែលមានការឆ្លង ឬការរាតត្បាត ឬ វត្តមានស្រាប់នៃ ASFV ៥
២.៤. ប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត នៅក្នុងប្រព័ន្ធផលិតកម្មជ្រូកលក្ខណៈគ្រួសារ ៥
៣. ការបង្កើតប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ៨
៣.១. យោបល់ទូទៅអំពីការអនុវត្តវិធីសាស្ត្រនេះ ៨
៣.២. ទំនាក់ទំនងជាមួយស្ថានភាពហានិភ័យទូទៅនៃ ASF ៩
៣.៣. ការបង្កើតភាពជាដៃគូសាធារណៈ-ឯកជន ៩
៣.៤. ការស្វែងយល់ពីបរិបទហានិភ័យ ASF ១២
៣.៥. ការគ្រប់គ្រងបរិបទហានិភ័យ ASF ១៥
៣.៦. ខ្លឹមសារនៃផែនការអាជីវកម្ម ២៤

៤. អនាគតនៃការអនុវត្តប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ២៨

ឧបសម្ព័ន្ធ ១៖

វិធីសាស្ត្រវាយតម្លៃហានិភ័យ និងកាត់បន្ថយហានិភ័យក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ២៩

១. ការពណ៌នាអំពីខ្សែសង្វាក់តម្លៃរបស់អ្នកចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ (ជ្រូក និងសាច់ជ្រូក) ២៩

២. ការវាយតម្លៃហានិភ័យ ASF ៣២

៣. ការគ្រប់គ្រងបរិបទហានិភ័យ ASF ៥០

ឯកសារយោង ៥៨




# សេចក្តីថ្លែងអំណរគុណ

ការបោះពុម្ពនេះ គឺជាលទ្ធផលនៃកិច្ចសហការរវាងការិយាល័យ ប្រចាំអាស៊ី ប៉ាស៊ីហ្វិក នៃអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO RAP)និងសាកលវិទ្យាល័យទីក្រុងហុងកុង។ ការបោះពុម្ពផ្សាយនេះអាចធ្វើទៅបានតាមរយៈការគាំទ្រដែលផ្តល់ដោយការិយាល័យជំនួយមនុស្សធម៌ (BHA) ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (USAID) ក្រោមលក្ខខណ្ឌនៃការផ្តល់ជូន No.720FDA19IO00092 "ការពង្រឹងសមត្ថភាពនៅមូលដ្ឋានសម្រាប់ការរកឃើញជំងឺប៉េស្តជ្រូកអាហ្វ្រិក និងការឆ្លើយតបបន្ទាន់"។ មតិក្នុងឯកសារណែនាំនេះ គឺជាគំនិតរបស់អ្នកនិពន្ធ និងពុំសុទ្ធតែឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID ឡើយ។

FAO RAP សូមថ្លែងអំណរគុណចំពោះអ្នកនិពន្ធ Younjung Kim, Anne Conan, Andrew Bremang, Hao Tang, Yooni Oh និង Dirk Pfeiffer សម្រាប់ការរៀបរៀងគោលការណ៍ណែនាំនេះ។ យើងសូមថ្លែងអំណរគុណចំពោះសហការីរបស់ FAO គឺ Damian Tago- Pacheco, Fusheng Guo, Tosapol Dejyong និង Renee Willis ដែលបានផ្តល់មតិយោបល់ដ៏មានតម្លៃលើកំណែសេចក្តីព្រាងនៃឯកសារនេះ។ កំណែដែលបានកែសម្រួលត្រូវបានពិនិត្យដោយអ្នកជំនាញ Chaojian Shen (មជ្ឈមណ្ឌលសុខភាពសត្វ និងអេពីដេមីសាស្ត្ររបស់ប្រទេសចិន) ក្រោមស្មារតីនៃក្រុមអ្នកជំនាញខាងជំងឺប៉េស្តជ្រូកអាហ្វ្រិក (SGE-ASF) សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក ក្របខ័ណ្ឌសកលសម្រាប់ការគ្រប់គ្រងវឌ្ឍនភាពជំងឺសត្វឆ្លងដែន (GF-TADs) ។ យើងសូមអរគុណចំពោះការចំណាយពេលវេលា និងការរួមចំណែកដ៏មានតម្លៃក្នុងការកែលម្អឯកសារណែនាំនេះឱ្យងាយស្រួលប្រើ។

មជ្ឈមណ្ឌលអាសន្នសម្រាប់ជម្ងឺសត្វឆ្លងដែន(ECTAD) នៃការិយាល័យ FAO RAP អ្នកគ្រប់គ្រងថ្នាក់តំបន់ Kachen Wongsathapornchai បានផ្តល់ការណែនាំបច្ចេកទេសក្នុងការរៀបចំឯកសារណែនាំនេះ រួមទាំង Daniela Scalise និង Domingo Caro III ក៏បានផ្តល់មតិយោបល់បន្ថែមទៀតផងដែរ។

គោលការណ៍ណែនាំជាភាសាខ្មែរនេះត្រូវបានបកប្រែ និងពិនិត្យដោយលោក ហាក់ មករា លោក ឱត ស៊ីដេត លោកស្រី ហេង យេន (អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិប្រចាំកម្ពុជា)និងលោក ភឹម ម៉េងហាក់ (បណ្តាញសាកលវិទ្យាល័យសុខភាពតែមួយអាស៊ីអាគ្នេយ៍)។

# ពាក្យបំព្រួញ និងពាក្យកាត់

| | | |
|---|---|---|
| **ACMSF** | Advisory Committee on the Microbiological Safety of Food | គណៈកម្មការផ្តល់យោបល់អំពីសុវត្ថិភាពមីក្រូជីវសាស្ត្រចំណីអាហារ |
| **ASF** | African swine fever | ជំងឺប៉េស្តជ្រូកអាហ្វ្រិក |
| **ASFV** | African swine fever virus | វីរុសជំងឺប៉េស្តជ្រូកអាហ្វ្រិក |
| **EFSA** | European Food Safety Authority | មន្ត្រីសុវត្ថិភាពចំណីអាហារអឺរ៉ុប |
| **FAO** | Food and Agriculture Organization of the United Nations | អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ |
| **ILO** | International Labour Organization | អង្គការពលកម្មអន្តរជាតិ |
| **NGO** | Non-governmental organization | អង្គការក្រៅរដ្ឋាភិបាល |
| **OIE** | World Organisation for Animal Health | អង្គការពិភពលោកដើម្បីសុខភាពសត្វ |
| **PPP** | Public-private partnership | ភាពជាដៃគូសាធារណៈ-ឯកជន |
| **TAD** | Transboundary animal disease | ជំងឺសត្វឆ្លងដែន |
| **USDA** | United States Department of Agriculture | ក្រសួងកសិកម្មសហរដ្ឋអាមេរិក |


© ShutterStock/only_kim

# សេចក្ដីសង្ខេបចំណុចសំខាន់ៗ

## ១. វិសាលភាព

ឯកសារណែនាំនេះបង្ហាញពីគោលការណ៍នៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាតជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) សម្រាប់អ្នកចិញ្ចឹមជ្រូកលក្ខណៈគ្រួសារនៅអាស៊ីអាគ្នេយ៍

## ២. សេចក្ដីផ្ដើម

ASF ជាជំងឺឆ្លងបង្កដោយវីរុសលើសត្វជ្រូក ដែលនាំឱ្យសត្វឈឺ និងស្លាប់ក្នុងអត្រាខ្ពស់។ ដោយសារតែមានធនធានក្នុងកម្រិតកំណត់សម្រាប់វិធានការបង្ការ និងត្រួតពិនិត្យ និងភាពស្មុគស្មាញនៃខ្សែសង្វាក់តម្លៃជ្រូក អ្នកចិញ្ចឹមជ្រូកលក្ខណៈគ្រួសារងាយរងគ្រោះ ជាពិសេសចំពោះការឆ្លង និងការរាតត្បាតនៃមេរោគ ASF (ASFV) ដែលនាំមកនូវផលវិបាកសេដ្ឋកិច្ចសង្គមធ្ងន់ធ្ងរបណ្ដាលពីការផ្ទុះជំងឺ ASF។ ដោយសារហេតុផលដូចគ្នានេះ ការអនុវត្តឧបករណ៍ផ្អែកលើហានិភ័យដែលមានប្រសិទ្ធភាពខាងអេពីដេមីសាស្ត្រនិងនិរន្តរភាពសេដ្ឋកិច្ចសង្គម (ឧទាហរណ៍ ការកំណត់តំបន់ការបែងចែកជាផ្នែក និងពាណិជ្ជកម្មតាមមុខទំនិញ) កំពុងប្រឈមបញ្ហាសម្រាប់ប្រព័ន្ធផលិតកម្មជ្រូកលក្ខណៈគ្រួសារ។

ដោយសារបញ្ហាប្រឈមទាំងនេះ ឯកសារនេះស្នើឡើងនូវគោលគំនិតថ្មីមួយ ដែលហៅថាប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ដែលសមស្របសម្រាប់កសិករខ្នាតតូច។ ប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF មានគោលដៅធានានូវការផលិត និងការផ្គត់ផ្គង់ជ្រូក និងផលិតផលសាច់ជ្រូកជាបន្តបន្ទាប់ ទោះស្ថិតក្នុងស្ថានភាពហានិភ័យនៃ ASF ក៏ដោយ។

ឯកសារនេះកំណត់ប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាតASF ជាប្រព័ន្ធមួយនៃខ្សែសង្វាក់តម្លៃជ្រូក ដែលអាចរក្សាស្ថានភាពគ្មាន ASFV តាមរយៈភាពជាដៃគូសាធារណៈ ឯកជន។ ប្រព័ន្ធនេះដំណើរការក្រោមឧបករណ៍ផ្អែកលើហានិភ័យ និងគោលគំនិតនៃស្តង់ដារគ្រប់គ្រង ASF ដែលបានកែសម្រួលឱ្យកាន់តែសមស្របសម្រាប់ប្រព័ន្ធផលិតកម្មជ្រូកលក្ខណៈគ្រួសារ។ វិធីសាស្ត្រផ្អែកលើហានិភ័យបែបនេះ ផ្អែកលើគោលបំណងដែលបានព្រមព្រៀងគ្នា

កម្រិតដែលអាចទទួលយកបាននៃហានិភ័យ ASF និងនីតិវិធីស្តង់ដារប្រតិបត្តិការប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ដែលចែងក្នុងផែនការអាជីវកម្មរបស់ខ្លួន។

ដូច្នេះ ជោគជ័យនៃវិធីសាស្ត្រនេះ ទាមទារនូវការយល់ដឹងអំពី (i) អេពីដេមីសាស្ត្រនៃ ASF (ii) ប្រព័ន្ធផលិតកម្មជ្រូក និងសាច់ជ្រូក (iii) ស្ថានភាពអេពីដេមីសាស្ត្រជំងឺ និង (iv) ការបង្កើតភាពជាដៃគូសាធារណៈឯកជន រវាងមន្ត្រីបសុពេទ្យ និងភាគីពាក់ព័ន្ធសំខាន់ៗក្នុងវិស័យឯកជន។

# ៣. ការបង្កើតប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF

ដៃគូទាំងអស់ដែលអាចមានឥទ្ធិពលទៅលើហានិភ័យASF អាចរួមគ្នាជាក្រុមស្នូល ដើម្បីផ្តួចផ្តើមដំណើរការនៃការបង្កើតប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។ ជាទូទៅ ដៃគូសាធារណៈ ដែលរួមមាន ស្ថាប័ន រដ្ឋាភិបាល ដូចជាមន្ត្រីបសុពេទ្យ ចំណែកដៃគូឯកជន រួមមាន អ្នកចិញ្ចឹមជ្រូក និងស្ថាប័នពាណិជ្ជកម្មផ្សេងទៀតនៅក្នុងខ្សែសង្វាក់តម្លៃ។ ដៃគូទាំងនេះ គួរតែបង្កើតផែនការអាជីវកម្មមួយ ដែលចែងពីខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF និងអធិប្បាយជំហាននៃការអនុវត្តខ្សែសង្វាក់នេះ។ ក្រុមនេះគួរតែព្រមព្រៀងគ្នាលើកម្រិតដែលអាចទទួលយកបាននៃហានិភ័យ ASF ដោយចងចាំថា ពួកគេមិនអាចកាត់បន្ថយហានិភ័យ ASF ឱ្យដល់សូន្យបានទេ។

ដៃគូទាំងអស់អាចទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។ ឧទាហរណ៍ ដៃគូឯកជននឹងទទួលបានអត្ថប្រយោជន៍ពីការកាត់បន្ថយហានិភ័យនៃការខាតបង់ដោយសារជំងឺ ASF និងការផ្ទុះជំងឺផ្សេងទៀតដែលកំហិតលើផលិតកម្ម ទន្ទឹមនឹងបានឃើញថា ជ្រូកនិងផលិតផលសាច់ជ្រូកដែលផលិតនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត មានសុវត្ថិភាព និរន្តរភាព និងគុណភាពខ្ពស់។ ដៃគូសាធារណៈនឹងទទួលប្រយោជន៍ពីការកាត់បន្ថយហានិភ័យ ASF នៅទូទាំងឧស្សាហកម្មជ្រូកទាំងមូល។

គេត្រូវមានការយល់ដឹងផងដែរអំពីបរិបទហានិភ័យ ASF ដោយពណ៌នាអំពីខ្សែសង្វាក់តម្លៃ សម្រាប់ជ្រូក និងផលិតផលពីសត្វជ្រូក នៃអ្នកចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ និងធ្វើការវាយតម្លៃហានិភ័យសម្រាប់ការឆ្លងនិងការរាតត្បាតនៃ ASFV។ ផ្អែកលើលទ្ធផលវាយតម្លៃហានិភ័យ គេអាចអនុវត្តវិធានការកាត់បន្ថយហានិភ័យ ដើម្បីកាត់បន្ថយហានិភ័យទាំងមូលមកត្រឹមកម្រិតដែលអាចទទួលយកបាន ឬទាបជាងកម្រិតហានិភ័យ ASF។ វិធានការបែបនេះស្ថិត

នៅក្រោមប្រធានបទនៃការគ្រប់គ្រងហានិភ័យនៃ (i) ជីវសុវត្ថិភាព (ii) ការតាមដានតាមដានឃ្លាំមើល និង (iii) ការកំណត់អត្តសញ្ញាណ/ការរក្សាកំណត់ត្រា/ការអង្កេតដាន។

ក្នុងករណីមានការផ្ទុះជំងឺ ASF សេចក្តីរាយការណ៍ ការបញ្ជាក់ពីមន្ទីរពិសោធន៍រោគវិនិច្ឆ័យ និងការស៊ើបអង្កេតអេពីដេមីសាស្រ្តគួរតែបានធ្វើឡើង នៅខាងក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។ វិធានការត្រួតពិនិត្យគួរតែត្រូវបានអនុវត្តដូចដែលបានព្រមព្រៀងគ្នាក្នុងចំណោមដៃគូ។ ក្នុងករណីនៃការផ្ទុះជំងឺ ASF នៅខាងក្រៅប្រព័ន្ធ វិធានការកាត់បន្ថយហានិភ័យដែលបានព្រមព្រៀងគ្នាក្នុងចំណោមដៃគូ គួរតែបានអនុវត្ត។

ដូច្នេះ ផែនការអាជីវកម្មនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ត្រូវពណ៌នាអំពី៖ (i) គោលបំណងនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF (ii) កម្រិតទទួលយកបាននៃហានិភ័យ ASF និង (iii) នីតិវិធីស្តង់ដារប្រតិបត្តិការ។ ផែនការអាជីវកម្មបែបនេះ គួរពិចារណាពី (i) ភាពស៊ីសង្វាក់គ្នាជាមួយបទប្បញ្ញត្តិនានា (ii) ការប្រាស្រ័យទាក់ទង និងកិច្ចសហការក្នុងចំណោមដៃគូពាក់ព័ន្ធ (iii) ចរាចរណ៍សត្វជ្រូក និងផលិតផលមានប្រភពពីសត្វជ្រូកនៅក្នុងប្រព័ន្ធ និងចេញពីប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF (iv) ការត្រួតពិនិត្យលើការអនុវត្តនីតិវិធីគ្រងប់គ្រងហានិភ័យ និង (v) រចនាសម្ព័ន្ធគ្រប់គ្រង។

# ៤. សេចក្តីផ្តើម

ការបង្កើតប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF គួរតែមានភាពជាក់ស្តែងសម្រាប់ការអនុវត្តនៅក្នុងបរិបទនៃផលិតកម្មជ្រូកលក្ខណៈគ្រួសារ ទន្ទឹមនឹងការកាត់បន្ថយហានិភ័យ ASF ឱ្យនៅត្រឹម ឬទាបជាងកម្រិតដែលអាចទទួលយកបាន។ ភាពជាដៃគូសាធារណៈ និងឯកជន រួមទាំង មន្ត្រីបសុពេទ្យ និងអ្នកពាក់ព័ន្ធសំខាន់ៗនៅក្នុងខ្សែសង្វាក់តម្លៃជ្រូក មានសារៈសំខាន់សម្រាប់ភាពជោគជ័យនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ។

# ផែនទីគំនិត



អ្នកពាក់ព័ន្ធនៅក្នុងខ្សែសង្វាក់តម្លៃសាច់ជ្រូក
អ្នកចិញ្ចឹមលក្ខណៈគ្រួសារ
ឈ្មួញ និងអន្តរការីដទៃទៀត
សត្តឃាតដ្ឋាន
អ្នកពាក់ព័ន្ធដទៃទៀត
មន្ត្រីបសុពេទ្យ
ប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត
បង្កើតភាពជាដៃគូសាធារណៈ-ឯកជន
រៀបចំឯកសារផែនការអាជីវកម្ម
ផែនការអាជីវកម្ម
ពិពណ៌នា៖
1. គោលបំណងនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF
2. ព្រមព្រៀងគ្នាលើកម្រិតដែលអាចទទួលយកបាននៃហានិភ័យ ASF
3. នីតិវិធីប្រតិបត្តិការ
ពិចារណា៖
1. បទប្បញ្ញត្តិ
2. ការប្រាស្រ័យទាក់ទង និងកិច្ចសហការ
3. ចរាចរណ៍ជ្រូកនិងផលិតផលពីជ្រូក
4. សវនកម្ម
5. រចនាសម្ព័ន្ធគ្រប់គ្រង
ពិពណ៌នាខ្សែសង្វាក់តម្លៃសាច់ជ្រូក
អនុវត្តការវាយតម្លៃហានិភ័យនៃការឆ្លង &ការរាតត្បាតនៃ ASF
អនុវត្តវិធានការកាត់បន្ថយហានិភ័យ៖
1. ជីវសុវត្ថិភាព
2. ការឃ្លាំមើល
3. ការកំណត់អត្តសញ្ញាណ/ការរក្សាកំណត់ត្រា/ការអង្កេតតាមដាន
ការប្រែប្រួលហានិភ័យនៃជំងឺ ASF នៅខាងក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF (ឧ. ការផ្ទុះជំងឺ)
ការផ្ទុះជំងឺ ASF នៅខាងក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF
វិធានការត្រួតពិនិត្យ
ស៊ើបអង្កេតការផ្ទុះជំងឺ
ការបញ្ជាក់ពីមន្ទីរពិសោធន៍រោគវិនិច្ឆ័យ
របាយការណ៍អំពីករណីសង្ស័យ ASF

# ១ ទិសាលភាព

ឯកសារណែនាំនេះ បង្ហាញពីគោលការណ៍នៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ជំងឺប៉េស្តជ្រូកអាហ្វ្រិក(ASF) សម្រាប់អ្នកចិញ្ចឹមជ្រូកលក្ខណៈគ្រួសារនៅអាស៊ីអាគ្នេយ៍។ ឯកសារនេះផ្តល់អនុសាសន៍សម្រាប់ប្រព័ន្ធផលិតកម្មជ្រូកលក្ខណៈគ្រួសារ អំពីការអនុវត្តជាក់ស្តែងនៃការគ្រប់គ្រងជីវសុវត្ថិភាពល្អ ដែលចាំបាច់សម្រាប់ការបន្តផលិតកម្ម និងការផ្គត់ផ្គង់ទំនិញតាមខ្សែសង្វាក់តម្លៃសាច់ជ្រូក ដោយមិនគិតពីស្ថានភាពហានិភ័យ ASF ដែលកំពុងមាននោះឡើយ។ គោលគំនិតនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ត្រូវបានបង្ហាញនៅទីនេះថា ជាវិធីសាស្ត្រថ្មីមួយ ក្នុងការគ្រប់គ្រង ASF ដោយផ្អែកលើភាពជាដៃគូសាធារណៈ និងឯកជនដែលបានរៀបចំ។ គោលការណ៍ណែនាំនេះ ត្រូវបានរៀបរៀងឡើងសម្រាប់តួអង្គទាំងអស់ដែលពាក់ព័ន្ធនឹងភាពជាដៃគូនេះ។ ដោយសារព័ត៌មានដែលបានបង្ហាញគឺជាទ្រឹស្តី បច្ចុប្បន្ននៅពុំទាន់មានឧទាហរណ៍ជាក់ស្តែងណាមួយនៅឡើយទេ។



© ShutterStock/Patnaree Asavacharanitich


© ShutterStock/Yuangeng Zhang

# ២ សេចក្តីផ្តើម

## ២.១ ASF នៅអាស៊ី និងប៉ាស៊ីហ្វិក

ជំងឺប៉េស្តជ្រូកអាហ្វ្រិក(ASF) គឺជាជំងឺឆ្លងដ៏ខ្លាំងដែលបង្កដោយវីរុសលើសត្វជ្រូក ដែលបណ្តាលឱ្យសត្វឈឺ និងស្លាប់ក្នុងអត្រាខ្ពស់ (Dixon et al., 2020)។ ជំងឺនេះមានលក្ខណៈរាតត្បាតស្មុគស្មាញ និងមានសក្តានុពលក្នុងការរីករាលដាលឆាប់រហ័សនៅក្នុងចំណោមជ្រូកក្នុងស្រុក និងនាំមកនូវផលវិបាកសេដ្ឋកិច្ចសង្គមធ្ងន់ធ្ងរ (Sánchez-Vizcaíno et al., 2019)។ ការឆ្លង ASFV អាចកើតឡើង តាមគន្លងហានិភ័យជាច្រើន ជាពិសេសនៅចំណុចនានានៃខ្សែសង្វាក់ផ្គត់ផ្គង់។ របៀបនៃការចម្លងរោគ រួមមាន (ប៉ុន្តែមិនមែនមានត្រឹម) ការប៉ះពាល់ជាមួយជ្រូករស់ដែលឆ្លងមេរោគ សំណល់សម្ភារៈពីកសិដ្ឋាន សាកសពជ្រូក និងផលិតផលមានប្រភពពីសត្វជ្រូកផ្សេងៗ។ លើសពីនេះ មេរោគ ASF អាចមានជីវិតយ៉ាងយូរនៅលើសម្ភារៈដែលឆ្លងរោគ។ ភាពងាយចម្លងតាមវិធីច្រើនបែបនេះ ធ្វើឱ្យ ASF ក្លាយជាជំងឺដែលប្រឈម ជាពិសេសក្នុងការគ្រប់គ្រង ដែលប្រើប្រាស់វិធានការជីវសុវត្ថិភាពជាលក្ខណៈបុគ្គល។ វិធីសាស្ត្រខ្សែសង្វាក់ផ្គត់ផ្គង់ស្អាតជាសមូហភាព ពាក់ព័ន្ធនឹងបណ្តាវិធានការដែលមានគោលដៅកាត់បន្ថយផលប៉ះពាល់នៃ ASF លើជីវភាពរស់នៅរបស់អ្នកពាក់ព័ន្ធ។ មេរោគ ASF (ASFV) បន្តរីករាលដាលនៅអាស៊ីនិងប៉ាស៊ីហ្វិក ដែលមានកសិដ្ឋានចិញ្ចឹមលក្ខណៈគ្រួសារមានប្រមាណ ៨០%នៃចំនួនជ្រូកចិញ្ចឹមសរុប (Smith et al., 2019; Dixon et al., 2020)។ ប្រការនេះ មិនត្រឹមតែគំរាមកំហែងដល់ប្រភពចំណូលចម្បងសម្រាប់គ្រួសារក្នុងមូលដ្ឋាន ដែលពាក់ព័ន្ធនឹងផ្នែកផ្សេងៗនៃខ្សែសង្វាក់តម្លៃជ្រូកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង ភាពសម្បូរបែបនៃប្រភេទជ្រូកព្រៃ និងជ្រូកចិញ្ចឹមផងដែរ។ លើសពីនេះ ASF ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការផលិត និងពាណិជ្ជកម្មជ្រូក និងផលិតផលសាច់ជ្រូក អាហារូបត្ថម្ភរបស់មនុស្ស និងសន្តិសុខស្បៀងនៅកម្រិតពិភពលោក។ ភាគីពាក់ព័ន្ធក្នុងឧស្សាហកម្មជ្រូកនៅអាស៊ី មានការព្រួយបារម្ភពិតប្រាកដជាពិសេស លើសមត្ថភាពក្នុងការគ្រប់គ្រង និងទប់ស្កាត់ការរីករាលដាលបន្ថែមទៀតនៃជំងឺនេះ។ ជារឿយៗ ការទប់ស្កាត់ការរីករាលដាល ASF ពឹងផ្អែកលើការពង្រឹងជីវសុវត្ថិភាពនៅតាមព្រំដែន។ ទោះបីជាយ៉ាងណាក៏ដោយ សូម្បីវិធានការនេះពិតជាចាំបាច់ក៏ដោយវាមិនសុទ្ធតែទទួលបានជោគជ័យទេ ជាពិសេសសម្រាប់ប្រទេសដែលមានប្រាក់ចំណូលទាបទៅមធ្យមដែលច្រើនតែមានធនធានក្នុងកម្រិតកំណត់ សម្រាប់ការអនុវត្តវិធានការកាន់តែច្រើនឡើង។ នៅទីបំផុត ប្រសិនបើមេរោគចូលដល់ក្នុងប្រទេសហើយនោះ វាអាចបង្កការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជ្រូកទាំងអស់។ ជាលទ្ធផល រដ្ឋាភិបាល អង្គការអន្តររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលជាច្រើន មានបំណងអនុម័តវិធីសាស្ត្រសហការ និងអភិក្រម កម្រិតតំបន់បន្ថែមទៀត ដើម្បីគ្រប់គ្រងការរីករាលដាលនៃជំងឺ ASF។ នៅថ្នាក់មូលដ្ឋាន ការទទួលយកវិធីសាស្ត្រសហការ

សម្រាប់ការអនុវត្តប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF នឹងជួយដល់កិច្ចការពារសុខភាពអ្នកចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ និងជីវភាពរបស់អ្នកពាក់ព័ន្ធទាំងអស់។

## ២.២ ផលប៉ះពាល់នៃការផ្ទុះជំងឺ ASF លើការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ

នៅក្នុងព្រឹត្តិការណ៍នៃការផ្ទុះជំងឺ ASF មន្ត្រីបសុពេទ្យ អនុវត្តវិធានការអនាម័យ ជាការឆ្លើយតបបន្ទាន់ដើម្បីទប់ស្កាត់ការផ្ទុះឡើង។ នៅពេលដែលសត្វមួយត្រូវបានធ្វើតេស្តវិជ្ជមាននៅក្នុងកសិដ្ឋាន តំបន់ត្រួតពិនិត្យត្រូវបានបង្កើតឡើងភ្លាមៗដើម្បីអនុញ្ញាតឱ្យមានការអនុវត្តវិធានការរឹតបន្តឹងលើចរាចរណ៍ បន្ថែមពីលើការពិឃាត និងការកំទេចចោល កំចាត់ជាតុកខ្វក់ ការរំងាប់មេរោគ និងសកម្មភាពតាមដានឃ្លាំមើល (OIE 2019a, 2019)។ ដូចគ្នានេះផងដែរ យោងតាមនីតិវិធីប្រតិបត្តិការនៃកម្មវិធីគ្រប់គ្រងរបស់ជាតិ ការហាមឃាត់ពាណិជ្ជកម្មទាំងស្រុង ការរឹតបន្តឹង ឬការហាមឃាត់ការដឹកជញ្ជូន និងជីវសុវត្ថិភាពតឹងរ៉ឹង ត្រូវបានដាក់ឱ្យអនុវត្ត។ វិធានការត្រួតពិនិត្យទាំងនេះអាចពង្រីកដល់ជ្រូកទាំងអស់ និងមិនត្រឹមតែតំបន់គ្រប់គ្រងឡើយ ហេតុនេះប៉ះពាល់ដល់ខ្សែសង្វាក់តម្លៃជ្រូក និងផលិតផលសាច់ជ្រូកទាំងអស់។ ដូច្នេះ ការគ្រប់គ្រងការផ្ទុះជំងឺ ASF មិនត្រឹមតែតម្រូវឱ្យរដ្ឋាភិបាលចំណាយច្រើនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដាក់បន្ទុកមកលើធនធានសេវាកម្មបសុពេទ្យរបស់ជាតិផងដែរ។ ឧទាហរណ៍ ការខាតបង់ខាងសេដ្ឋកិច្ចដោយផ្ទាល់របស់ប្រទេសចិនដោយសារ ASF ក្នុងមួយឆ្នាំៗ បន្ទាប់ពីជួបប្រទះការផ្ទុះជំងឺ ASF ដំបូង មានចំនួន ១៤១ពាន់លានដុល្លា (Berthe, 2020)។ នៅក្នុងសហគមន៍លក្ខណៈគ្រួសារ ខ្សែសង្វាក់តម្លៃសាច់ជ្រូក ពឹងផ្អែកជាខ្លាំងលើការដឹកជញ្ជូនជ្រូករស់ និងផលិតផលសាច់ជ្រូកជាញឹកញាប់។ ដូច្នេះ វិធានការឆ្លើយតបតឹងរ៉ឹងនៅក្នុងការគ្រប់គ្រងការផ្ទុះជំងឺ អាចបង្កការរំខានធ្ងន់ធ្ងរនៅក្នុងវិស័យនេះ ហើយផលប៉ះពាល់ទាំងនេះនឹងកាន់តែធ្ងន់ធ្ងរឡើង ប្រសិនបើពុំមានគម្រោងផ្តល់សំណង។ បន្ថែមពីលើការខូចខាតផ្ទាល់ដោយសារជ្រូកស្លាប់កាន់តែច្រើន ឬការបន្តផ្តល់ចំណីដល់ជ្រូកដែលមិនទាន់អាចដឹកជញ្ជូនទៅសត្តឃាតដ្ឋាន ក៏នៅមានការចំណាយដោយប្រយោលដែលទាក់ទងនឹងការហាមឃាត់ពាណិជ្ជកម្ម ការថយចុះផលិតភាពនៃជ្រូកដែលឆ្លងមេរោគរ៉ាំរ៉ៃ ឬការលំបាកក្នុងការរកប្រភពជ្រូកជំនួសផងដែរ។ ការចំណាយទាំងនេះ បណ្តាលពីការផ្ទុះជំងឺ ASF អាចប៉ះពាល់ជាខ្លាំងដល់សេដ្ឋកិច្ច។ អាស្រ័យហេតុនេះ គ្រួសារដែលពឹងផ្អែកលើការចិញ្ចឹមជ្រូកសម្រាប់ជារបរចិញ្ចឹមជីវិត ទំនងជានឹងជួបប្រទះការខាតបង់សេដ្ឋកិច្ចយ៉ាងខ្លាំង និងអាចត្រូវឈប់ចិញ្ចឹមជ្រូកថែមទៀតផង។

## ២.៣. ជម្រើសសម្រាប់ការបន្តពាណិជ្ជកម្ម និងប្រើប្រាស់ទីផ្សារសម្រាប់ម្ចាស់អាជីវកម្មលក្ខណៈគ្រួសារនៅក្នុងតំបន់ភូមិសាស្ត្រដែលមានការឆ្លង ឬវត្តមានស្រាប់នៃ ASFV

ការកំណត់តំបន់ ការបែងចែកជាផ្នែក និងពាណិជ្ជកម្មផ្អែកដែលលើមុខទំនិញ ត្រូវបានអនុវត្តជាច្រើនឆ្នាំមកហើយ ដើម្បីកាត់បន្ថយហានិភ័យជំងឺជាអន្តរជាតិ(Scott et al., 2006; Cowled et al., 2019)។ ឧបករណ៍ផ្អែកលើហានិភ័យទាំងនេះ ត្រូវបានអនុវត្តនៅទូទាំងពិភពលោក ដើម្បីគ្រប់គ្រងការផ្ទុះជំងឺ ASF ដោយផ្អែកលើគោលគំនិតនៃការអង្កេតតាមដានជីវសុវត្ថិភាព និងការបំបែកហ្វូងសត្វជ្រូក ពីប្រភព/តំបន់ដែលមានមេរោគ ASFV (Scott et al., 2006; Pfeiffer et al., 2021)។ ទោះជាយ៉ាងណាក៏ដោយ ឧបករណ៍ផ្អែកលើហានិភ័យទាំងនេះទាមទារធនធានមនុស្ស និងមូលធនយ៉ាងច្រើន ទើបមានប្រសិទ្ធភាពដោះស្រាយបញ្ហាអេពីដេមីសាស្ត្រ និងជានានិរន្តរភាពសេដ្ឋកិច្ចសង្គម ដូច្នេះវាជាការកំហិតលើលទ្ធភាពដែលអាចអនុវត្តបានសម្រាប់ប្រព័ន្ធផលិតកម្មជ្រូកលក្ខណៈគ្រួសារ (Cowled et al. , 2019) ឯកសារនេះស្នើឱ្យមានវិធីសាស្ត្រថ្មីមួយ ដែលហៅថាប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ដោយផ្អែកលើការកែសម្រួលឧបករណ៍ផ្អែកលើហានិភ័យទាំងនេះ និងគោលគំនិតនៃស្តង់ដារគ្រប់គ្រងហានិភ័យ ASF ឱ្យស្របតាមកាលៈទេសៈពិសេស របស់ម្ចាស់អាជីវកម្មលក្ខណៈគ្រួសារ។

## ២.៤ ប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត នៅក្នុងប្រព័ន្ធផលិតកម្មជ្រូកលក្ខណៈគ្រួសារ

ប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាតដែលគ្មានធាតុបង្កជំងឺ ត្រូវបានកំណត់ថាជា ប្រព័ន្ធរងមួយនៃខ្សែសង្វាក់តម្លៃដែលដៃគូសាធារណៈ និងឯកជនធ្វើការរួមគ្នា ដើម្បីរក្សាស្ថានភាពគ្មានជំងឺរបស់ខ្លួន ដូច្នេះជាការធានាឱ្យមានការផលិត និងការផ្គត់ផ្គង់ទំនិញជាបន្ត។ ប្រព័ន្ធរងនេះដំណើរការក្រោមឧបករណ៍ផ្អែកលើហានិភ័យ និងគោលគំនិតនៃស្តង់ដារគ្រប់គ្រងមេរោគដែលសម្របតាមប្រព័ន្ធផលិតកម្មលក្ខណៈគ្រួសារឱ្យកាន់តែប្រសើរ។ វិធីសាស្ត្រផ្អែកលើហានិភ័យបែបនេះ ចែងពីគោលបំណងដែលបានព្រមព្រៀងគ្នា កម្រិតដែលអាចទទួលយកបាននៃហានិភ័យ និងនីតិវិធីស្តង់ដារប្រតិបត្តិការនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ដែលបានកំណត់នៅក្នុងផែនការអាជីវកម្មរបស់ខ្លួន។

ជារឿយៗ វិធានការត្រួតពិនិត្យប្រឆាំងនឹងការរីករាលដាលនៃជំងឺសត្វឆ្លងដែន(TAD) ជួបផលវិបាកអវិជ្ជមានដោយ អចេតនានៅក្នុងឧស្សាហកម្មសត្វ។ ឧទាហរណ៍ វិធានការអនាម័យដូចជា ការធ្វើចត្តាឡីស័ក ការរឹតបន្តឹងចរាចរណ៍ ឬហាមឃាត់ការដឹកជញ្ជូន ត្រូវបានប្រើជាញឹកញាប់ដើម្បីបំបែកសត្វដែលឆ្លងមេរោគ ឬរងការប៉ះពាល់ ចេញពីក្រុមសត្វដែលមិនឆ្លង។ ទោះយ៉ាងណាក៏ដោយ ការអនុវត្តវិធានការទាំងនេះ នឹងរំខានដល់ខ្សែសង្វាក់តម្លៃ។ ប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ដែលបានអនុវត្តដោយជោគជ័យ ប្រើប្រាស់វិធីសាស្ត្រផ្អែកលើហានិភ័យដែលអាចកាត់បន្ថយការរំខានដល់ការជួញដូរសត្វ និងផលិតផលរបស់ខ្លួន នៅតាមខ្សែសង្វាក់

តម្លៃ នៅមុនក្នុងកំឡុងពេល និងក្រោយស្ថានភាពផ្ទុះឡើងនៃ TAD។

ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត សម្រាប់ការត្រៀមបង្ការ ការគ្រប់គ្រងជំងឺ និងទីបំផុត ការបន្តអាជីវកម្មនៅក្នុងប្រព័ន្ធបសុសត្វ ពឹងផ្អែកលើប្រតិបត្តិការស៊ីសង្វាក់គ្នានៃសមាសធាតុសំខាន់ៗមួយចំនួន។ សមាសធាតុទាំងនេះរួមមានការបំបែកមេរោគឆ្លង ជីវសុវត្ថិភាព ការអង្កេតដាន និងការតាមដានឃ្លាំមើលដែលជាគោលការណ៍ស្នូល និងជាបង្អែកសម្រាប់ដំណើរការនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ដើម្បីអាចចាត់ទុកថាពិតជាផ្អែកលើហានិភ័យ (Scott et al., 2006)។ ក្នុងការអនុវត្តប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត សម្រាប់ការគ្រប់គ្រងជំងឺ គេត្រូវគិតគូរអំពីការរាតត្បាតនៃភ្នាក់ងារបង្ករោគ ប្រព័ន្ធផលិតកម្ម និងប្រព័ន្ធពាណិជ្ជកម្ម និងមុខទំនិញដែលពាក់ព័ន្ធ។ វិធីសាស្រ្តខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ត្រូវតែបានរៀបចំឡើង ឱ្យស្របតាមជំងឺនីមួយៗ និងស្ថានភាពរាតត្បាតជាក់លាក់នីមួយៗ ទើបមានប្រសិទ្ធភាព។ នៅក្នុងបរិបទអាជីវកម្មលក្ខណៈគ្រួសារ គួរមានការពិចារណាបន្ថែមអំពី កត្តាសេដ្ឋកិច្ចសង្គមដែលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោល ដល់លទ្ធភាព និងការទទួលយកវិធីសាស្រ្តនេះ។

ការបង្កើតភាពជាដៃគូសាធារណៈ ឯកជន រវាងមន្រ្តីបសុពេទ្យ និងអ្នកពាក់ព័ន្ធសំខាន់ៗ គឺជាលក្ខខណ្ឌតម្រូវជាមុនដ៏សំខាន់ សម្រាប់ការអនុវត្តប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាតឱ្យជោគជ័យ។ នៅក្រោមប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ផលិតករដើរតួជាអ្នកអនុវត្តចម្បង ទន្ទឹមនឹងមន្រ្តីបសុពេទ្យ អ្នកប្រើប្រាស់ និងអ្នកពាក់ព័ន្ធផ្សេងទៀតទាំងអស់ នៅតាមខ្សែសង្វាក់តម្លៃ។ ភាគីពាក់ព័ន្ធទាំងអស់ គួរតែចូលរួម និងឈានដល់ការមូលមតិដែលអាចទទួលយកបាន អំពីការទទួលខុសត្រូវផ្ទាល់ខ្លួន និងរួមគ្នារបស់ពួកគេ។ ផ្នែកសំខាន់មួយនៃការចូលរួមរបស់អ្នកពាក់ព័ន្ធគឺ ការឯកភាពលើកម្រិតដែលអាចទទួលយកបាននៃហានិភ័យជំងឺ។ ហានិភ័យនេះគឺជាអត្រាធៀបនឹងហានិភ័យនៃជំងឺណាមួយ ដែលមាននៅខាងក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត និងមិនអាចកាត់បន្ថយឱ្យដល់សូន្យបានទេ។ គោលបំណងសម្រាប់ភាគីពាក់ព័ន្ធទាំងអស់គឺ កំហិតហានិភ័យនៃជំងឺណាមួយ មកត្រឹម ឬទាបជាងកម្រិតដែលអាចទទួលយកបានដែលឯកភាពគ្នា ដើម្បីធានាការបន្តផលិតកម្ម និងការផ្គត់ផ្គង់ទំនិញសម្រាប់អ្នកពាក់ព័ន្ធទាំងអស់។



© ShutterStock/Patnaree Asavacharanitich

# ៣ ការបង្កើតប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF

ជំហានដំបូង និងសំខាន់បំផុតក្នុងការបង្កើតប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF គឺការបង្កើតផែនការអាជីវកម្ម ដែលពណ៌នាពីការអនុវត្ត និងការថែរក្សាប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត (សូមមើលផ្នែកទី ៣.៦)។ ផែនការអាជីវកម្មនេះ ត្រូវផ្អែកលើកិច្ចព្រមព្រៀងមួយស្តីពីគោលបំណងនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF និងជាពិសេស អំពីកម្រិតដែលអាចទទួលយកបាននៃហានិភ័យ ASF នៅពេលប្រព័ន្ធនេះដំណើរការ។ ផ្នែកនេះពិពណ៌នាអំពីជំហាននានានៃការអនុវត្តប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ដែលគួរតែត្រូវបានបង្កើតឡើងនៅក្នុងផែនការអាជីវកម្ម។

## ៣.១ យោបល់ទូទៅអំពីការអនុវត្តវិធីសាស្ត្រនេះ

គោលការណ៍នៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF គឺការបង្កើតភាពជាដៃគូសាធារណៈឯកជន (PPP) រវាងកសិករចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ មន្ត្រីបសុពេទ្យ និងភាគីពាក់ព័ន្ធផ្សេងទៀតនៅក្នុងខ្សែសង្វាក់តម្លៃសាច់ជ្រូក។ ប្រការចាំបាច់គឺត្រូវរកឱ្យឃើញតុល្យភាពសមស្របមួយ រវាងភាពម៉ត់ចត់ខាងវិទ្យាសាស្ត្រ និងភាពជាក់ស្តែងនៃស្ថានភាពនៅក្នុងមូលដ្ឋាន។ ឧទាហរណ៍ កសិករលក្ខណៈគ្រួសារ និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងមូលដ្ឋាន ត្រូវតែមានលទ្ធភាព និងមានឆន្ទៈ ក្នុងការអនុវត្តប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាតASF។ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព រវាងសមាជិកទាំងអស់នៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត មានសារៈសំខាន់ខ្លាំងណាស់។ ចំពោះបញ្ហានេះ ជាការល្អ គួររៀបចំការប្រជុំក្រុមគោលដៅ ដើម្បីបង្កើតប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។ ទោះជាយ៉ាងណាក៏ដោយ ការគ្រប់គ្រងហានិភ័យ ASF ក៏ត្រូវតែផ្អែកលើគោលការណ៍ដ៏រឹងមាំនៃ អេពីដេមីសាស្ត្រផងដែរ។ ដើម្បីសម្រេចគោលការណ៍នេះ ការវាយតម្លៃហានិភ័យបែបវិទ្យាសាស្ត្រដែលមានរចនាសម្ព័ន្ធ ផ្តល់ជាបង្អែកសម្រាប់វិធីសាស្ត្រគ្រប់គ្រងហានិភ័យ ដែលជាមូលដ្ឋានសម្រាប់ប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ដំណើរការ។ ឯកសារនេះរៀបរាប់អំពីជំហានដែលគួរដាក់បញ្ចូលក្នុងដំណើរការនេះ ហើយចងក្រងជាឯកសារនៅក្នុងផែនការអាជីវកម្ម (ផ្នែកទី ៣.៦) និងលើកស្នើអំពីរបៀបអនុវត្តជំហាននីមួយៗ។ ទោះជាយ៉ាងណាក៏ដោយ នៅទីបំផុត វាអាស្រ័យលើដៃគូដែលពាក់ព័ន្ធនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ក្នុងការសម្រេចថា តើជំហាននីមួយៗត្រូវតែស៊ីជម្រៅកម្រិតណា ឬតើពួកគេត្រូវកែសម្រួលវិធីសាស្ត្រនេះបែបណា ឱ្យស្របនឹងកាលៈទេសៈជាក់លាក់ក្នុងមូលដ្ឋាន។ ភាពជាដៃគូដ៏មានប្រសិទ្ធភាពក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF គឺជាគន្លឹះនៃជោគជ័យសម្រាប់វិធីសាស្ត្រនេះ ហើយវានៅមិនទាន់អាចបញ្ជាក់ភាពគ្រប់គ្រាន់នៅឡើយទេ។

## ៣.២ ទំនាក់ទំនងជាមួយស្ថានភាពហានិភ័យទូទៅនៃ ASF

ប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត អាចបង្កើតឡើងបាននៅក្នុងតំបន់ភូមិសាស្ត្រដែលគ្មាន ASFV ឬ ដែលជាកម្មវត្ថុនៃការរាតត្បាតឬការឆ្លង ASFV។ ដៃគូនានាទំនងជាយល់អំពីការលើកទឹកចិត្តនានា ដើម្បីបង្កើនឆន្ទៈចំពោះប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ប្រសិនបើពួកគេបានជួបប្រទះ ឬបានឃើញផលប៉ះពាល់នៃ ASF មកលើកសិដ្ឋានលក្ខណៈគ្រួសារ។ អ្នកពាក់ព័ន្ធគួរតែដឹងថា វត្តមាននៃ ASFV នៅក្នុងប្រព័ន្ធអាហារសាច់ជ្រូកក្នុងស្រុក នឹងបង្កើនលទ្ធភាពនៃការឆ្លង ASFV ទៅក្នុងប្រព័ន្ធខ្សែ សង្វាក់ផ្គត់ផ្គង់ស្អាត ASF ដែលជាការសាកល្បងសមត្ថភាពនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ក្នុងការផ្តល់អត្ថប្រយោជន៍ដែលដៃគូរំពឹងចង់បាន។ គួរកត់សំគាល់ផងដែរថា សូម្បីគ្មាន ASF ក៏ដោយ ក៏ការលើកទឹកចិត្តខាងផ្នែកសេដ្ឋកិច្ច នឹងនៅតែកើតចេញពីការកែលំអជារួមនៃជីវសុវត្ថិភាព ការតាមដានតាមដានឃ្លាំមើលជំងឺ និងជំនឿទុកចិត្តរវាងដៃគូនានា (ក្នុងចំណោមអត្ថប្រយោជន៍ផ្សេងទៀត)។

## ៣.៣ ការបង្កើតភាពជាដៃគូសាធារណៈ-ឯកជន

គោលការណ៍នៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF គឺការបង្កើតភាពជាដៃគូសាធារណៈឯកជន (PPP) រវាងកសិករចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ មន្ត្រីបសុពេទ្យ និងអ្នកពាក់ព័ន្ធផ្សេងទៀតនៅក្នុងខ្សែសង្វាក់តម្លៃសាច់ជ្រូក។ *កូនសៀវភៅ OIE PPP៖ គោលការណ៍ណែនាំសម្រាប់ភាពជាដៃគូសាធារណៈ-ឯកជន ក្នុងកិច្ចការបសុពេទ្យ* អាចផ្តល់ការណែនាំដល់ដំណើរការបង្កើត PPP។ ប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF អាចជាដំណើរការជាលក្ខណៈសហករណ៍ ដោយមានការដាក់បញ្ចូលមន្ត្រីបសុពេទ្យ ជាដៃគូសាធារណៈលេចធ្លោមួយ។ អង្គការពលកម្មអន្តរជាតិ (ILO) ផ្តល់ឯកសារសិក្សាតាមអនឡាញដោយឥតគិតថ្លៃ និងវីដេអូអំពីវិធីសាស្ត្រចូលរួមសម្រាប់ការបង្កើតសហករណ៍ (ILO 2019)។

**កំណត់សំគាល់**

កញ្ចប់បណ្តុះបណ្តាល My.COOP អាចយកមកប្រើបាន នៅក្នុងអំឡុងពេលបង្កើត និងដំណើរការប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។ ឯកសារនេះក៏មានលើគេហទំព័រសម្រាប់ការសិក្សាដោយខ្លួនឯងផងដែរ ដែលមានឈ្មោះថា My.Coop Smart.

### ៣.៣.១ ការកំណត់អត្តសញ្ញាណដៃគូ

តួអង្គស្នូលមួយក្រុម ដូចជាអ្នកចិញ្ចឹមជ្រូកលក្ខណៈគ្រួសារមួយក្រុម ទំនងជាអាចផ្តួចផ្តើមដំណើរការបង្កើតប្រព័ន្ធខ្សែ សង្វាក់ស្អាតASFបាន។ ជាទូទៅ តួអង្គស្នូលទាំងនេះក៏មានទាំងអ្នកដែលយល់ពីអត្ថប្រយោជន៍ដែលអាចកើតចេញពីការបង្កើតប្រព័ន្ធខ្សែសង្វាក់ស្អាត ASFផងដែរ។ ពួកគេទំនងជាដើរតួជាគណៈកម្មការដឹកនាំដំបូង ហើយអាចផ្អែកលើសហករណ៍

ដែលមានស្រាប់ ឬបង្កើតឡើងថ្មីទាំងស្រុង ដើម្បីរៀបចំប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។ ក្រោយមកទៀត ក្រុមបឋមនេះអាចនឹងត្រូវពង្រីកបន្ថែម ដើម្បីចូលរួមជាមួយដៃគូឯកជន និងសាធារណៈទាំងអស់ ដែលអាចមានឥទ្ធិពលលើហានិភ័យនៃការឆ្លង ASFV ឬ រាតត្បាត នៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ។ ដូច្នេះ ប្រការចាំបាច់គឺត្រូវកំណត់ព្រំដែននៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាតនេះ ពោលគឺ តើផ្នែកណាមួយនៃខ្សែសង្វាក់តម្លៃនេះ ដែលត្រូវបញ្ចូល និងមួយណាមិនត្រូវបញ្ចូល។ គេក៏អាចបញ្ចូលដៃគូបន្ថែមទៀតផងដែរ ដោយសារស្ថានភាពអាចបង្ហាញច្បាស់ថា អ្នកណាត្រូវតែចូលរួម និងអ្នកដែលចាប់អារម្មណ៍ចូលរួម។

ក្នុងករណីភាគច្រើន ដៃគូវិស័យសាធារណៈ ត្រូវតំណាងដោយមន្ត្រីបសុពេទ្យ ដោយសារពួកគេកាន់តួនាទីនិយ័តកម្មក្នុងការគ្រប់គ្រងហានិភ័យ ASF។ ដៃគូដែលមានសក្ដានុពលផ្សេងទៀត បន្ថែមលើអ្នកចិញ្ចឹមជ្រូក និងមន្ត្រីបសុពេទ្យ រួមមានអ្នកដឹកជញ្ជូន អ្នកជួញដូរ អ្នកពិឃាតសត្វយកសាច់ អ្នកលក់រាយ ឬអ្នកពាក់ព័ន្ធផ្សេងទៀតនៅទូទាំងខ្សែសង្វាក់តម្លៃនេះ។

ដើម្បីរៀបចំប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ប្រការចាំបាច់គឺត្រូវមានមូលនិធិគាំទ្រពីរដ្ឋាភិបាល ឬអង្គការក្រៅរដ្ឋាភិបាល (NGO) ឬ ត្រូវទទួលឥណទានពីស្ថាប័នហិរញ្ញវត្ថុ។ តាមធម្មតា ស្ថាប័នទាំងនេះប្រហែលជាចង់ចូលរួមជាដៃគូផងដែរ។

**កំណត់សំគាល់**

ឯកសារ " Start-COOP. Module 1 – ការកំណត់អត្តសញ្ញាណសមាជិកស្នូល និងគំនិតអាជីវកម្ម" ចេញផ្សាយដោយអង្គការពលកម្មអន្តរជាតិ (ILO) ផ្ដល់ការណែនាំសម្រាប់ការកំណត់សមាជិកភាពនៃសហករណ៍ដោយប្រើវិធីសាស្ត្រចូលរួម (ILO 2020a)។ ឯកសារនេះអាចរកបានដោយមិនគិតថ្លៃនៅលើអ៊ីនធឺណិត។

### ៣.៣.២ ការឯកភាពគ្នាលើគោលបំណង និងកម្រិតទទួលយកបាននៃហានិភ័យ ASF

ប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF អាចជោគជ័យបានលុះត្រាតែដៃគូទាំងអស់ប្ដេជ្ញាចិត្ត និងមានគោលដៅរួមមួយ។ គោលដៅនេះទំនងជានឹងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងហានិភ័យ ASF ដោយរក្សាហានិភ័យនៃការឆ្លង ASF នៅត្រឹម ឬទាបជាងកម្រិតដែលអាចទទួលយកបាន ដែលបានព្រមព្រៀង ទន្ទឹមនឹងនៅតែអាចជួញដូរជ្រូករស់និងផលិតផលជ្រូករបស់ខ្លួន។ កម្រិតដែលអាចទទួលយកបាននៃហានិភ័យ ASF អាចទាក់ទងនឹង ១) ហានិភ័យបច្ចុប្បន្នសម្រាប់ជ្រូកក្នុងស្រុក នៅក្នុងស្ថានភាពដែល ASF ឆ្លងក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ឬ២) ហានិភ័យដែលអាចកើតមាននៅក្នុងករណីនៃការឆ្លង ASF ដល់ជ្រូកក្នុងមូលដ្ឋាននៅតំបន់ជុំវិញនោះ។ សំខាន់បំផុត ដៃគូត្រូវទទួលស្គាល់ថា ទោះបីផលិតកម្មជ្រូកនៅតែបន្ត ការកាត់បន្ថយហានិភ័យ ASF ឱ្យដល់សូន្យ មិនអាចទៅរួចទេ។ ដូច្នេះ ដៃគូត្រូវតែកំណត់ប្រេកង់

ដែលរំពឹងទុកនៃការឆ្លង/ការផ្ទុះជំងឺ ASF ក្នុងរយៈពេលណាមួយ នៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ពោលគឺ ការរំពឹងទុកអំពីការឆ្លង/ការផ្ទុះឡើង ក្នុងអំឡុងពេលកំណត់ណាមួយ (ប្រាំមួយខែ មួយឆ្នាំ ពីរឆ្នាំ ឬរយៈពេលណាមួយដែលចាត់ទុកថាមានភាពប្រាកដនិយម)។ ក្នុងន័យនេះ ត្រូវតែមានផែនការគ្រប់គ្រងការរាតត្បាត និងសេដ្ឋកិច្ច សម្រាប់ដោះស្រាយព្រឹត្តិការណ៍បែបនេះ។ ផែនការនេះអាចរួមបញ្ចូលការអនុវត្តវិធានការត្រួតពិនិត្យ និងមានគោលនយោបាយផ្តល់សំណងសម្រាប់ដៃគូដែលរងផលប៉ះពាល់។

ការប្រាស្រ័យទាក់ទងអំពីកម្រិតហានិភ័យដែលអាចទទួលយកបាន មិនមែនងាយស្រួលនោះទេ ព្រោះថា ជាទូទៅ ការរំពឹងទុកតែងចង់ឱ្យហានិភ័យធ្លាក់ដល់សូន្យ។ ការពិភាក្សាអំពីភាពខុសគ្នា រវាងលទ្ធភាពនៃការកើតព្រឹត្តិការណ៍ណាមួយ និងផលវិបាកដែលអាចកើតមានពីព្រឹត្តិការណ៍នោះ អាចជួយដៃគូឱ្យធ្វើការវិនិច្ឆ័យជាក់ស្តែង អំពីអ្វីដែលពួកគេចង់បាន និងអាចសម្រេចបាននៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF របស់ខ្លួន។ ឧទាហរណ៍ ប្រសិនបើប្រើមាត្រដ្ឋានហានិភ័យគុណភាព ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធទី ១ ដៃគូត្រូវដឹងថា ហានិភ័យនៃការឆ្លង ASFV នឹងមិនអាចធ្វេសប្រហែសបាន (= 'កម្រិតទាបបំផុត ដែលពុំចាំបាច់គិតគូរ') ប៉ុន្តែវានៅតែមានវត្តមានកម្រិតទាប(= 'កម្រិតទាប ប៉ុន្តែអាចកើតឡើង') និងអាចសូម្បីតែទាបបំផុត (='កម្រិតទាបបំផុត ប៉ុន្តែក៏មិនអាចមិនធ្វេសប្រហែសបានឡើយ')។ ដៃគូក៏ត្រូវទទួលស្គាល់ថា ការប៉ាន់ប្រមាណហានិភ័យនេះ មិនទាន់គិតបញ្ចូលផលវិបាកនៃការផ្ទុះជំងឺ ASF នៅឡើយទេ។ ដៃគូត្រូវសម្រេចចិត្តថា តើត្រូវប៉ាន់ប្រមាណថ្លៃខូចខាតដែលទាក់ទងនឹងការផ្ទុះជំងឺ ASF ដែរឬទេ។ ការយល់ដឹងអំពីថ្លៃខូចខាតដែលអាចកើតចេញពីការផ្ទុះជំងឺ ASF នឹងមានប្រយោជន៍ នៅពេលឆ្លុះបញ្ចាំងពីហេតុផលអាជីវកម្ម សម្រាប់ការបង្កើតប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ។

ការបង្កើតប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF នឹងនាំមកនូវការចំណាយថេរ និងអថេរបន្ថែមសម្រាប់ដៃគូ ឧទាហរណ៍ ដោយសារការពង្រឹងជីវសុវត្ថិភាព។ ការចំណាយនឹងអាចកាត់បន្ថយបាន តាមរយៈការប្រើប្រាស់មធ្យោបាយរួមគ្នា ដូច្នេះអាចកាត់បន្ថយការចំណាយក្នុងចំណោមកសិករ និងដៃគូផ្សេងទៀត ដែលជាផ្នែកមួយនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត (ឧ. ចំណីសត្វ ឱសថ សេវាបសុពេទ្យ) (Baltenweck et al., 2018; Cowled et al., ឆ្នាំ 2019)។ សម្រាប់ដៃគូសាធារណៈ អាចមានការចំណាយដែលទាក់ទងនឹងការធ្វើតេស្តរោគវិនិច្ឆ័យ និងការត្រួតពិនិត្យជាដើម។

អត្ថប្រយោជន៍ជាក់ស្តែង ត្រូវតែអាចទូទាត់ជាមួយការចំណាយបន្ថែម បើពុំដូច្នោះទេ ប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត នឹងពុំមាននិរន្តរភាពឡើយ។ ដៃគូឯកជនអាចទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចពីការចូលរួមនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ដោយសារពួកគេមិនសូវទទួលរងការខាតបង់ផ្នែកហិរញ្ញវត្ថុពីការផ្ទុះជំងឺ ASF ឡើយ។ អត្ថប្រយោជន៍ខាងសេដ្ឋកិច្ចក៏អាចរួម

បញ្ចូលផងដែរនូវ លទ្ធភាពប្រើប្រាស់ទីផ្សារកាន់តែប្រសើរឡើង ពីព្រោះទិន្នផលជ្រូករស់ ឬសាច់ជ្រូកដែលផលិតក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត អាចត្រូវបានចាត់ទុកថា មានគុណភាព និងសុវត្ថិភាពខ្ពស់ ដូច្នេះអាចលក់បានកាន់តែថ្លៃ។ លើសពីនេះ ការពង្រឹងជីវសុវត្ថិភាព ក៏អាចកាត់បន្ថយការខាតបង់ដែលពាក់ព័ន្ធ បណ្ដាលពីជំងឺឆ្លងនិងជំងឺរាតត្បាតផ្សេងទៀតដែលជាកត្តាកំណត់នៃផលិតកម្មផងដែរ។ សម្រាប់ដៃគូសាធារណៈ ប្រព័ន្ធខ្សែសង្វាក់ស្អាត ASF អាចបម្រើផលប្រយោជន៍សាធារណៈ ដោយសារហានិភ័យនៃ ASF នឹងត្រូវបានកាត់បន្ថយសម្រាប់ឧស្សាហកម្មជ្រូកទាំងមូល ដែលជួយឱ្យសេដ្ឋកិច្ចកាន់តែមានស្ថិរភាព និងសន្តិសុខស្បៀងកាន់តែប្រសើរឡើង។

លទ្ធភាពផ្សេងទៀតសម្រាប់ទូទាត់ការចំណាយ ឧទាហរណ៍ ភាគីទីបី ដូចជាសហគ្រាសផលិតជ្រូកធំៗ អាចទទួលបានអត្ថប្រយោជន៍ពីការកាត់បន្ថយហានិភ័យនៃ ASF នៅក្នុងតំបន់ជុំវិញកសិដ្ឋានរបស់ខ្លួន។ ជាលទ្ធផល ពួកគេអាចនឹងត្រៀមខ្លួនដើម្បីធ្វើការវិនិយោគលើការគ្រប់គ្រងជីវសុវត្ថិភាពឱ្យកាន់តែប្រសើរឡើងសម្រាប់កសិដ្ឋានជុំវិញ។ ឧទាហរណ៍មួយទៀតរួមមាន ការចាប់ដៃគូជាមួយក្រុមហ៊ុនធានារ៉ាប់រង ដែលផ្ដល់ការបញ្ចុះតម្លៃបុព្វលាភសម្រាប់សមាជិកនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។ ក្នុងករណីមានការផ្ទុះជំងឺ ASF មន្ត្រីបសុពេទ្យអាចពិចារណាបង្កើនប្រាក់សំណងដល់សមាជិក ដើម្បីទូទាត់សងសម្រាប់ការប្រឹងប្រែង និងការវិនិយោគរបស់អ្នកទាំងនោះ លើការអនុវត្តប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ។

**កំណត់សំគាល់**

"Start-COOP. Module 1 – *ការកំណត់អត្តសញ្ញាណសមាជិកស្នូល និងគំនិតអាជីវកម្ម*" និង "Start-COOP. Module 2 - *ការស្រាវជ្រាវលទ្ធភាពនៃគំនិតអាជីវកម្ម*" អ្នកអាចចូលអានឯកសារទាំងនេះ ដោយឥតគិតថ្លៃ តាមអ៊ីនធឺណិត និងដែលចេញផ្សាយដោយ ILO ។ ឯកសារទាំងនេះផ្ដល់ការណែនាំសម្រាប់កំណត់អត្តសញ្ញាណគំនិតអាជីវកម្ម និងលទ្ធភាពនៃគំនិតទាំងនោះ សម្រាប់សហករណ៍មួយ ដែលប្រើវិធីសាស្ត្រចូលរួម (ILO 2020a, b)

## ៣.៤ ការស្វែងយល់អំពីបរិបទហានិភ័យ ASF

ដើម្បីចាត់ជាអាទិភាពនូវអន្តរាគមន៍សម្រាប់ការគ្រប់គ្រងហានិភ័យ ចាំបាច់ត្រូវពិនិត្យមើលបរិបទអេកូឡូស៊ី-សង្គម ដែល មានការឆ្លង និងសាយភាយ ASFV។ បរិបទនេះមានលក្ខណៈប្រហែលគ្នាជាច្រើន រវាងប្រព័ន្ធផលិតកម្មជ្រូកនៅអាស៊ីអាគ្នេយ៍ និងអាស៊ីបូព៌ា។ ទោះជាយ៉ាងណាក៏ដោយ សារៈសំខាន់ធៀបនៃកត្តាខុសៗគ្នាក្នុងការចម្លង ASFV អាចនៅតែអាចខុសគ្នា រវាងប្រទេស ឬសូម្បីនៅក្នុងប្រទេសនានា។ ដំណើរការដើម្បីស្វែងយល់ពីបរិបទហានិភ័យ ASF គួរតែមានលក្ខណៈជាក់ស្ដែង ពាក់ព័ន្ធជាមួយអ្នកចូលរួមនានា និងមិនគួរជាលំហាត់សិក្សាសុទ្ធសាធនោះទេ។

ជំហានដំបូងក្នុងការស្វែងយល់ពីបរិបទហានិភ័យ ASF គឺត្រូវពិពណ៌នាពីខ្សែសង្វាក់តម្លៃផលិតកម្មជ្រូកលក្ខណៈគ្រួសារ។ ជំហានទីពីរគឺ ត្រូវធ្វើការវាយតម្លៃហានិភ័យ រួមទាំងការពិពណ៌នាអំពីគន្លងហានិភ័យនៃការឆ្លង និងការរីករាលដាលនៃASFV។ ការអនុវត្តជំហានទាំងនេះអាចធ្វើឡើងដោយប្រើដ្យាក្រាមសាមញ្ញ និងការវិភាគតិចតួច ដើម្បីបង្កើតការប៉ាន់ស្មានហានិភ័យប្រកបដោយគុណភាព។ ដំណើរការនេះចាំបាច់ណាស់ សម្រាប់ការធានាថា ផែនការអាជីវកម្មប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត (ផ្នែកទី ៣.៦) ផ្អែកលើការសម្រេចចិត្តសមហេតុផល។ លើសពីនេះ ដំណើការនេះអនុញ្ញាតឱ្យដៃគូទាំងអស់ដឹងពីសកម្មភាពចាំបាច់ និងហានិភ័យដែលទាក់ទងនឹងកង្វះការអនុលោមភាព។ នៅក្នុងដំណើរការនេះ គួរមានការកំណត់ព្រំដែននៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ។ នៅទីបំផុត គេអាចមើលឃើញច្បាស់ថាតួអង្គដទៃទៀតអាចមានឥទ្ធិពលលើហានិភ័យនៃការឆ្លង ឬរីករាលដាល ASFV នៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត និងគួរតែអញ្ជើញឱ្យចូលរួមនៅក្នុង PPP។ ដៃគូទាំងអស់គួរចងចាំថាបរិបទហានិភ័យអាចផ្លាស់ប្ដូរតាមពេលវេលា ដូច្នេះគួរតែមានការពិនិត្យឡើងវិញនូវការវាយតម្លៃហានិភ័យ ឬ ធ្វើការវាយតម្លៃឡើងវិញជាទៀងទាត់។ វិធីសាស្ត្រលម្អិតនៃការវាយតម្លៃហានិភ័យគុណភាពក្នុងបរិបទនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត មានពិពណ៌នានៅក្នុងឧបសម្ព័ន្ធ ១។

### ៣.៤.១ វិធីសាស្ត្រវាយតម្លៃហានិភ័យ

គោលបំណងនៃការវាយតម្លៃហានិភ័យ ពីដំណើរការលំអិតនៃអេពីដេមីសាស្ត្រ ដែលបណ្ដាលឱ្យមានព្រឹត្តិការណ៍មិនល្អ ដូចជាលំដាប់លំដោយនៃព្រឹត្តិការណ៍អាស្រ័យតាមលក្ខខណ្ឌណាមួយ ដែលបណ្ដាលឱ្យមានការឆ្លងមេរោគ ASFV ទៅក្នុងកសិដ្ឋាន (OIE 2010; FAO 2011)។ ចំណុចនេះអាចត្រូវបានបង្ហាញដោយប្រើដ្យាក្រាមគន្លងហានិភ័យមួយ ឬច្រើន។ ការញែកដាច់គ្នាបែបនេះអនុញ្ញាតឱ្យមានការប៉ាន់ស្មានហានិភ័យសំខាន់ៗ និងកំណត់កន្លែងដែលអាចអនុវត្តវិធានការកាត់បន្ថយហានិភ័យយ៉ាងមានប្រសិទ្ធភាព និងនិរន្តរភាពបំផុត។ ដំណើរការវាយតម្លៃហានិភ័យ ផ្សំដោយការកំណត់សំណួរហានិភ័យ ការបង្កើតដ្យាក្រាមគន្លងហានិភ័យ និងការប៉ាន់ប្រមាណហានិភ័យដែលទាក់ទងនឹងគន្លងនីមួយៗ។

ដើម្បីធ្វើការវាយតម្លៃហានិភ័យឱ្យមានប្រយោជន៍ ចាំបាច់ត្រូវមានការយល់ដឹងច្បាស់អំពីខ្សែសង្វាក់តម្លៃសាច់ជ្រូកក្នុងស្រុក និងគោលការណ៍ទូទៅនៃការគ្រប់គ្រងសុខភាពជ្រូក។ ប្រការសំខាន់ផងដែរគឺ ត្រូវយល់ពីលក្ខណៈរាតត្បាតនៃ ASFV។ លក្ខណៈរាតត្បាតនៃ ASFV ក្នុងផលិតកម្មជ្រូកលក្ខណៈគ្រួសារ ត្រូវបានសង្ខេបនៅក្នុងកាតជំងឺ ASF ដែលបោះពុម្ពដោយ OIE (2019b)។ ព័ត៌មានបន្ថែមអាចរកបាននៅក្នុង Sanchez-Vizcaino et al., (2019)។

ឯកសាររបស់អង្គការ FAO *គោលការណ៍ណែនាំសម្រាប់បង្ការ និងការត្រួតពិនិត្យជំងឺប៉េស្តជ្រូកអាហ្វ្រិក(ASF) ក្នុងការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារនៅអាស៊ី - ជីវសុវត្ថិភាពកសិដ្ឋាន ការពិឃាតចោល និងធ្វើការចិញ្ចឹមសត្វឡើងវិញ* ពណ៌នាអំពីវិធានការជីវសុវត្ថិភាពដែលពាក់ព័ន្ធនឹងការចិញ្ចឹមលក្ខណៈគ្រួសារ។ ព័ត៌មានបន្ថែមអំពីជីវសុវត្ថិភាពកសិដ្ឋាន អាចស្វែងរកបានផងដែរក្នុង Alarcon et al., (2021) និង Dewulf et al., (2019)។

ការវាយតម្លៃហានិភ័យ ASF ដោយមានគោលបំណងច្បាស់លាស់ វិទ្យាសាស្ត្រ និងតម្លាភាពនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត អាចជួបការលំបាក ដោយសារមានការផ្តល់ធនធាន និងជំនាញក្នុងកម្រិតកំណត់ ដល់សេវាបសុពេទ្យរបស់ជាតិ។ លើសពីនេះ ការវាយតម្លៃនេះត្រូវគិតគូរបញ្ហាជាក់ស្តែង និងកត្តាសេដ្ឋកិច្ចសង្គម ដែលពាក់ព័ន្ធនៅក្នុងប្រព័ន្ធផលិតកម្មជ្រូកលក្ខណៈគ្រួសារ។ បញ្ហាប្រឈម និងបរិបទបែបនេះបង្ហាញថា ការវាយតម្លៃហានិភ័យនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត អាចទទួលប្រយោជន៍ពីវិធីសាស្ត្រចូលរួម។ វិធីសាស្ត្រចូលរួមពាក់ព័ន្ធនឹងទិន្នន័យដែលប្រមូលបានតាមរយៈការពិភាក្សាក្នុងក្រុមគោលដៅ។ ជាការល្អ ការពិភាក្សាបែបនេះគួរដឹកនាំដោយសមាជិកដែលមានជំនឿទុកចិត្តលើប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាតដែលមានជំនាញបច្ចេកទេសសមស្រប។ តាមធម្មតា នេះមានន័យថា មន្ត្រីបសុពេទ្យគួរតែចូលរួមនៅក្នុងការដឹកនាំដំណើរការនេះ។ ការវាយតម្លៃហានិភ័យតាមបែបចូលរួម នឹងប្រមូលផ្តុំតួអង្គទាំងអស់ដែលពាក់ព័ន្ធក្នុងខ្សែសង្វាក់តម្លៃជ្រូកលក្ខណៈគ្រួសារ ជាក្រុមគោលដៅ។ ការពិភាក្សានឹងត្រូវធ្វើឡើង ទាក់ទងនឹងរចនាសម្ព័ន្ធខ្សែសង្វាក់តម្លៃ កត្តាហានិភ័យ ASF និងវិធានការជីវសុវត្ថិភាព ក្នុងចំណោមក្រុមគោលដៅនេះ។ ផ្អែកលើរបកគំឃើញពីការពិភាក្សាទាំងនេះ មន្ត្រីបសុពេទ្យគួរតែកំណត់មធ្យោបាយសមស្របសម្រាប់ការប្រមូលទិន្នន័យ និងការប៉ាន់ប្រមាណហានិភ័យដែលទាក់ទងនឹងគន្លងហានិភ័យផ្សេងៗគ្នា នៅក្នុងប្រព័ន្ធ សង្វាក់ស្អាត ASF ។

ការវាយតម្លៃហានិភ័យគួរតែបានធ្វើឡើងវិញ ក្នុងចន្លោះពេលទៀងទាត់ ដើម្បីរកមើលការប្រែប្រួលណាមួយនៃខ្សែសង្វាក់តម្លៃ និងអាកប្បកិរិយារបស់អ្នកពាក់ព័ន្ធ។ គួរមានការសម្រេចលើភាពញឹកញាប់នៃការវាយតម្លៃឡើងវិញ នៅក្នុងដំណាក់កាលនៃការបង្កើតប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF និងត្រូវបានចងក្រងជាឯកសារនៅក្នុងផែនការអាជីវកម្ម។ ដំណើរការនេះក៏នឹងជួយរក្សាការយល់ដឹងជាបន្តក្នុងចំណោមសមាជិកនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ផងដែរ អំពីហានិភ័យ ASF និងសារៈសំខាន់នៃការអនុលោមតាមវិធានការកាត់បន្ថយ។

## ៣.៥ ការគ្រប់គ្រងបរិបទហានិភ័យ ASF

ជោគជ័យនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF អាស្រ័យលើថា តើវិធានការកាត់បន្ថយហានិភ័យណាមួយ ត្រូវបានបង្កើតឡើងស្របតាមសំណុំលក្ខណៈជាក់លាក់នៃបរិបទហានិភ័យដែលបានបញ្ជាក់តាមរយៈការវាយតម្លៃហានិភ័យឬទេ។ ជារឿយៗ កសិករ និងអ្នកឯកទេសសុខភាពសត្វ ចង់ធ្វើការសម្រេចចិត្តភ្លាមៗលើវិធានការកាត់បន្ថយហានិភ័យ ដោយពុំចាំបាច់ធ្វើការវាយតម្លៃហានិភ័យជាមុនសិនឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើបែបនេះបង្កើនឱកាសនៃការបាត់គន្លងហានិភ័យសំខាន់ៗនៃការឆ្លង និងការរីករាលដាល ASFV ដូច្នេះពុំឆ្លុះបញ្ចាំងបានត្រឹមត្រូវនូវកត្តាហានិភ័យសំខាន់ៗឡើយ។ ជាលទ្ធផល ការសម្រេចចិត្តសមហេតុផលអំពីសារៈសំខាន់ដែលទាក់ទងនៃវិធានការកាត់បន្ថយហានិភ័យផ្សេងៗគ្នា នឹងជួបការលំបាក។ លើសពីនេះ ការសម្រេចចិត្តលើការកាត់បន្ថយហានិភ័យ ដោយគ្មានការវាយតម្លៃហានិភ័យមានន័យថា គ្មានការទទួលស្គាល់បានត្រឹមត្រូវ នូវភាពពាក់ព័ន្ធរវាងគ្នានៃជំហានបន្តបន្ទាប់គ្នានៅតាមគន្លងហានិភ័យ និងរបៀបផ្តោតវិធានការកាត់បន្ថយហានិភ័យឱ្យចំគោលដៅ នៅត្រង់ជំហានសំខាន់ៗ'ដើមខ្សែ' នៅតាមគន្លងហានិភ័យជាក់លាក់ដើម្បីមានឥទ្ធិពលខ្លាំងក្លាបំផុតឡើយ។

ជំហានដំបូងនៅក្នុងដំណើរការគ្រប់គ្រងបរិបទហានិភ័យASF គឺការប្រៀបធៀបការប៉ាន់ប្រមាណហានិភ័យរួម ជាមួយនឹងកម្រិតហានិភ័យដែលអាចទទួលយកបាននិងដែលព្រមព្រៀងគ្នា។ ប្រសិនបើមានការសន្និដ្ឋានថា ចាំបាច់ត្រូវធ្វើការកាត់បន្ថយហានិភ័យ មានន័យថា ត្រូវធ្វើការពិនិត្យឡើងវិញនូវសក្តានុពលសម្រាប់ការកាត់បន្ថយហានិភ័យប្រកបដោយប្រសិទ្ធភាពតាមគន្លងហានិភ័យនីមួយៗ និងផលប៉ះពាល់នៃគន្លងនោះមកលើការប៉ាន់ប្រមាណហានិភ័យទាំងមូល។ គោលបំណងគួរតែ ជាការកាត់បន្ថយការប៉ាន់ប្រមាណហានិភ័យទាំងមូលមកនៅត្រឹម ឬទាបជាងកម្រិតហានិភ័យដែលអាចទទួលយកបាន។

### ៣.៥.១ ប្រធានបទនានានៃការគ្រប់គ្រងហានិភ័យ

មានវិធានការកាត់បន្ថយ ហានិភ័យទូទៅមួយចំនួនដែលគួរពិចារណា នៅពេលរៀបចំប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាតASF។ គេអាចចាត់បញ្ចូលវិធានការទាំងនោះជាក្រុម ក្រោមប្រធានបទនៃការគ្រប់គ្រងហានិភ័យស្តីពី ជីវសុវត្ថិភាព ការតាមដានឃ្លាំមើល និងការកំណត់អត្តសញ្ញាណ/ការរក្សាកំណត់ត្រា/ការអង្កេតដាន។

ប្រការសំខាន់គឺត្រូវចាំថា ប្រសិទ្ធភាពនៃវិធានការកាត់បន្ថយហានិភ័យ អាស្រ័យលើអនុលោមភាពនៃដៃគូដែលទទួលខុសត្រូវក្នុងការអនុវត្តវិធានការនីមួយៗ (Collineau and Stärk, 2019)។ ភាពស្មុគស្មាញនៃខ្សែសង្វាក់តម្លៃ និងចំនួនមនុស្សដែលមានអាទិភាពសេដ្ឋកិច្ចសង្គមខុសៗគ្នាបង្ហាញថា ការបន្តរក្សាបាននូវកម្រិតអនុលោមភាព ត្រូវតែជាអាទិភាពយុទ្ធសាស្ត្រនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។ ដៃគូនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ស្អាតត្រូវ

បង្កើតប្រព័ន្ធលើកទឹកចិត្តសម្រាប់អនុលោមភាព ការអនុវត្តប្រព័ន្ធនេះគួរតែគាំទ្រដោយការធ្វើសវនកម្មជាទៀងទាត់។ ត្រូវចាត់ចែងផ្តល់វគ្គបណ្តុះបណ្តាលឡើងវិញជាទៀងទាត់អំពីជីវសុវត្ថិភាព ដែលជំរុញឥរិយាបថទៅរកជីវសុវត្ថិភាពដែលចង់បាន។

### ៣.៥.១.១ ជីវសុវត្ថិភាព

សមាសធាតុទាំងអស់នៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ត្រូវតែដំណើរការក្នុងកម្រិតនៃជីវសុវត្ថិភាព ដែលកាត់បន្ថយហានិភ័យនៃការឆ្លងចូល និងរីករាលដាលនៃ ASFV នៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF តាមរយៈសត្វមានជីវិត ក៏ដូចជា ទំនិញដែលមានមេរោគដូចជា ចំណីសត្វ សំណល់អាហារ សាច់ ឬសម្ភារៈប្រើប្រាស់។ ដើម្បីទទួលបានលទ្ធផលតាមការចង់បាន ប្រការសំខាន់គឺត្រូវផ្តោតលើវិធានការកាត់បន្ថយហានិភ័យដែលជាអាទិភាព។ មានកត្តាសំខាន់ៗបី ដែលសម្រួលដល់ការឆ្លងវីរុស ពោលគឺ កសិដ្ឋាន ការដឹកជញ្ជូន និងសត្តឃាតដ្ឋាន។

#### ៣.៥.១.១.១ ជីវសុវត្ថិភាពកសិដ្ឋាន

លក្ខខណ្ឌតម្រូវដ៏សំខាន់មួយសម្រាប់ប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF គឺថា កសិដ្ឋានទាំងអស់ត្រូវតែបន្តរក្សាបាននូវស្តង់ដារជីវសុវត្ថិភាពគ្រប់គ្រាន់ ដែលកាត់បន្ថយយ៉ាងមានប្រសិទ្ធភាពនូវហានិភ័យនៃការឆ្លងចូល និងរីករាលដាលនៃ ASFV មកក្នុងកសិដ្ឋានរបស់ខ្លួន ដោយផ្អែកលើការយល់ដឹងអំពីគន្លងហានិភ័យដែលពាក់ព័ន្ធ។ ប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF គួរតែបង្កើតផែនការជីវសុវត្ថិភាព ដែលនឹងក្លាយជាផ្នែកមួយនៃស្តង់ដារនីតិវិធីគ្រប់គ្រងកសិដ្ឋានរបស់ខ្លួន។ គួរមានការពិចារណាលើអនុសាសន៍ និងឧបករណ៍ជីវសុវត្ថិភាព ASF ដែលមានពណ៌នានៅក្នុងឯកសារ FAO គោលការណ៍ណែនាំសម្រាប់បង្ការនិងគ្រប់គ្រងជំងឺប៉េស្តជ្រូកអាហ្វ្រិក(ASF)ក្នុងការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារនៅអាស៊ី - ជីវសុវត្ថិភាពកសិដ្ឋាន ការពិឃាតចោល និងការធ្វើការចិញ្ចឹមសត្វឡើងវិញ ។ ជីវសុវត្ថិភាពកសិដ្ឋាន ផ្សំដោយសមាសធាតុខាងក្រៅនានា ដែលមានគោលដៅបង្ការការឆ្លងជំងឺ និងសមាសធាតុខាងក្នុងដែលមានគោលដៅទប់ស្កាត់ការរីករាលដាលនៅក្នុងកសិដ្ឋាន។តារាងទី១ផ្តល់ឧទាហរណ៍មួយអំពីផ្នែកសំខាន់ៗនៃវិធានការកាត់បន្ថយហានិភ័យដែលពាក់ព័ន្ធនឹងជីវសុវត្ថិភាពខាងក្រៅកសិដ្ឋាន។ ដៃគូដែលចូលរួមក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ត្រូវវាយតម្លៃថា តើវិធានការណាដែលពាក់ព័ន្ធ ជាក់ស្តែង និងទំនងជាមានប្រសិទ្ធភាព។ តារាងទី ២ ពណ៌នាអំពីវិធានការកាត់បន្ថយហានិភ័យដែលបានជ្រើសរើសសម្រាប់ពង្រឹងជីវសុវត្ថិភាពផ្ទៃក្នុងកសិដ្ឋាន។

ការធ្វើចត្តាឡីស័ក (ឬការបង្ខាំងដោយឡែក) គឺជាវិធានការកាត់បន្ថយហានិភ័យដ៏សំខាន់សម្រាប់កាត់បន្ថយលទ្ធភាពនៃការឆ្លង ASFV មកក្នុងកសិដ្ឋាន។ ជ្រូករស់ដែលមានប្រភពមកពីខាងក្នុង ឬខាងក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ត្រូវតែដាក់នៅដាច់ដោយឡែកពីគេ ទាំងនៅប្រភពដើម និង/ឬនៅកសិដ្ឋានគោលដៅ។ ដើម្បីឱ្យមណ្ឌលចត្តាឡីស័កមាន

ប្រសិទ្ធភាព វាត្រូវតែស្ថិតនៅដាច់ចេញពីកន្លែងសត្វផ្សេងទៀត ហើយត្រូវមានការកំហិតលើការចេញចូល ដោយគោរពយ៉ាងតឹងរ៉ឹងតាមពិធីសារនៃការសម្អាត និងរំងាប់មេរោគ។ ដើម្បីសម្រេចគោលបំណងនេះ ពោលគឺ ទប់ស្កាត់ការចម្លងជ្រូកឈឺចូលទៅក្នុងកសិដ្ឋាន វិធានការចត្តាឡីស័ក ត្រូវតែមានបញ្ចូលការតាមដានឃ្លាំមើលប្រកបដោយប្រសិទ្ធភាព សម្រាប់តាមរកការឆ្លងមេរោគ ឬជំងឺនៅដំណាក់កាល ដំបូង។ ជម្រើសវិធីសាស្ត្រតាមដានឃ្លាំមើល គឺជាកត្តាកំណត់រយៈពេលចត្តាឡីស័ក។ ចំពោះការតាមដានឃ្លាំមើលដែលផ្អែកលើការរកឃើញវីរុស ដោយប្រើការធ្វើតេស្តវិភាគម៉ូលេគុល ដូចជា PCR រយៈពេលចត្តាឡីស័ក អាចខ្លីជាងវិធីតាមដានឃ្លាំមើលនៅក្នុងកសិដ្ឋានដោយផ្អែកលើការតាមរកសញ្ញាគ្លីនិកតែឯង។ ដៃគូនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ត្រូវតែសម្រេចចិត្តថា តើរយៈពេលណាមួយដែលអាចធ្វើទៅបាន ដោយផ្អែកលើកត្តាសេដ្ឋកិច្ច និងប្រតិបត្តិការសម្រាប់ខ្លួន។ នៅក្នុងដំណើរការនោះ ត្រូវតែចងចាំផងដែរអំពីរយៈពេលលូតលាស់នៃ ASFV ( ឧ. ៤-១៩ ថ្ងៃ ) ( OIE 2019b )។


© ShutterStock/VipadaLoveYou

**តារាងទី ១.** ជីវសុវត្ថិភាពខាងក្រៅកសិដ្ឋាន៖ ឧទាហរណ៍នៃវិធានការកាត់បន្ថយហានិភ័យដែលអាចកើតមាន(ចំពោះព័ត៌មានបន្ថែម សូមអានឯកសារ FAO *គោលការណ៍ណែនាំសម្រាប់បង្ការ និងគ្រប់គ្រងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) ក្នុងការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារនៅអាស៊ី - ជីវសុវត្ថិភាពកសិដ្ឋាន ការពិឃាតចោល និងការធ្វើការចិញ្ចឹមសត្វឡើងវិញ)*

| គន្លងហានិភ័យ ASF | វិធានការកាត់បន្ថយហានិភ័យដែលអាចកើតមាន |
|---|---|
| កសិដ្ឋានចិញ្ចឹមជ្រូកជិតខាង | ▪ មានរបងការពារ (ធម្មជាតិ ឬសិប្បនិម្មិត) ដែលញែកហ្វូងដាច់ចេញពីសត្វអ្នកជិតខាង |
| ជ្រូកព្រៃ/ជ្រូកចិញ្ចឹមប្រលែង | ▪ វត្តមានរបងការពារដើម្បីរារាំងការប៉ះពាល់រវាងសត្វជ្រូកព្រៃ និងជ្រូកលែងសេរី |
| អ្នកចូលទស្សនា/ភ្ញៀវ | ▪ ហាមភ្ញៀវជម្មតាចូលទៅក្នុងកសិដ្ឋាន<br>▪ កាត់បន្ថយការចូលទៅក្នុងកសិដ្ឋាន សម្រាប់អ្នកដឹកជញ្ជូន អ្នកផ្គត់ផ្គង់ចំណី និងបសុពេទ្យ។ល។)<br>▪ បង្ហាញកន្លែងស្អាត និងកខ្វក់ សម្រាប់ការចេញចូលក្នុងកសិដ្ឋាន<br>▪ ការប្រកាន់ខ្ជាប់ចំពោះវិធានការសម្អាត និងរំងាប់មេរោគទៅកាន់ភ្ញៀវទាំងអស់។ |
| បុគ្គលិកកសិដ្ឋាន | ▪ បង្កើតវប្បធម៌នៃការគោរពតាមលក្ខខណ្ឌជីវសុវត្ថិភាពតាមរយៈការបណ្តុះបណ្តាលទៀងទាត់ ការត្រួតពិនិត្យគ្រប់គ្រាន់ និងការលើកទឹកចិត្តប្រកបដោយប្រសិទ្ធភាព<br>▪ បង្ហាញពីកន្លែងស្អាត និងកខ្វក់ សម្រាប់ការចូលក្នុងកសិដ្ឋាន<br>▪ ការប្រកាន់ខ្ជាប់ចំពោះវិធានការសម្អាត និងរំងាប់មេរោគដោយបុគ្គលិកកសិដ្ឋានទាំងអស់។ |
| យានយន្តនិងបរិក្ខារ | ▪ ការប្រកាន់ខ្ជាប់ចំពោះវិធានការសម្អាត និងរំងាប់មេរោគសម្រាប់អ្នកចូលទស្សនា<br>▪ ហាមប្រើមធ្យោបាយរួមគ្នារវាងកសិដ្ឋាន<br>▪ បង្ហាញកន្លែងស្អាត និងកន្លែងកខ្វក់សម្រាប់ការចេញចូលក្នុងកសិដ្ឋាន |
| ការនាំជ្រូកចូលមកពីក្រៅ | ▪ អនុវត្តចត្តាឡីស័កសម្រាប់គ្រប់ជ្រូកនាំចូលថ្មីៗ |
| ប៉ារ៉ាស៊ីត (ករណីពាក់ព័ន្ធ) | ▪ ទប់ស្កាត់ការប៉ះពាល់ជាមួយប្រភពបាក់តេរី/ចៃ |

**តារាងទី ២.** ជីវសុវត្ថិភាពផ្ទៃក្នុងកសិដ្ឋាន៖ ឧទាហរណ៍នៃវិធានការកាត់បន្ថយហានិភ័យដែលអាចកើតមាន(ចំពោះព័ត៌មានបន្ថែម សូមអានឯកសារ FAO *គោលការណ៍ណែនាំសម្រាប់បង្ការ និងគ្រប់គ្រងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) ក្នុងការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារនៅអាស៊ី - ជីវសុវត្ថិភាពកសិដ្ឋាន ការពិឃាតចោល និងការធ្វើការចិញ្ចឹមសត្វឡើងវិញ)*

| គន្លងហានិភ័យ ASF | វិធានការកាត់បន្ថយហានិភ័យដែលអាចកើតមាន |
|---|---|
| បុគ្គលិកកសិដ្ឋាន | ▪ បង្កើតវប្បធម៌នៃការគោរពតាមលក្ខខណ្ឌជីវសុវត្ថិភាពតាមរយៈការបណ្តុះបណ្តាលទៀងទាត់ ការត្រួតពិនិត្យគ្រប់គ្រាន់ និងប្រព័ន្ធលើកទឹកចិត្តប្រកបដោយប្រសិទ្ធភាព<br>▪ ការប្រកាន់ខ្ជាប់ចំពោះវិធានការសម្អាត និងរំងាប់មេរោគសម្រាប់បុគ្គលិកកសិដ្ឋាន។ |
| លំហូរជ្រូក | ▪ ត្រូវមានរបាំងញែកដាច់គ្នា រវាងដំណាក់កាលខុសគ្នានៃផលិតកម្មជ្រូក (ឧ. កូនជ្រូក មេពូជ ជ្រូកសាច់)<br>▪ ការប្រកាន់ខ្ជាប់ចំពោះវិធានការសម្អាត និងរំងាប់មេរោគ<br>▪ អនុវត្តប្រព័ន្ធបញ្ចូលជ្រូក និងបញ្ចេញជ្រូកទាំងអស់ពីទ្រុងណាមួយ ដើម្បីទុកពេលសំអាត។ |
| ជ្រូកឈឺ | ▪ ត្រូវមានកន្លែងដោយឡែកសម្រាប់ជ្រូកឈឺ<br>▪ រក្សាកន្លែងជ្រូកឈឺនៅដាច់ដោយឡែកពីផ្នែកផ្សេងទៀតនៃកសិដ្ឋាន |
| សំណល់ជ្រូកស្លាប់ | ▪ ការបោលសំណល់សាកសពជ្រូកឱ្យមានសុវត្ថិភាព |
| លាមកជ្រូក | ▪ ការគ្រប់គ្រងលាមកជ្រូកឱ្យមានសុវត្ថិភាព |

### ៣.៤.១.១.២ ជីវសុវត្ថិភាពក្នុងការដឹកជញ្ជូន និងនៅតាមសត្តឃាតដ្ឋាន

កត្តាសំខាន់បំផុតមួយក្នុងការកាត់បន្ថយការរីករាលដាល ASFV តាមខ្សែសង្វាក់តម្លៃគឺ ជីវសុវត្ថិភាពក្នុងការដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាព (Yoo et al., 2021)។ សារៈសំខាន់ ជាពិសេសគឺ ការចរាចរណ៍ផលិតផលជ្រូក និងសាច់ជ្រូកដែលទាក់ទងនឹងសត្តឃាតដ្ឋាន។ មន្ត្រីបសុពេទ្យ រួមជាមួយដៃគូផ្សេងទៀតនៅក្នុងប្រព័ន្ធសង្វាក់ស្អាត ASF អាចធ្វើការជាមួយ អ្នកគ្រប់គ្រងសត្តឃាតដ្ឋាន និងអ្នកដឹកជញ្ជូន ដើម្បីបង្កើតនីតិវិធីសមស្របដែលនឹងកាត់ បន្ថយហានិភ័យនៃការរីករាលដាល ASFV តាមរយៈការដឹកជញ្ជូន និងមនុស្ស។ គួរបង្កើត ប្រព័ន្ធនៃពិធីសារ និងសវនកម្ម ដើម្បីបង្ការហានិភ័យ ASF ដែលបង្កឡើងដោយការប៉ះពាល់ ទាំងនេះ នៅក្នុងកម្រិតដែលអាចទទួលយកបាន សម្រាប់ប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ។ ប្រព័ន្ធនេះអាចរាប់បញ្ចូល ការចេញលិខិតអនុញ្ញាតដឹកជញ្ជូនទៅកាន់សត្តឃាតដ្ឋាន បន្ទាប់ពីការធ្វើសវនកម្មតាមកាលកំណត់នៃជីវសុវត្ថិភាពដឹកជញ្ជូនរបស់ពួកគេ។

### ៣.៥.១.២ ការតាមដានតាមដានឃ្លាំមើល

ការតាមដានឃ្លាំមើលនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ត្រូវតែមានគោលដៅ រកឱ្យឃើញជាដំបូងនូវការឆ្លងមេរោគ ASFV បន្ទាប់ពីការបញ្ចូលទៅក្នុងសមាសធាតុណាមួយ របស់វា ដែលភាគច្រើនទំនងជាកសិដ្ឋានចិញ្ចឹមជ្រូក។ គោលបំណងមួយទៀតគឺ ការធានា ឡើងវិញដល់អ្នកពាក់ព័ន្ធខាងក្រៅថា នៅក្នុងប្រព័ន្ធ ឬទំនិញដែលផលិតដោយប្រព័ន្ធនេះគ្មាន ASFVឡើយ ឬយ៉ាងហោចណាស់ហានិភ័យនៃវត្តមានរបស់ ASFV មានត្រឹម ឬទាបជាង កម្រិតដែលអាចទទួលយកបាន ដែលបានព្រមព្រៀងគ្នា។ នេះមានន័យថា ការអនុវត្តប្រព័ន្ធ តាមដានឃ្លាំមើលត្រូវតែសម្រេចបាននូវកម្រិតជាក់លាក់នៃភាពរួស ភាពទាន់ពេលវេលា និង ភាពជាតំណាង ដែលត្រូវតែមានការព្រមព្រៀងគ្នាជាមុន ក្នុងចំណោមដៃគូនៅក្នុងប្រព័ន្ធខ្សែ សង្វាក់ផ្គត់ផ្គង់ស្អាត ASF។ ឧទាហរណ៍៖ ប៉ារ៉ាម៉ែត្រនៃការអនុវត្តជាគោលដៅ អាចជាភាព រួស ៩៥% នៃការរកឃើញ ASFV មិនលើសពីប្រាំពីរថ្ងៃ បន្ទាប់ពីការបញ្ចូលទៅក្នុងប្រព័ន្ធ ខ្សែសង្វាក់ស្អាត ASF។

ក្នុងអំឡុងពេលនៃការអនុវត្តប្រព័ន្ធតាមដានឃ្លាំមើល ដៃគូនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ ស្អាត ASF ត្រូវពិចារណាពីលទ្ធភាព និរន្តរភាព និងប្រសិទ្ធភាពចំណាយ នៃជាតុផ្សំផ្សេងៗ ដែលអាចមាន។ ដៃគូទាំងនោះអាចយោងទៅការណែនាំ និងឧបករណ៍តាមដានឃ្លាំមើល ASF ដែលបានពិពណ៌នានៅក្នុងឯកសាររបស់ FAO *គោលការណ៍ណែនាំសម្រាប់ការបង្ការ និងគ្រប់គ្រងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) ក្នុងការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារនៅអាស៊ី - ការ តាមដានឃ្លាំមើលសម្រាប់ការតាមដាន ASF ។*

បេកគំឃើញអំពីការវាយតម្លៃហានិភ័យ នឹងផ្តល់ជាមូលដ្ឋានសម្រាប់ជំហានសំខាន់ៗនៅតាមគន្លងហានិភ័យ ដែលអាចមានដាក់ឱ្យអនុវត្តជាតុផ្សំនានានៃការតាមដានឃ្លាំមើល។ ការធ្វើបែបនេះអាចអនុញ្ញាតឱ្យមានការអនុវត្តការតាមដានឃ្លាំមើល ដោយផ្អែកលើ ហានិភ័យ ដូច្នេះអាចបង្កើនប្រសិទ្ធភាពចំណាយ (OIE 2015; Backx et al., 2016)។

ការតាមដានឃ្លាំមើល ASFV ដែលធ្វើឡើងដោយមន្ត្រីបសុពេទ្យនៅក្នុងតំបន់ភូមិសាស្ត្រដែលមានខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF នឹងបង្កើតព័ត៌មានសំខាន់ៗសម្រាប់ការគ្រប់គ្រងហានិភ័យ ASF ប្រកបដោយប្រសិទ្ធភាព។ ប្រសិនបើមានការរកឃើញថា មានការឆ្លងមេរោគ ASFV នៅក្នុងតំបន់ជុំវិញប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF គេអាចត្រូវធ្វើការកាត់បន្ថយហានិភ័យបន្ថែម ដើម្បីបង្ការការឆ្លង ASFV ទៅក្នុងប្រព័ន្ធនេះ។

មន្ត្រីបសុពេទ្យមានភារៈទទួលខុសត្រូវ ក្នុងការត្រួតពិនិត្យសកម្មភាពតាមដានតាមដានឃ្លាំមើលទាំងអស់នៅក្នុង និងក្រៅប្រព័ន្ធខ្សែសង្វាក់ស្អាត ASF។ មន្ត្រីពេទ្យសត្វត្រូវធានាថាប្រព័ន្ធរាយការណ៍អនុញ្ញាតឱ្យមានការជូនដំណឹងភ្លាមៗ បន្ទាប់ពីមានការសង្ស័យអំពី ASF នៅក្នុងផ្នែកណាមួយនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។ នៅកម្រិតនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF គួរមានការកំណត់តួនាទីឱ្យបានច្បាស់ សម្រាប់រាយការណ៍នូវការសង្ស័យអំពី ASF។ បន្ទាប់ពីការបញ្ជាក់អំពី ASF មន្ត្រីបសុពេទ្យត្រូវតែជូនដំណឹងដល់អ្នកពាក់ព័ន្ធទាំងអស់។

> **កំណត់សំគាល់**
>
> ដើម្បីទទួលបានអនុសាសន៍លម្អិតស្តីពីការតាមដានឃ្លាំមើល ASFV នៅក្នុងកសិដ្ឋានចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ គួរពិគ្រោះជាមួយឯកសាររបស់ FAO គោលការណ៍ណែនាំសម្រាប់បង្ការ និងការគ្រប់គ្រងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) ក្នុងការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារនៅអាស៊ី - ការតាមដានឃ្លាំមើលជំងឺ ASF ។

### ៣.៥.១.៣ ការកំណត់អត្តសញ្ញាណ ការរក្សាកំណត់ត្រា និងការអង្កេតដាន

លក្ខខណ្ឌតម្រូវសំខាន់មួយទៀតសម្រាប់ការបង្កើតប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF គឺវត្តមានវិធីសាស្ត្រជាក់ស្តែងសម្រាប់កំណត់អត្តសញ្ញាណ និងអង្កេតដានជ្រូក និងផលិតផលជ្រូក។ នេះជាឧបករណ៍សុខភាពសត្វដ៏សំខាន់មួយ ដែលជាធម្មតាត្រូវបានប្រើប្រាស់ដើម្បីគ្រប់គ្រងជំងឺ ការតាមដានឃ្លាំមើល សកម្មភាពពាណិជ្ជកម្ម និងសុវត្ថិភាពចំណីអាហារ (OIE 2019a)។ នៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ការកំណត់អត្តសញ្ញាណ និងអង្កេតដាននៃផលិតផលជ្រូក និងសាច់ជ្រូក អាចធានាថា រាល់ការចរាចរណ៍ទំនិញតាមខ្សែសង្វាក់តម្លៃ ត្រូវបានអង្កេតដាន នៅចំណុចណាមួយ ក្នុងពេលវេលា ក្នុងទិសដៅណាមួយ។

ដៃគូ ត្រូវព្រមព្រៀងគ្នា លើប្រព័ន្ធដែលអាចទុកចិត្តបាន ដែលមានប្រយោជន៍ និងមានប្រសិទ្ធភាពចំណាយ។

ការរក្សាទុកកំណត់ត្រាដោយកសិករតូចតាច និងតួអង្គផ្សេងទៀតដែលពាក់ព័ន្ធនឹងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF គឺជាលក្ខខណ្ឌតម្រូវដ៏សំខាន់ សម្រាប់ការគ្រប់គ្រងហានិភ័យ ASF ប្រកបដោយប្រសិទ្ធភាព (USDA 2016)។ ក្នុងកម្រិតអប្ប- បរមា កំណត់ត្រានេះត្រូវចែងអំពីផលិតកម្មជ្រូក ប៉ុន្តែក៏មានការលើកទឹកចិត្តឱ្យរក្សាទុកផងដែរ នូវកំណត់ត្រាស្តីពីធាតុចូលនៅក្នុងផលិតកម្ម ការចរាចរណ៍បុគ្គលិក និងចរាចរណ៍ឧបករណ៍ ដោយហេតុថា នឹងមានតម្រូវការកំណត់ត្រាទាំងនេះសម្រាប់ការអង្កេតដានទៅមុខ និងថយក្រោយ ដែលជាផ្នែកមួយនៃការសើបអង្កេតការផ្ទុះឡើងនៃជំងឺរាតត្បាត។

## ៣.៥.២ ការឆ្លើយតបទៅនឹងការឆ្លង ASF

### ៣.៥.២.១ ការផ្ទុះ ASF នៅខាងក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF

មន្ត្រីបសុពេទ្យ និងសមាជិកនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ត្រូវព្រមព្រៀងគ្នាលើវិធីដោះស្រាយការឆ្លងមេរោគ ASFV នៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។ នេះគឺជាដំណើរការដ៏សំខាន់មួយក្នុងដំណាក់កាលបង្កើតប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។ គេត្រូវរកឱ្យឃើញតុល្យភាពសមស្រប រវាងកិច្ចការពាររបរចិញ្ចឹមជីវិតរបស់សមាជិក សន្តិសុខស្បៀង កម្រិតជីវសុវត្ថិភាពដែលបានអនុវត្ត និងតម្រូវការចាំបាច់របស់អ្នកចិញ្ចឹមជ្រូក នៅក្នុងនិងក្រៅប្រព័ន្ធសង្វាក់ផ្គត់ផ្គង់ស្អាត ASF នៅក្នុងពេលមានការឆ្លង ASFV។ លទ្ធផលនៃដំណើរការនោះនឹងក្លាយជាការពិចារណាដ៏សំខាន់បំផុតមួយសម្រាប់គាំទ្រ ឬជំទាស់នឹងការចូលរួមរបស់កសិករ និងតួអង្គផ្សេងទៀតនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។

**ជំហាន 1**

ដៃគូនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ត្រូវមានកិច្ចព្រមព្រៀងមួយទាក់ទងនឹងលក្ខខណ្ឌសម្រាប់រាយការណ៍អំពីការសង្ស័យថាកើតមានជំងឺ ASF ទៅមន្ត្រីបសុពេទ្យ។ លក្ខខណ្ឌបែបនេះអាចរាប់បញ្ចូល សត្វមួយ ឬច្រើនដែលបង្ហាញសញ្ញាគ្លីនិកគួរឱ្យសង្ស័យ ឬប៉ារ៉ាម៉ែត្រសរុប ដូចជា ការកើនឡើងនៃជំងឺ/ការស្លាប់ជាក្រុម ឬជាហ្វូង។ ដូច្នេះ ជំហានដំបូងក្នុងការឆ្លើយតបទៅនឹងករណីសង្ស័យ ASF គឺការរកឃើញ និងរាយការណ៍ពីលក្ខខណ្ឌនេះ។

**ជំហាន 2**

ជាការឆ្លើយតបទៅនឹងរបាយការណ៍ មន្ត្រីបសុពេទ្យ ត្រូវស៊ើបអង្កេតវត្តមាននៃការឆ្លងមេរោគ ASFV ដោយផ្អែកលើការបញ្ជាក់ពីមន្ទីរពិសោធន៍រោគវិនិច្ឆ័យ។ ក្នុងពេលអនុវត្តកិច្ចការនេះ មន្ត្រីបសុពេទ្យអាចសម្រេចចិត្តថា តើត្រូវបញ្ឈប់រាល់ការចរាចរណ៍ជ្រូកពីកសិដ្ឋាន និងបង្កើនវិធានការជីវសុវត្ថិភាពឬទេ។ ការអនុវត្តវិធានការទាំងនេះចំពោះកសិដ្ឋានទាំងអស់ និងសមាសធាតុផ្សេងទៀតនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ដូចជា អ្នកដឹកជញ្ជូន និងសត្តឃាតដ្ឋានក៏ប្រហែលជាចាំបាច់ផងដែរ។

**ជំហាន 3**

បន្ទាប់ពីមានការបញ្ជាក់លើរោគវិនិច្ឆ័យ មន្ត្រីបសុពេទ្យត្រូវធ្វើការស៊ើបអង្កេតអេពីដេមីសាស្ត្រដើម្បីកំណត់ វិសាលភាពនៃការផ្ទុះឡើង កន្លែងដែលអាចជាប្រភពនៃការផ្ទុះនេះ (អង្កេតជានមកក្រោយវិញ) និងតើការឆ្លងអាចរីករាលដាលពីកសិដ្ឋាននេះទៅកន្លែងណាខ្លះ (អង្កេតជានទៅមុខ)។

**ជំហាន 4**

របកគំហើញពីការស៊ើបអង្កេតលើការផ្ទុះជំងឺរាតត្បាត នឹងប្រាប់អំពីជំហានបន្ទាប់ក្នុងការឆ្លើយតបនឹងការផ្ទុះឡើងនេះ ដែលរួមទាំង តើត្រូវវិធានការអ្វីខ្លះចំពោះកសិដ្ឋានដែលមានមេរោគ និងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASFទាំងមូល។ នេះជាចំណុចសំខាន់ក្នុងការសម្រេចចិត្ត ដែលមន្ត្រីបសុពេទ្យត្រូវតែធ្វើការជាមួយដៃគូផ្សេងទៀត ដើម្បីផ្តល់តុល្យភាពសមស្រប រវាងផលប្រយោជន៍របស់សហគមន៍ដែលពាក់ព័ន្ធ និងអ្នកនៅក្នុង និងក្រៅប្រព័ន្ធសង្វាក់ផ្គត់ផ្គង់ស្អាត ASF។ ប្រការសំខាន់គឺត្រូវមានការព្រមព្រៀងគ្នាលើយុទ្ធសាស្ត្រគ្រប់គ្រងសម្រាប់សេណារីយ៉ូនៃការផ្ទុះឡើង មុនពេលមានផ្ទុះឡើងជាក់ស្តែង។ ការសម្រេចចិត្តសំខាន់ៗរួមមាន វិសាលភាពនៃការពិឃាតសត្វជ្រូកដែលមានជំងឺ ឬជ្រូកដែលមានការប៉ះពាល់ និងរយៈពេលនៃការរឹតបន្តឹងការចរាចរណ៍ និងវិធាននៃការធ្វើការចិញ្ចឹមសត្វឡើងវិញ។

**កំណត់សំគាល់**

*ឯកសាររបស់អង្គការ FAO គោលការណ៍ណែនាំសម្រាប់បង្ការ និងការគ្រប់គ្រងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) ក្នុងការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារនៅអាស៊ី - ការសម្លាប់ចោល និងការកំទេចចោលជ្រូកនៅក្នុងការផ្ទុះជំងឺ ASF អាចផ្តល់នូវព័ត៌មានលម្អិតបច្ចេកទេសបន្ថែមសម្រាប់ការពិគ្រោះយោបល់។*

### ៣.៥.២.២ ការផ្ទុះជំងឺ ASF នៅក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF

ត្រូវមានការព្រមព្រៀងគ្នា អំពីយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យដែលត្រូវអនុវត្តនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាតASFក្នុងអំឡុងពេលមានស្ថានភាពផ្ទុះឡើងនៅខាងក្រៅប្រព័ន្ធនេះ នៅមុនពេលមានព្រឹត្តិការណ៍បែបនេះកើតឡើង។ មន្ត្រីបសុពេទ្យ និងដៃគូផ្សេងទៀត គួរមានការព្រមព្រៀងគ្នាលើយុទ្ធសាស្ត្រទាំងនេះ។ ហេតុផលសំខាន់មួយសម្រាប់ការចូលរួមនៅក្នុងប្រព័ន្ធនេះគឺ សមត្ថភាពក្នុងការបន្តធ្វើពាណិជ្ជកម្ម នៅក្នុងអំឡុងពេលមានការផ្ទុះឡើងនៃ ASF នៅខាងក្រៅខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។

ការពង្រឹងវិធានការជីវសុវត្ថិភាព អាចជាលក្ខខណ្ឌតម្រូវ ដើម្បីសម្រួលដល់ការបន្តធ្វើពាណិជ្ជកម្ម និងការពារប្រព័ន្ធខ្សែ សង្វាក់ស្អាត ASF ពីការឆ្លង ASFV។ វិធានការនេះអាចរួមបញ្ចូល ការដាក់កំហិត ឬ អាចបញ្ឈប់ការចរាចរណ៍ជ្រូករស់ ចំណីជ្រូក យានជំនិះ និងបុគ្គលិករវាងកសិដ្ឋាន និងគ្រឿងបរិក្ខារផ្សេងទៀតដែលពាក់ព័ន្ធនឹងប្រព័ន្ធនេះ។ ក្នុងអំឡុងពេលនៃកំណើនហានិភ័យ មន្ត្រីបសុពេទ្យ និងដៃគូផ្សេងទៀត អាចត្រូវធ្វើសវនកម្មលើវិធានការជីវសុវត្ថិភាព ដែលបានអនុវត្តនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។

## ៣.៦ ខ្លឹមសារនៃផែនការអាជីវកម្ម

ប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF គួរមានផែនការអាជីវកម្មរបស់ខ្លួន។ ផែនការនេះគួរកំណត់ឱ្យបានច្បាស់អំពីគោលបំណងនៃប្រព័ន្ធនេះ កម្រិតហានិភ័យដែលអាចទទួលយកបាន និងដែលព្រមព្រៀងគ្នា និងនីតិវិធីប្រតិបត្តិការ ដែលរួមទាំង វិធានការដែលត្រូវអនុវត្ត ក្នុងការឆ្លើយតបទៅនឹងការផ្ទុះឡើងនៃជំងឺ ASF ខាងក្នុង ឬក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាតនេះ។

ផែនការអាជីវកម្ម មានសារៈសំខាន់ណាស់សម្រាប់ការកំណត់របៀបប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពសម្រាប់ប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។ ផែនការត្រូវតែបានពិនិត្យឡើងវិញ ហើយប្រសិនបើចាំបាច់ កែសម្រួលជាទៀងទាត់។ ការពិនិត្យផែនការអាជីវកម្មនេះឡើងវិញ អាចធ្វើឡើងដោយដៃគូ និងអាចមានការចូលរួមពីភាគីពាក់ព័ន្ធខាងក្រៅផងដែរ។ គួរមានការពិនិត្យឡើងវិញប្រចាំឆ្នាំជាទៀងទាត់ ទោះយ៉ាងណាក៏ដោយ ក្នុងដំណាក់កាលដំបូងនៃការអនុវត្ត ការពិនិត្យនេះត្រូវធ្វើញឹកញាប់ជាងនេះ។

**កំណត់សំគាល់**

ឯកសារអនឡាញឥតគិតថ្លៃ "Start-COOP. Module 3 – ការរៀបចំផែនការអាជីវកម្ម" ចេញផ្សាយដោយ ILO ផ្តល់ការណែនាំអំពីការរៀបរៀងផែនការអាជីវកម្មសម្រាប់សហករណ៍ ដោយប្រើវិធីសាស្ត្រចូលរួម (ILO 2020c).

បញ្ហាដែលគួរតែត្រូវបានពិចារណាសម្រាប់ការដាក់បញ្ចូល ឬឃោងនៅក្នុងផែនការអាជីវកម្មខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF មានរៀបរាប់ខាងក្រោម។

### ៣.៦.១ បទប្បញ្ញត្តិនានា

មានការសន្មតថា មន្ត្រីបសុពេទ្យមានកាតព្វកិច្ចក្រោមបញ្ញត្តិច្បាប់ជាក់លាក់ ដែលអនុញ្ញាតឱ្យពួកគេអនុវត្តគោលនយោបាយគ្រប់គ្រងជំងឺ។ មន្ត្រីនេះត្រូវជានាថា ការអនុវត្តប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ធ្វើឡើងស្របច្បាប់។

### ៣.៦.២ ការប្រាស្រ័យទាក់ទង និងកិច្ចសហការ

ការអនុវត្ត និងនិរន្តរភាពនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF អាស្រ័យលើចំណេះដឹង និងអាកប្បកិរិយារបស់ដៃគូនានាដែលទាក់ទងនឹងគន្លងហានិភ័យ ASF ហើយត្រូវប្រើប្រាស់របៀបអន្តរាគមន៍បច្ចេកទេស និងការកែប្រែអាកប្បកិរិយាដើម្បីកាត់បន្ថយហានិភ័យ។ នេះមានន័យថា ត្រូវមានការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពក្នុងចំណោមដៃគូ ដែលរួមទាំងមន្ត្រីបសុពេទ្យផងដែរ។ ការប្រាស្រ័យទាក់ទងបែបនេះ ត្រូវតែពាក់ព័ន្ធនឹងការអភិវឌ្ឍចំណេះដឹងបច្ចេកទេស និងដោះស្រាយបញ្ហានៃការលើកទឹកចិត្ត និងឧបសគ្គសម្រាប់តួអង្គនានា នៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ដើម្បីទទួលយក និងអនុវត្តវិធានការកាត់បន្ថយហានិភ័យសមស្រប (Collineau and Stärk, 2019)។

ការអនុវត្តប្រកបដោយជោគជ័យ និងនិរន្តរភាពនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ទាមទារនូវកិច្ចសហការយ៉ាងសកម្មរវាងដៃគូនៃប្រព័ន្ធនេះ ពោលគឺ អ្នកទាំងឡាយនៅក្នុងខ្សែសង្វាក់តម្លៃជ្រូកលក្ខណៈគ្រួសារ និងមន្ត្រីបសុពេទ្យ។

### ៣.៦.៣ ចរាចរណ៍ជ្រូក និងផលិតផលសាច់ជ្រូក

ចរាចរណ៍ជ្រូករស់ និងផលិតផលសាច់ជ្រូកប្រកបដោយសុវត្ថិភាព គឺជាលក្ខខណ្ឌតម្រូវដ៏សំខាន់មួយ ដើម្បីសម្រេចគោលបំណងនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។ ចរាចរណ៍បែបនេះ អាចចែកចេញជាបីប្រភេទធំៗ ដែលរួមទាំង (i) ជ្រូករស់ចូលក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF (ii) ចរាចរណ៍ជ្រូក ឬផលិតផលសាច់ជ្រូក នៅក្នុងប្រព័ន្ធនេះ និង (iii)

រាល់ចរាចរណ៍ទាំងអស់នៅឆ្ងាយពីប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។ ដៃគូគួរព្រមព្រៀងលើរបៀបគ្រប់គ្រងការចរាចរណ៍ទាំងនេះ ដើម្បីរក្សាហានិភ័យនៃការឆ្លង ASFV និងការរីករាលដាល ឱ្យស្ថិតនៅត្រឹម ឬទាបជាងម្រិតហានិភ័យដែលអាចទទួលយកបាននិងដែលព្រមព្រៀងគ្នា។ ដំណើរការលិខិតអនុញ្ញាតដឹកជញ្ជូនផ្អែកលើហានិភ័យ ត្រូវបានពិពណ៌នានៅក្នុង Umber et al., (2019)។

## ៣.៦.៤ សវនកម្ម

ចរាចរណ៍ជ្រូករស់ និងផលិតផលសាច់ជ្រូកប្រកបដោយសុវត្ថិភាព គឺជាលក្ខខណ្ឌតម្រូវដ៏សំខាន់មួយ ដើម្បីសម្រេចគោលបំណងនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។ ចរាចរណ៍បែបនេះ អាចចែកចេញជាបីប្រភេទធំៗ ដែលរួមទាំង (i) ជ្រូករស់ចូលក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF (ii) ចរាចរណ៍ជ្រូក ឬផលិតផលសាច់ជ្រូក នៅក្នុងប្រព័ន្ធនេះ និង (iii) រាល់ចរាចរណ៍ទាំងអស់នៅឆ្ងាយពីប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។ ដៃគូគួរព្រមព្រៀងលើរបៀបគ្រប់គ្រងការចរាចរណ៍ទាំងនេះ ដើម្បីរក្សាហានិភ័យនៃការឆ្លង ASFV និងការរីករាលដាល ឱ្យស្ថិតនៅត្រឹម ឬទាបជាងម្រិតហានិភ័យដែលអាចទទួលយកបាននិងដែលព្រមព្រៀងគ្នា។ ដំណើរការលិខិតអនុញ្ញាតដឹកជញ្ជូនផ្អែកលើហានិភ័យ ត្រូវបានពិពណ៌នានៅក្នុង Umber et al., (2019)។

ផលប្រយោជន៍នៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF សម្រាប់អ្នកពាក់ព័ន្ធទាំងអស់ អាស្រ័យលើការជឿទុកចិត្តរបស់ពួកគេក្នុងការគ្រប់គ្រងហានិភ័យ។ ដំណើរការសវនកម្មដែលអាចទុកចិត្តបាន គឺជាគន្លឹះក្នុងការបង្កើត និងរក្សាទំនុកចិត្ត។ សវនកម្មអាចធ្វើឡើងដោយមន្ត្រីបសុពេទ្យ ឬសវនករឯករាជ្យ តាមការព្រមព្រៀងដោយដៃគូទាំងអស់ក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ។ សវនករ ត្រូវពិនិត្យមើលអនុលោមភាពរបស់តួអង្គនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ដោយប្រើប្រាស់នីតិវិធីគ្រប់គ្រងហានិភ័យ ដែលរួមទាំងជីវសុវត្ថិភាព ការតាមដានឃ្លាំមើល ការកំណត់អត្តសញ្ញាណជ្រូក ការអង្កេតដាន និងការរក្សាកំណត់ត្រា។ ដៃគូទាំងអស់ត្រូវ ត្រូវព្រមព្រៀងគ្នាលើកម្រិតញឹកញាប់នៃសវនកម្ម និងត្រូវដឹងថា ដំណើរការសវនកម្មនឹងមានឥទ្ធិពលជាសំខាន់មកលើភាពជឿជាក់របស់ភាគីពាក់ព័ន្ធខាងក្រៅ មកលើប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ។

នៅក្នុងការធ្វើសវនកម្ម អាចមានការប្រើប្រាស់បញ្ជីស្តង់ដារត្រួតពិនិត្យ។ ឧទាហរណ៍ គេអាចកែសម្រួលបញ្ជីត្រួតពិនិត្យ ជីវសុវត្ថិភាព និងការតាមដានឃ្លាំមើល ដែលមាននៅក្នុងឯកសាររបស់FAO គោលការណ៍ណែនាំសម្រាប់បង្ការ និងគ្រប់គ្រងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) ក្នុងការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារនៅអាស៊ី - ជីវសុវត្ថិភាពកសិដ្ឋាន ការពិឃាតសត្វ និងការធ្វើការចិញ្ចឹមសត្វសត្វឡើងវិញ សម្រាប់ធ្វើសវនកម្ម។ គួរប្រើប្រាស់លទ្ធផលនៃហានិភ័យ ដើម្បីកែសម្រួលបញ្ជីត្រួតពិនិត្យឱ្យស្របនឹងលក្ខខណ្ឌនៅមូលដ្ឋាន។

### ៣.៦.៥ រចនាសម្ព័ន្ធគ្រប់គ្រង

ដើម្បីឱ្យប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF សម្រេចគោលដៅនិរន្តរភាពរបស់ខ្លួន ដៃគូត្រូវព្រមព្រៀងគ្នាលើរចនាសម្ព័ន្ធគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។ ប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាតនេះ គួរតែដឹកនាំដោយគណៈកម្មការតម្រង់ទិសមួយ ដែលអាចផ្តល់ការណែនាំ និងអនុវត្តជំហានទាំងអស់ដែលបានពិពណ៌នាខាងលើ។

**កំណត់សំគាល់**

ឯឯកសារអនឡាញសម្រាប់ការប្រើប្រាស់ដោយឥតគិតថ្លៃStart-COOP.Module 4 - ការចាត់ចែងស្ថាប័ន ចេញផ្សាយដោយ ILO បង្ហាញពីរបៀបរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៃសហករណ៍ដោយប្រើវិធីសាស្រ្តចូលរួម (ILO 2020d)។



© ShutterStock/Patnaree Asavacharanitich

# ៤. អនាគតនៃការអនុវត្តប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត

ឯកសារនេះបង្ហាញពីគោលការណ៍ និងដំណើរការសម្រាប់ការបង្កើតប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ដែលមានគោលដៅជួយសម្រួលដល់ការបន្តធ្វើពាណិជ្ជកម្មផលិតផលជ្រូក និងសាច់ជ្រូកនៅក្នុងបរិបទផលិតកម្មជ្រូកលក្ខណៈគ្រួសារ។ នេះជាគោលគំនិតថ្មីមួយ ដែលត្រូវបានស្នើឱ្យដំណើរការនៅក្រោមឧបករណ៍ផ្អែកលើហានិភ័យ និងគោលគំនិតនៃការគ្រប់គ្រងហានិភ័យដែលកែសម្រួលឱ្យស្របនឹងប្រព័ន្ធផលិតកម្មជ្រូករបស់ផលិតករលក្ខណៈគ្រួសារ។ ដូច្នេះ ការអនុវត្តប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ត្រូវតែផ្អែកលើការវាយតម្លៃហានិភ័យ និងវិធីសាស្ត្រគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ទន្ទឹមនឹងការពិចារណាកាលៈ ទេសៈជាក់លាក់ក្នុងមូលដ្ឋាន សម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព ជាក់ស្តែង និងនិរន្តរភាព។ ប្រការសំខាន់បំផុត គឺដៃគូត្រូវតែព្រមព្រៀងគ្នាលើកម្រិតដែលអាចទទួលយកបាននៃហានិភ័យ ASF ដោយទទួលស្គាល់ថា មិនអាចកាត់បន្ថយហានិភ័យ ASF ឱ្យដល់សូន្យបានឡើយ។

ដើម្បីឱ្យប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF អាចដំណើរការបាន ហានិភ័យ ASF ដែលបានកាត់បន្ថយនៅក្នុងប្រព័ន្ធនេះ ត្រូវតែផ្តល់ប្រយោជន៍ខាងសេដ្ឋកិច្ចដល់ដៃគូរបស់ខ្លួន តាមរយៈភាពជាដៃគូសាធារណៈ-ឯកជន។ ភាគីពាក់ព័ន្ធដែលមានឥទ្ធិពលលើហានិភ័យនៃការឆ្លងASFV និងដែលរំពឹងចង់បានប្រយោជន៍ពីប្រព័ន្ធនេះ អាចផ្តួចផ្តើមការអនុវត្តនៅក្នុងក្រុមស្នូលមួយ។ សហករណ៍មួយនៃក្រុមអ្នកចិញ្ចឹមជ្រូកលក្ខណៈគ្រួសារ អាចជាគំរូដ៏ល្អមួយ នៃតួអង្គស្នូលទាំងនេះ ដោយសារគោលបំណងនៃប្រព័ន្ធនេះ គឺការផ្តល់ប្រយោជន៍ខាងសេដ្ឋកិច្ចដល់សមាជិករបស់ខ្លួន ដែលស្រដៀងនឹងការលើកទឹកចិត្តសម្រាប់ការអនុវត្តខ្សែសង្វាក់ផ្គត់ផ្គង់ស្អាតដែរ ហើយរចនាសម្ព័ន្ធ និងទំហំនៃសហករណ៍ ទំនងជាអនុញ្ញាតឱ្យមានការចូលរួមនៅក្នុងដំណើរការធ្វើការសម្រេចចិត្ត និងការសម្របខ្លួនយ៉ាងស្វាហាប់ ក្នុងការកែប្រែបរិបទហានិភ័យ ASF។ មន្ត្រីបសុពេទ្យត្រូវតែចូលរួម ក្នុងនាមជាដៃគូសាធារណៈ ព្រោះថា ការគ្រប់គ្រង ASF ដែលរួមទាំង ការឆ្លើយតបទៅនឹងការផ្ទុះឡើងនៃមេរោគ គឺជាការទទួលខុសត្រូវរបស់ពួកគេ។ ប្រសិនបើការផ្ទុះឡើងនៃជំងឺ ASF កើតឡើងនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ដំណើរការនានាដែលមានការឯកភាពជាមួយមន្ត្រីបសុពេទ្យសម្រាប់ការអនុវត្តវិធានការត្រួតពិនិត្យឱ្យមានប្រសិទ្ធភាព ក៏អាចជួយប្រព័ន្ធនេះឱ្យបន្តការជួញដូរផលិតផលជ្រូក និងសាច់ជ្រូកនៅក្នុងប្រព័ន្ធបានភ្លាមៗផងដែរ។

# ឧបសម្ព័ន្ធទី ១៖ វិធីសាស្រ្តវាយតម្លៃហានិភ័យ និងកាត់បន្ថយហានិភ័យ ក្នុងបរិបទនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត

ឧបសម្ព័ន្ធនេះពណ៌នាអំពីជំហានផ្សេងគ្នានៃការវាយតម្លៃហានិភ័យ និងការកាត់បន្ថយហានិភ័យ ដែលត្រូវអនុវត្តជាចាំបាច់ នៅមុនពេលចាប់ផ្តើមបង្កើតប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ។

## ១. ការពណ៌នាអំពីខ្សែសង្វាក់តម្លៃលក្ខណៈគ្រួសារសម្រាប់ជ្រូកនិងផលិតផលសាច់ជ្រូក

ជំហានដំបូង គឺត្រូវស្វែងយល់ពីខ្សែសង្វាក់តម្លៃសម្រាប់ជ្រូក និងផលិតផលសាច់ជ្រូក នៅក្នុងបរិយាកាសក្នុងស្រុក ដែលត្រូវអនុវត្តប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត។ គោលបំណងគឺ ការបង្កើតដ្យាក្រាមខ្សែសង្វាក់តម្លៃដែលពិពណ៌នាអំពីជំហានផ្សេងៗដែលពាក់ព័ន្ធនឹងការកែច្នៃជ្រូក និងផលិតផលសាច់ជ្រូក និងចែកចាយផលិតផលសាច់ជ្រូកដល់អ្នកប្រើប្រាស់។ ដូច្នេះតាមធម្មតា ដ្យាក្រាមចាប់ផ្តើមពីកសិដ្ឋានចិញ្ចឹមជ្រូក និងត្រូវបញ្ចប់ត្រឹមអ្នកប្រើប្រាស់ ហើយគ្រប់ជំហានទាំងអស់រវាងចំណុចទាំងពីរនេះ ត្រូវបានភ្ជាប់ដោយព្រួញកំណត់ទិស (សូមមើលរូបភាព A1)។ ការកំណត់អត្តសញ្ញាណតួអង្គដែលពាក់ព័ន្ធនឹងដំណើរការនេះ ក៏ចាំបាច់ផងដែរ ដោយសារពួកគេអាចមានតួនាទីក្នុងការគ្រប់គ្រងហានិភ័យ ASF។ នៅក្នុងខ្សែសង្វាក់តម្លៃជ្រូកលក្ខណៈគ្រួសារ ជាទូទៅតួអង្គសំខាន់ៗគឺ អ្នកផ្គត់ផ្គង់ធាតុចូល និងអ្នកផ្តល់សេវាសម្រាប់ការផលិតជ្រូក អ្នកផលិតជ្រូក អ្នកប្រមូលទិញជ្រូក ឬឈ្មួញ (រួមទាំងឈ្មួញកណ្តាល) អ្នកគ្រប់គ្រងសត្តឃាតដ្ឋាន អ្នកពិឃាតសត្វ អ្នកលក់ដុំ អ្នកលក់រាយ និងអ្នកប្រើប្រាស់ (Baltenweck et al., 2018; Qiu et al., 2020)។ ជាញឹកញាប់ខ្សែសង្វាក់តម្លៃជ្រូកលក្ខណៈគ្រួសារ អាចត្រូវញែកដាច់ពីផលិតកម្មជ្រូកលក្ខណៈពាណិជ្ជកម្ម។ ប៉ុន្តែប្រសិនបើមានទំនាក់ទំនងជាមួយកសិដ្ឋានចិញ្ចឹមជ្រូកលក្ខណៈពាណិជ្ជកម្មតាមរយៈចំណី ជ្រូករស់ មនុស្ស ឬអ្វីផ្សេងទៀតនោះ ចំណុចទាំងនេះត្រូវតែមានឆ្លុះបញ្ចាំងនៅក្នុងដ្យាក្រាមខ្សែសង្វាក់តម្លៃផងដែរ។

ខ្សែសង្វាក់តម្លៃកសិករលក្ខណៈគ្រួសារ នៅមជ្ឈដ្ឋានដែលខ្សត់ធនធាន ច្រើនតែប្រើប្រាស់ពូជផ្ទាល់ខ្លួន ប៉ុន្តែមានការផ្គត់ផ្គង់ចំណីចម្រុះជាលក្ខណៈពាណិជ្ជកម្ម តាមរយៈបណ្តាញភ្នាក់ងារនានា(Baltenweck et al., 2018)។ អ្នកចិញ្ចឹមលក្ខណៈគ្រួសារជាច្រើន បានទទួលកូនជ្រូកពីមេពូជរបស់ខ្លួនផ្ទាល់ ចំណែកអ្នកចិញ្ចឹមជ្រូកខ្លះ អាចទិញកូនជ្រូកពីក្នុងមូលដ្ឋាន ឬមកពីតំបន់ផ្សេងទៀត។ ជាតុផ្សំនៃចំណីរួមមាន សំណល់ពីផ្ទះបាយ ចំណីដែលរៀបចំដោយខ្លួនឯងពីផលិតផលពោតក្នុងមូលដ្ឋាន ដំណាំចំណីសត្វ និងចំណីផ្សំសម្រេច។ អ្នកចិញ្ចឹមជ្រូកលក្ខណៈគ្រួសារភាគច្រើនពឹងផ្អែកលើប្រភេទ និងប្រភពចំណីចម្រុះ។ អ្នកផលិត អាចទទួលបានចំណីដោយផ្ទាល់ពីក្រុមហ៊ុនផ្គត់ផ្គង់ចំណីសត្វ តាមរយៈរថយន្តតូចៗ និងម៉ូតូ។ តួអង្គខ្លះ

ក្នុងខ្សែសង្វាក់តម្លៃ ពាក់ព័ន្ធក្នុងដំណើរការច្រើនជាងមួយ នៅក្នុងខ្សែសង្វាក់តម្លៃជ្រូកចិញ្ចឹមលក្ខណៈគ្រួសារ។ អ្នកផលិតខ្លះអាចទាក់ទងដោយផ្ទាល់ជាមួយអ្នកលក់រាយ ដើម្បីពិឃាតជ្រូក កាប់សាច់ និងលក់សាច់ជ្រូករបស់ខ្លួន។ ទោះយ៉ាងណាក៏ដោយ ក្នុងករណីភាគច្រើន ឈ្មួញកណ្តាល និងអ្នកប្រមូលទិញ ដើរតួនាទីយ៉ាងសំខាន់ក្នុងការជួញដូរជ្រូករស់ រវាងអ្នកផលិត និងសត្តឃាតដ្ឋាន។ តួអង្គទាំងនេះអាចប្រើប្រាស់វិធីដឹកជញ្ជូន ឬការដឹកជញ្ជូនពាណិជ្ជកម្មផ្ទាល់ខ្លួនរបស់ពួកគេ (ឧ. អ្នកបើកបរដែលមានឯកទេសក្នុងសេវាកម្មដឹកជញ្ជូនបសុសត្វ) ទៅមកពីទីផ្សារជ្រូករស់។ ជាពិសេស ផលិតផលជ្រូក និងសាច់ជ្រូកពីប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF អាចលាយឡំជាមួយផលិតផលដែលមកពីកសិដ្ឋានចិញ្ចឹមជ្រូកផ្សេងទៀតនៅក្នុងទីផ្សារជ្រូក ដែលបង្កឱ្យមានកំណើនហានិភ័យនៃការឆ្លង ASFV។ ដូច្នេះ ទីផ្សារជ្រូករស់ ពាណិជ្ជករ ឈ្មួញកណ្តាល និងអ្នកប្រមូលទិញ មានតួនាទីជាសំខាន់នៅក្នុងការចម្លង និងការរីករាលដាលរបស់ ASFV (Baltenweck et al., 2018; Qiu et al., 2020។ ទីបំផុតអ្នកលក់ដុំ និងអ្នកលក់រាយ ក្លាយជាអ្នកតភ្ជាប់ដ៏សំខាន់ សត្តឃាតដ្ឋាន ទៅអ្នកប្រើប្រាស់។

## រូបភាព A1. ឧទាហរណ៍មួយអំពីខ្សែសង្វាក់តម្លៃជ្រូកចិញ្ចឹមលក្ខណៈគ្រួសារ



## ២. ការវាយតម្លៃហានិភ័យ ASF

### ២.១ ការកំណត់សំណួរហានិភ័យ

គោលបំណងដែលបានព្រមព្រៀងគ្នាក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF អាចកាត់បន្ថយលទ្ធភាពនៃការចម្លង ASFV ចូល និងរីករាលដាលនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។ ចំណុចនេះត្រូវតែបកស្រាយទៅជាសំណួរហានិភ័យមួយ ឬច្រើន អាស្រ័យលើគន្លងហានិភ័យដែលកំពុងពិចារណា។ ដៃគូដែលពាក់ព័ន្ធនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF អាចចង់ផ្ដោតលើសំណួរហានិភ័យចម្បងមួយ ឬពីរ ដើម្បីរារាំងកិច្ចការនេះកុំឱ្យចំណាយពេលយូរ ឬស្មុគស្មាញពេក។ សំណួរហានិភ័យផ្សេងទៀត នឹងអាចបន្ថែមនៅដំណាក់កាលក្រោយ នៅពេលដែលដៃគូមានអារម្មណ៍ល្អជាមួយអត្ថប្រយោជន៍នៃវិធីសាស្ត្រនេះ។ សំណួរ ហានិភ័យក៏អាចស្មុគស្មាញផងដែរ អាស្រ័យលើដៃគូនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ហើយតាមពិតពួកគេអាចសម្រេចចិត្តកែសម្រួលសំណួរហានិភ័យដែលបង្ហាញខាងក្រោមឱ្យកាន់តែសាមញ្ញ ដើម្បីងាយស្រួលទាក់ទងគ្នាក្នុងចំណោមដៃគូ៖

**សំណួរហានិភ័យ A**

តើការនាំចូលជ្រូករស់ តាមរយៈការធ្វើពាណិជ្ជកម្មស្របច្បាប់ពីកសិដ្ឋាននៅខាងក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF នឹងមានលទ្ធភាពកម្រិតណា ក្នុងការធ្វើឱ្យយ៉ាងហោចណាស់ជ្រូកមួយក្បាលក្នុងកសិដ្ឋានលក្ខណៈគ្រួសារមួយ នៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ឆ្លងមេរោគ ASFV ក្នុងមួយឆ្នាំៗ?

**សំណួរហានិភ័យ B**

តើយានជំនិះដែលប្រើសម្រាប់ដឹកជញ្ជូនជ្រូករស់ទៅកាន់សត្តឃាតដ្ឋាននៅក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF នឹងមានលទ្ធភាពកម្រិតណា ក្នុងការធ្វើឱ្យយ៉ាងហោចណាស់ជ្រូកមួយក្បាលក្នុងកសិដ្ឋានចិញ្ចឹមលក្ខណៈគ្រួសារមួយនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ឆ្លងមេរោគ ASFV ក្នុងមួយឆ្នាំៗ?

**សំណួរហានិភ័យ C**

តើចំណីជ្រូកដែលទិញមកពីខាងក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF នឹងមានលទ្ធភាពកម្រិតណា ក្នុងការធ្វើឱ្យយ៉ាងហោចណាស់ជ្រូកមួយក្បាល ក្នុងកសិដ្ឋានចិញ្ចឹមលក្ខណៈគ្រួសារមួយនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ឆ្លងមេរោគ ASFV ក្នុងមួយឆ្នាំៗ?

**សំណួរហានិភ័យ D**

តើការដឹកជញ្ជូនជ្រូករស់នៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ពីកសិដ្ឋានលក្ខណៈគ្រួសារមួយ ទៅកសិដ្ឋានមួយទៀតនឹងមានលទ្ធភាពកម្រិតណា ក្នុងការធ្វើឱ្យយ៉ាងហោចណាស់ជ្រូកមួយក្បាល នៅក្នុងយ៉ាងហោចណាស់កសិដ្ឋានលក្ខណៈគ្រួសារមួយ ឆ្លងមេរោគ ASFV ក្នុងមួយឆ្នាំៗ?

## ២.២ ការបង្កើតដ្យាក្រាមគន្លងហានិភ័យ

ផ្អែកលើចំណេះដឹងរួមគ្នាអំពីជំងឺរាតត្បាត ASF និងខ្សែសង្វាក់តម្លៃ ដ្យាក្រាមគន្លងហានិភ័យត្រូវបានបង្កើតឡើងសម្រាប់សំណួរហានិភ័យនីមួយៗ ដើម្បីពិពណ៌នាអំពីដំណើរការរោគរាតត្បាតទៅតាមលំដាប់នៃជំហាននានា។ សកម្មភាពនេះក៏មានសារៈសំខាន់ផងដែរ ដោយសារវាអាចឱ្យយើងមើលឃើញយន្តការនានាសម្រាប់ចម្លងASFV ចូលទៅក្នុង និងសាយភាយនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ហេតុនេះវាជួយពង្រឹងអនុលោមភាពជាមួយវិធានការកាត់បន្ថយហានិភ័យ។ ត្រូវប្រើប្រាស់រចនាសម្ព័ន្ធតាមលំដាប់លំដោយនៃដ្យាក្រាមគន្លងហានិភ័យ ដើម្បីបង្ហាញពីសារៈសំខាន់នៃសកម្មភាព‘ដើមខ្សែ’ ក្នុងការកំណត់ហានិភ័យ ASF ‘ចុងខ្សែ’។ តួអង្គក្នុងខ្សែសង្វាក់តម្លៃដែលមានឥទ្ធិពលលើព្រឹត្តិការណ៍‘ដើមខ្សែ’ អាចមានសារៈសំខាន់សម្រាប់ការគ្រប់គ្រងហានិភ័យប្រកបដោយប្រសិទ្ធភាព ដែលតួអង្គទាំងនោះខ្លួនឯងប្រហែលពុំបានដឹងទៀតផង។

នៅក្នុងដំណើរការវាយតម្លៃហានិភ័យ ជំហាននេះអាចត្រូវបានបញ្ចប់ដោយការប្រើដ្យាក្រាមគន្លងហានិភ័យទូទៅ ដែលមានបង្ហាញជូនខាងក្រោម ប៉ុន្តែអាចកែសម្រួលដ្យាក្រាមទាំងនេះឱ្យស្របតាមលក្ខណៈនៃបរិបទហានិភ័យASFក្នុងមូលដ្ឋាន។ ដូចបានបញ្ជាក់ក្នុងផ្នែកមុន ការចាប់ផ្តើមពីសំណួរហានិភ័យ ១ ឬ ២ បន្ទាប់មកបង្កើតដ្យាក្រាមគន្លងហានិភ័យមួយ ក្នុងសំណួរហានិភ័យមួយ អាចជាប្រការសមហេតុផល។ តារាង A1 បង្ហាញឧទាហរណ៍នៃដ្យាក្រាមគន្លងហានិភ័យដែលអាចមានសម្រាប់សំណួរហានិភ័យដែលបានស្នើឡើងខាងលើ។

**កំណត់សំគាល់**

ដ្យាក្រាមគន្លងហានិភ័យក្នុងឧទាហរណ៍ទាំងនេះ មានលក្ខណៈសាមញ្ញណាស់ ហើយក្នុងអំឡុងពេលពិភាក្សាជាមួយដៃគូក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ជំហានសំខាន់ៗផ្សេងទៀតក្នុងគន្លងហានិភ័យទំនងជាបង្ហាញឱ្យឃើញជាក់ស្តែង។ ប្រសិនបើរឿងនេះកើតឡើង វាគួរតែចាត់ទុកថាជាជោគជ័យ ព្រោះមានន័យថាការចូលរួមជាមួយដៃគូប្រព្រឹត្តទៅបានយ៉ាងល្អ។ នៅពេលចាប់ផ្តើមដំណើរការវាយតម្លៃហានិភ័យ ដៃគូមួយចំនួន ភាគច្រើន ឬទាំងអស់ទំនងជាលំបាកយល់គោលគំនិតអំពីហានិភ័យ។ បុគ្គលិកមន្ត្រីបសុពេទ្យត្រូវមានតួនាទីណែនាំដៃគូក្នុងខ្សែ សង្វាក់ផ្គត់ផ្គង់ស្អាត ASF តាមរយៈដំណើរការនៃការបង្កើតការយល់ដឹងអំពីហានិភ័យ។

លើសពីនេះ សំណួរហានិភ័យទាំងនេះពុំមានចេតនាដើម្បីបញ្ចូលវិធានការកាត់បន្ថយហានិភ័យជាក់លាក់ណាមួយឡើយ។ សំណួរទាំងនេះនឹងត្រូវបញ្ចូលបន្ថែមនៅពេលរៀបចំផែនការគ្រប់គ្រងហានិភ័យ។

**តារាង A1.** ឧទាហរណ៍អំពីដ្យាក្រាមគន្លងហានិភ័យសម្រាប់សំណួរហានិភ័យមួយចំនួន

**A:** តើការនាំចូលជ្រូករស់ តាមរយៈការធ្វើពាណិជ្ជកម្មស្របច្បាប់ពីកសិដ្ឋាននៅខាងក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF នឹងមានលទ្ធភាពកម្រិតណា ក្នុងការធ្វើឱ្យយ៉ាងហោចណាស់ជ្រូកមួយក្បាលក្នុងកសិដ្ឋានលក្ខណៈគ្រួសារមួយ នៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ឆ្លងមេរោគ ASFV ក្នុងមួយឆ្នាំៗ?



**B:** តើយានជំនិះដែលប្រើសម្រាប់ដឹកជញ្ជូនជ្រូករស់ទៅកាន់សត្តឃាតដ្ឋាននៅក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF នឹងមានលទ្ធភាពកម្រិតណា ក្នុងការធ្វើឱ្យយ៉ាងហោចណាស់ជ្រូកមួយក្បាលក្នុងកសិដ្ឋានចិញ្ចឹមលក្ខណៈគ្រួសារមួយនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ឆ្លងមេរោគ ASFV ក្នុងមួយឆ្នាំៗ?



**C:** តើចំណីជ្រូកដែលទិញមកពីខាងក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF នឹងមានលទ្ធភាពកម្រិតណា ក្នុងការធ្វើឱ្យយ៉ាងហោចណាស់ជ្រូកមួយក្បាល ក្នុងកសិដ្ឋានចិញ្ចឹមលក្ខណៈគ្រួសារមួយនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ឆ្លងមេរោគ ASFV ក្នុងមួយឆ្នាំៗ?



**D:** តើការដឹកជញ្ជូនជ្រូករស់នៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ពីកសិដ្ឋានលក្ខណៈគ្រួសារមួយ ទៅកសិដ្ឋានមួយទៀត នឹងមានលទ្ធភាពកម្រិតណា ក្នុងការធ្វើឱ្យយ៉ាងហោចណាស់ជ្រូកមួយក្បាល នៅក្នុងយ៉ាងហោចណាស់កសិដ្ឋានលក្ខណៈគ្រួសារមួយ ឆ្លងមេរោគ ASFV ក្នុងមួយឆ្នាំៗ?



## ២.៣ ការប៉ាន់ប្រមាណហានិភ័យ ASF

ដំណើរការប៉ាន់ប្រមាណហានិភ័យមានសារៈសំខាន់។ ទីមួយ វាកំណត់អំពីកម្រិតហានិភ័យ ដែលបន្ទាប់មកគួរតែអាច ប្រៀបធៀបជាមួយហានិភ័យដែលអាចទទួលយកបាន និងដែលព្រមព្រៀងសម្រាប់ប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។ ទីពីរ វាអាចឱ្យមានការវាយតម្លៃប្រសិទ្ធភាពនៃវិធានការកាត់បន្ថយហានិភ័យដែលមានស្រាប់ ដែលបន្ទាប់មកគួរតែជាមូលដ្ឋានសម្រាប់ការសម្រេចចិត្តអំពីតំបន់សក្តានុពលនៅតាមគន្លងហានិភ័យ ដែលវិធានការកាត់បន្ថយហានិភ័យបន្ថែមគួរតែបានដាក់ឱ្យអនុវត្ត ដើម្បីកាត់បន្ថយកម្រិតហានិភ័យ។

**កំណត់សំគាល់**

អាស្រ័យលើដៃគូដែលពាក់ព័ន្ធនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ក្នុងការសម្រេចថា តើផ្នែកនេះនៃដំណើរការវាយតម្លៃហានិភ័យ គួរតែធ្វើឱ្យបានលំអិតកម្រិតណា។

ផ្នែកដំបូងនៃដំណើរការប៉ាន់ប្រមាណហានិភ័យ គឺការកំណត់តម្រូវការទិន្នន័យ និងកំណត់ប្រភពទិន្នន័យដោយផ្អែកលើដ្យាក្រាមគន្លងហានិភ័យ។ ផ្នែកទីពីរ គឺប្រមូលទិន្នន័យ និងវាយតម្លៃភាពពេញលេញ និងភាពត្រឹមត្រូវរបស់វា។ ផ្នែកទីបី គឺជាការប៉ាន់ប្រមាណលទ្ធភាពនៅជំហាននីមួយៗ ហើយផ្នែកទីបួន គឺការបញ្ចូលទិន្នន័យទាំងនោះទៅក្នុងការគណនាហានិភ័យរួមសម្រាប់គន្លងហានិភ័យ។ ហើយប្រសិនបើមានគន្លងហានិភ័យដាច់ដោយឡែកពីគ្នាមួយចំនួន ដូចជា គន្លងហានិភ័យ A, B, និង C ការបញ្ចូលផ្នែកទី ៥ ដើម្បីរួមបញ្ចូលគ្នានូវការប៉ាន់ប្រមាណហានិភ័យទៅជាការប៉ាន់ប្រមាណហានិភ័យទាំងមូលមួយ ដែលបន្ទាប់មកអាចយកមកពិចារណា ធៀបនឹងកម្រិតហានិភ័យដែលមានការព្រមព្រៀងគ្នាថាអាចទទួលយកបាន គឺជាការចាំបាច់។

### ២.៣.១ ការប៉ាន់ប្រមាណហានិភ័យ ផ្នែកទី ១ – កំណត់តម្រូវការទិន្នន័យនិងកំណត់អត្តសញ្ញាណប្រភពទិន្នន័យ

តារាង A2 បង្ហាញពីតម្រូវការទិន្នន័យសម្រាប់សំណួរហានិភ័យ A. ជារឿយៗ ការបង្កើតប្រយោគគុណភាពអំពីតួលេខទាំងនេះ មានត្រឹមតែជាលទ្ធភាពប៉ុណ្ណោះ។ គេអាចប្រើប្រាស់ជំពូកនៃលទ្ធភាព និងភាពមិនច្បាស់លាស់ដែលមានរាយក្នុងតារាង A3 និងតារាង A4។ បន្ទាប់ពីកំណត់តម្រូវការទិន្នន័យ គេត្រូវកំណត់ប្រភពដែលមានសក្តានុពលនៃទិន្នន័យបែបនេះ។

**តារាង A2.** ឧការប្រមូលទិន្នន័យចាំបាច់ត្រូវភ្ជាប់ជាមួយនឹងសំណួរហានិភ័យ A "តើការនាំចូលជ្រូករស់ តាមរយៈការធ្វើពាណិជ្ជកម្មស្របច្បាប់ពីកសិដ្ឋាននៅខាងក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF អាចមានលទ្ធភាពកម្រិតណា ក្នុងការធ្វើឱ្យយ៉ាងហោចណាស់ជ្រូកមួយក្បាលក្នុងកសិដ្ឋានតូចមួយក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ឆ្លងមេរោគASFV ក្នុងមួយឆ្នាំៗ?

| ជំហាននានានៅតាមគន្លងហានិភ័យ | តម្រូវការប្រមូលទិន្នន័យ |
|---|---|
| ជ្រូកឆ្លង ASFV មានវត្តមាននៅក្នុងប្រទេស/តំបន់/តំបន់រដ្ឋបាល ដែលកសិដ្ឋាននាំចូលស្ថិតនៅ | ស្ថានភាពឆ្លងរោគ ASFV ក្នុងតំបន់ភូមិសាស្ត្រដែលជាកន្លែងតាំងនៅនៃកសិដ្ឋានដើម |
| ជ្រូកឆ្លងមេរោគ ASFV មានវត្តមាននៅក្នុងកសិដ្ឋាននាំចូល | កម្រិតរាលដាលនៃកសិដ្ឋានដែលមានមេរោគ ASFV នៅក្នុងតំបន់ភូមិសាស្ត្រនៃប្រភពដើម និងភាពខុសគ្នាដែលអាចកើតមាននៃកម្រិតរាលដាលរវាងប្រភេទកសិដ្ឋាននានា វិធានការជីវសុវត្ថិភាពក្នុងកសិដ្ឋានដើម/នាំចូល |
| ជ្រូកឆ្លង ASFV ត្រូវបានជ្រើសរើសសម្រាប់ពាណិជ្ជកម្ម | កម្រិតរាលដាលនៃ ASFV នៅក្នុងកសិដ្ឋានដើម ការធ្វើតេស្តរោគវិនិច្ឆ័យ និងចត្តាឡីស័ក សម្រាប់ជ្រូកដែលត្រូវជួញដូរ |
| ជ្រូកឆ្លងមេរោគ ASFV មកដល់កសិដ្ឋានចិញ្ចឹមលក្ខណៈគ្រួសារនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF បន្ទាប់ពីការដឹកជញ្ជូន | ព័ត៌មានអំពីរយៈពេលដឹកជញ្ជូន អត្រាជ្រូកស្លាប់ជាដើម និងការធ្វើតេស្តរោគវិនិច្ឆ័យ និងវិធានការចត្តាឡីស័ក ក្នុងអំឡុងពេលដឹកជញ្ជូន ឬក្រោយពេលមកដល់ |
| ជ្រូកឆ្លងមេរោគ ASFV ចម្លងមេរោគទៅជ្រូកដទៃក្នុងកសិដ្ឋានគោលដៅ | រយៈពេលលូតលាស់នៃ ASFV ការបញ្ចេញមេរោគ ឥទ្ធិពលចម្លងការរស់រានមានជីវិតនៃជ្រូកដែលឆ្លងរោគ ការរស់រានមានជីវិតនៃមេរោគនៅក្នុងបរិស្ថាន |

### ២.៣.២ ការប៉ាន់ប្រមាណហានិភ័យ ផ្នែកទី ២ – ការប្រមូល និងវាយតម្លៃទិន្នន័យ

ត្រូវប្រមូលទិន្នន័យពីប្រភពដែលបានកំណត់ និងវាយតម្លៃភាពពេញលេញ និងភាពត្រឹមត្រូវនៃទិន្នន័យទាំងនោះ។ ប្រសិនបើទិន្នន័យដែលប្រមូលបានត្រូវបានចាត់ទុកថាមិនពេញលេញ និង/ឬមិនត្រឹមត្រូវ គេគួរធ្វើការពិចារណានៅពេលវាយតម្លៃភាពមិនច្បាស់លាស់ដែលទាក់ទងនឹងការប៉ាន់ស្មានលទ្ធភាព។ ឧទាហរណ៍នៃជំពូកមិនច្បាស់លាស់ មានបង្ហាញនៅក្នុងតារាង A4 ។

### ២.៣.២ ការប៉ាន់ប្រមាណហានិភ័យ ផ្នែកទី ២ – ប៉ាន់ប្រមាណលទ្ធភាព និងភាពមិនច្បាស់លាស់សម្រាប់ជំហាននីមួយៗនៅតាមគន្លងហានិភ័យ

នៅទីនេះ ទិន្នន័យដែលប្រមូលបានសម្រាប់ជំហាននីមួយៗនៅតាមគន្លងហានិភ័យ នឹងត្រូវបានប្រើប្រាស់ដើម្បីបង្កើតការប៉ាន់ប្រមាណលទ្ធភាពសម្រាប់ជំហានជាក់លាក់នោះ។ ការមើលតែនៅជំហាននីមួយៗ មានសារៈសំខាន់ណាស់ ហើយនេះមិនមែនជាការរួមបញ្ចូលការប៉ាន់ប្រមាណលទ្ធភាពនៃជំហាននោះ ជាមួយលទ្ធផលពីជំហានមុនៗទេ។ ការបញ្ចូលបែបនេះនឹងកើតឡើងនៅក្នុងផ្នែកទី ៣ នៃដំណើរការប៉ាន់ប្រមាណហានិភ័យ។

តារាង A3 បង្ហាញឧទាហរណ៍នៃជំពូកលទ្ធភាពខុសៗគ្នាបែបគុណភាព និងការបកស្រាយជំពូកទាំងនោះ ដែលអាចត្រូវបានប្រើប្រាស់នៅក្នុងការវាយតម្លៃហានិភ័យ។ តារាង A4 បង្ហាញឧទាហរណ៍អំពីជំពូកនៃភាពមិនប្រាកដប្រជាផ្សេងៗគ្នា។ សម្រាប់តារាងទាំងពីរចំនួននៃជំពូក និងការបកស្រាយជំពូកទាំងនេះ អាចត្រូវដែគូពាក់ព័ន្ធក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ធ្វើការកែប្រែ។

**តារាង A3.** និយមន័យជំពូកនៃលទ្ធភាពហានិភ័យតាមបែបគុណភាព

| ការប៉ាន់ប្រមាណលទ្ធភាពហានិភ័យ | និយមន័យ |
|---|---|
| គ្មាន | មានវត្តមានទាបខ្លាំងបំផុត ដែលពុំចាំបាច់កត់សំគាល់ឡើយ |
| ទាបណាស់ | មានវត្តមានទាបខ្លាំង ប៉ុន្តែអាចកត់សំគាល់បាន |
| ទាប | មានវត្តមានទាប និងបានកើតឡើង |
| មធ្យម | មានវត្តមាន និងកើតឡើងម្តងម្កាល |
| ខ្ពស់ | មានវត្តមានកើតឡើងញឹកញាប់ណាស់ |
| ខ្ពស់ណាស់ | ស្ទើរតែកើតឡើងគ្រប់ពេល |

ប្រភព៖ European Food Safety Authority ( EFSA ), 2006; Advisory Committee on the Microbiological Safety of Food ( ACMSF ), 2019

**តារាង A4.** ឧទាហរណ៍អំពីជំពូកគុណភាព សម្រាប់សំដែងភាពមិនប្រាកដប្រជាដែលទាក់ទង នឹងការប៉ាន់ប្រមាណហានិភ័យបែបគុណភាព

| កាជំពូកនៃភាពមិនប្រាកដប្រជាយ | ការបកស្រាយ |
|---|---|
| ទាប | មានទិន្នន័យរឹងមាំ និងពេញលេញ។ ភស្តុតាងរឹងមាំត្រូវបានផ្តល់ជូននៅក្នុងឯកសារយោងជាច្រើន។ អ្នកនិពន្ធរាយការណ៍ពីការសន្និដ្ឋានស្រដៀងគ្នា។ អ្នកជំនាញខ្លះមានបទពិសោធន៍ជាច្រើនអំពីព្រឹត្តិការណ៍នេះ និងមានការព្រមព្រៀងកម្រិតខ្ពស់រវាងអ្នកជំនាញ។ |
| មធ្យម | មានទិន្នន័យមួយចំនួន ប៉ុន្តែមិនទាន់ពេញលេញ។ ភស្តុតាងត្រូវបានផ្តល់ជូនជាឯកសារយោងមួយចំនួនតូច។ អ្នកនិពន្ធរាយការណ៍ពីការសន្និដ្ឋានដែលខុសៗគ្នា។ អ្នកជំនាញមានបទពិសោធន៍តិចតួចអំពីនៃព្រឹត្តិការណ៍ និង/ឬមានកិច្ចព្រមព្រៀងខ្លះៗរវាងអ្នកជំនាញ។ |
| ខ្ពស់ | មានភាពខ្វះខាតទិន្នន័យ ឬគ្មានទិន្នន័យ។ ពុំមានភស្តុតាងជាឯកសារយោងទេ ប៉ុន្តែមាននៅក្នុងរបាយការណ៍ដែលមិនបានបោះពុម្ព ឬផ្អែកលើការសង្កេត ឬទំនាក់ទំនងផ្ទាល់ខ្លួន។ អ្នកនិពន្ធរាយការណ៍ពីការសន្និដ្ឋានដែលខុសពីគ្នាយ៉ាងខ្លាំង។ អ្នកជំនាញមួយចំនួនតូចដែលមានបទពិសោធន៍ពីព្រឹត្តិការណ៍នេះ និង/ឬមានការព្រមព្រៀងគ្នានៅកម្រិតទាប។ |

ប្រភព៖ Fournié et al., 2014

តារាង A5 បង្ហាញពីលទ្ធភាព និងភាពមិនប្រាកដប្រជានៃការប៉ាន់ប្រមាណ ជាមួយអំណះអំណាងរបស់ពួកគេសម្រាប់ជំហាននីមួយៗនៅតាមគន្លងហានិភ័យ។ ត្រូវចងចាំថាជំហាននីមួយៗ លើកលែងតែជំហានទីមួយ សន្មតថាព្រឹត្តិការណ៍ជាទីចាប់អារម្មណ៍ ដែលក្នុងករណីនេះជា ការឆ្លងមេរោគ ASFV បានកើតឡើងក្នុងជំហានមុន។ ដូច្នេះ លទ្ធភាពសម្រាប់ជំហាន "ជ្រូកដែលឆ្លងមេរោគ ASFV ត្រូវបានជ្រើសរើសសម្រាប់ពាណិជ្ជកម្ម" សន្មតថា មានការឆ្លងនៅក្នុងកសិដ្ឋាននេះ។ ជាសំខាន់គួរតែពិចារណានៅដំណាក់កាលនេះផងដែរ ថាតើការប៉ាន់ប្រមាណលទ្ធភាពមួយចំនួន អាចទាបពេក ឬខ្ពស់ពេក ឧទាហរណ៍ ដែលយើងអាច

ជឿជាក់បានថា កម្រិតជីវសុវត្ថិភាពនៅក្នុងកសិដ្ឋានដើម ខ្ពស់គ្រប់គ្រាន់ដើម្បីបន្តការឆ្លងមេរោគដោយភាពជឿជាក់។ ផ្អែកលើការវាយតម្លៃនៃទិន្នន័យដែលប្រមូលបាន គេអាចអះអាងថា វាអាចជាការសមស្របជាងក្នុងការផ្តល់ពិន្ទុឱ្យវានៅត្រឹមកម្រិតទាប (= 'ទាប ប៉ុន្តែកើតឡើង') ជាងលទ្ធភាពទាបណាស់ (= 'ទាបណាស់ ប៉ុន្តែនៅតែអាចសំគាល់បាន')។ អ្នកផ្សេងទៀតក៏អាចបង្កើតការប៉ាន់ប្រមាណលទ្ធភាពផ្សេងគ្នា ជាមួយហេតុផលផ្ទាល់ខ្លួនរបស់ពួកគេផងដែរ។ ជំពូកនៃការពិភាក្សាទាំងនេះគួរតែត្រូវបានធ្វើឡើងក្នុងចំណោមដៃគូ នៅពេលធ្វើការវាយតម្លៃហានិភ័យទាំងនេះ។

**តារាង A5.** ការប៉ាន់ប្រមាណលទ្ធភាព និងភាពមិនប្រាកដប្រជាសម្រាប់ជំហាននីមួយៗតាមច្រកហានិភ័យសម្រាប់សំណួរហានិភ័យ A "តើការនាំចូលជ្រូករស់តាមរយៈការជួញដូរស្របច្បាប់ពីកសិដ្ឋាននៅខាងក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF នឹងមានលទ្ធភាពកម្រិតណា ក្នុងការធ្វើឱ្យយ៉ាងតិចជ្រូកមួយក្បាលក្នុងកសិដ្ឋានតូចមួយនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ឆ្លងមេរោគ ASFV ក្នុងមួយឆ្នាំៗ?

| ជំហាននៅតាមគន្លងហានិភ័យ | តម្រូវការប្រមូលទិន្នន័យ | ការប៉ាន់ប្រមាណលទ្ធភាព | ភាពមិនប្រាកដប្រជា | អំណះអំណាង |
|---|---|---|---|---|
| ជ្រូកឆ្លង ASFV មានវត្តមាននៅក្នុងប្រទេស/តំបន់តំបន់រដ្ឋបាលដែលកសិដ្ឋានដើមស្ថិតនៅ | ស្ថានភាពការឆ្លងមេរោគ ASFV នៃតំបន់ភូមិសាស្ត្រដែលកសិដ្ឋានដើមស្ថិតនៅ | មធ្យម | ទាប | កសិដ្ឋានដើមមានទីតាំងនៅក្នុងខេត្តជិតខាងដែលមានការផ្ទុះជំងឺASFជាប្រចាំ |
| ជ្រូកឆ្លងមេរោគ ASFV មានវត្តមានក្នុងកសិដ្ឋានដើម | កម្រិតរាលដាលនៃកសិដ្ឋានដែលមានមេរោគ ASFV នៅក្នុងតំបន់ភូមិសាស្ត្រនៃប្រភពដើម និងភាពខុសគ្នាដែលអាចកើតមាននៃកម្រិតរាលដាលរវាងប្រភេទកសិដ្ឋានវិធានការជីវសុវត្ថិភាពក្នុងកសិដ្ឋានដើម | ទាប | មធ្យម | កសិដ្ឋានដើមពុំធ្លាប់ជួបប្រទះការផ្ទុះជំងឺ ASF និងមានជីវសុវត្ថិភាពល្អ |

| | | | | |
|---|---|---|---|---|
| ជ្រូកឆ្លងមេរោគ ASFV ត្រូវបានជ្រើសសម្រាប់ពាណិជ្ជកម្ម | កម្រិតរាលដាលនៃ ASFV ក្នុងកសិដ្ឋានដើម ការធ្វើតេស្តរោគវិនិច្ឆ័យនិងចត្តាឡីស័កសម្រាប់ជ្រូកដែលត្រូវជួញដូរ | មធ្យម | មធ្យម | កសិដ្ឋានដើមមិនប្រើវិធីតេស្តរោគវិនិច្ឆ័យ ឬចត្តាឡីស័កមុនពេលដឹកជញ្ជូន |
| ជ្រូកឆ្លងមេរោគ ASFVបានមកដល់កសិដ្ឋានចិញ្ចឹមលក្ខណៈគ្រួសារនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF បន្ទាប់ពីការដឹកជញ្ជូន | ព័ត៌មានអំពីរយៈពេលដឹកជញ្ជូន អត្រាជ្រូកស្លាប់។ល។ រយៈពេលលូតលាស់នៃASFV, ការរស់រានមានជីវិតនៃជ្រូកឆ្លងរោគ ការធ្វើតេស្តរោគវិនិច្ឆ័យ និងវិធានការចត្តាឡីស័កក្នុងអំឡុងពេលដឹកជញ្ជូន | ខ្ពស់ | ទាប | គ្មានចត្តាឡីស័កក្នុងកសិដ្ឋានគោលដៅ គ្មានការធ្វើតេស្តរោគវិនិច្ឆ័យ និងមានអត្រាជ្រូកស្លាប់ទាបបំផុតក្នុងអំឡុងពេលដឹកជញ្ជូន |
| ជ្រូកឆ្លងមេរោគ ASFV ចម្លងទៅជ្រូកដទៃក្នុងកសិដ្ឋានគោលដៅ | រយៈពេលលូតលាស់នៃ ASFV, ការបញ្ចេញមេរោគ ការឆ្លង ការរស់រានមានជីវិតនៃជ្រូកដែលមានមេរោគ ការរស់រានមានជីវិតនៃមេរោគនៅក្នុងបរិស្ថាន | ខ្ពស់ | ទាប | ជ្រូកដែលឆ្លងមេរោគទំនងជាបញ្ចេញមេរោគក្នុងបរិមាណច្រើន ASFVអាចរស់បានពីច្រើនថ្ងៃទៅច្រើនសប្តាហ៍នៅក្នុងបរិស្ថាន |

## ២.៣.៣ ការវាយតម្លៃហានិភ័យ ផ្នែកទី ៤ – បាន់ប្រមាណហានិភ័យទាំងមូលសម្រាប់សំណួរហានិភ័យ

ដោយប្រើម៉ាទ្រីសបង្កំហានិភ័យដែលបង្ហាញក្នុងតារាងA6 ត្រូវរួមបញ្ចូលលទ្ធភាពរវាងជំហានបន្តបន្ទាប់ ដើម្បីប៉ាន់ប្រមាណលទ្ធភាព ឬហានិភ័យទាំមូលនៃការឆ្លងមេរោគ ASFV មកលើជ្រូកដែលងាយរងគ្រោះ នៅក្នុងកសិដ្ឋានលក្ខណៈគ្រួសារដែលពាក់ព័ន្ធក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។ លទ្ធផលនៃដំណើរការប៉ាន់ប្រមាណនេះ មានបង្ហាញក្នុងតារាង A7 នៅក្នុងជួរឈរ "លទ្ធភាពសរុប"។ លទ្ធផលនៃដំណើរការប៉ាន់ប្រមាណអំពីលទ្ធភាពដែលការនាំចូលជ្រូករស់ តាមរយៈការជួញដូរស្របច្បាប់ពីកសិដ្ឋាននៅខាងក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ដែលនាំឱ្យយ៉ាងហោចណាស់ជ្រូកមួយក្បាលក្នុងកសិដ្ឋានចិញ្ចឹមលក្ខណៈគ្រួសារមួយនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ឆ្លងមេរោគ ASFV ក្នុងមួយឆ្នាំៗ មាន អត្រា´ទាប´។

**តារាង A6.** ការប្រើប្រាស់ម៉ាទ្រីសប្រើសម្រាប់ការបញ្ចូលលទ្ធភាពបែបគុណភាព អាស្រ័យតាមលក្ខខណ្ឌពីរក្នុងនោះ លទ្ធភាពទី ២ អាស្រ័យលើលក្ខខណ្ឌនៃលទ្ធភាពទី ១

| លទ្ធភាពទី ១ | លទ្ធភាពទី ២ | | | | | |
|---|---|---|---|---|---|---|
| | ផាត់ចោលបាន | ទាបណាស់ | ទាប | មធ្យម | ខ្ពស់ | ខ្ពស់ណាស់ |
| គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន |
| ទាបណាស់ | គ្មាន | ទាបណាស់ | ទាបណាស់ | ទាបណាស់ | ទាបណាស់ | ទាបណាស់ |
| ទាប | គ្មាន | ទាបណាស់ | ទាប | ទាប | ទាប | ទាប |
| មធ្យម | គ្មាន | ទាបណាស់ | ទាប | មធ្យម | មធ្យម | មធ្យម |
| ខ្ពស់ | គ្មាន | ទាបណាស់ | ទាប | មធ្យម | ខ្ពស់ | ខ្ពស់ |
| ខ្ពស់ណាស់ | គ្មាន | ទាបណាស់ | ទាប | មធ្យម | ខ្ពស់ | ខ្ពស់ណាស់ |

ប្រភព៖ Gale et al., 2010; Peeler et al., 2015

**តារាង A7.** ការរួមបញ្ចូលគ្នានូវលទ្ធភាពរវាងជំហានតាមគន្លងហានិភ័យសម្រាប់សំណួរហានិភ័យ A "តើការនាំចូលជ្រូករស់តាមរយៈការជួញដូរស្របច្បាប់ពីកសិដ្ឋាននៅខាងក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF នឹងមានលទ្ធភាពកម្រិតណា ក្នុងការធ្វើឱ្យយ៉ាងហោចណាស់ជ្រូកមួយក្បាលនៅក្នុងកសិដ្ឋានលក្ខណៈគ្រួសារមួយនៅក្នុងប្រព័ន្ធខ្សែសង្វាក់ស្អាត ASF ឆ្លងមេរោគ ASFV ក្នុងមួយឆ្នាំៗ?

| ជំហាននៅតាមគន្លងហានិភ័យ | តម្រូវការប្រមូលទិន្នន័យ | ការប៉ាន់ប្រមាណលទ្ធភាព | ភាពមិនប្រាកដប្រជា | អំណះអំណាង |
|---|---|---|---|---|
| ជ្រូកឆ្លង ASFV មានវត្តមាននៅក្នុងប្រទេស/តំបន់/តំបន់រដ្ឋបាលដែលកសិដ្ឋានដើមស្ថិតនៅ | ស្ថានភាពការឆ្លងមេរោគ ASFV នៃតំបន់ភូមិសាស្ត្រដែលកសិដ្ឋានដើមស្ថិតនៅ | មធ្យម | កសិដ្ឋានដើមមានទីតាំងនៅក្នុងខេត្តជិតខាងដែលមានការផ្ទុះជំងឺASFជាប្រចាំ | |
| ជ្រូកឆ្លងមេរោគ ASFV មានវត្តមានក្នុងកសិដ្ឋានដើម | កម្រិតរាលដាលនៃកសិដ្ឋានដែលមានមេរោគ ASFV នៅក្នុងតំបន់ភូមិសាស្ត្រនៃប្រភពដើម និងភាពខុសគ្នាដែលអាចកើតមាននៃកម្រិតរាលដាលរវាងប្រភេទកសិដ្ឋាន វិធានការជីវសុវត្ថិភាពក្នុងកសិដ្ឋានដើម | ទាប | កសិដ្ឋានដើមពុំធ្លាប់ជួបប្រទះការផ្ទុះជំងឺ ASF ហើយមានជីវសុវត្ថិភាពល្អ | មធ្យម<br>* ទាប<br>= ទាប |

| ជំហាននៅតាមគន្លងហានិភ័យ | តម្រូវការប្រមូលទិន្នន័យ | ការប៉ាន់ប្រមាណលទ្ធភាព | ភាពមិនប្រាកដប្រជា | អំណះអំណាង |
|---|---|---|---|---|
| ជ្រូកមានមេរោគ ASFVត្រូវបានជ្រើសរើសសម្រាប់ពាណិជ្ជកម្ម | កម្រិតរាលដាលមេរោគ ASFV នៅក្នុងកសិដ្ឋានដែលឆ្លងរោគ | មធ្យម | នៅពេលដែល ASFV ត្រូវបានបញ្ចូលទៅក្នុងកសិដ្ឋានវាទំនងជារីករាលដាលពាសពេញក្នុងកសិដ្ឋាននោះ | ទាប<br>* មធ្យម<br>= ទាប |
| ជ្រូកឆ្លងមេរោគ ASFV មកដល់កសិដ្ឋានចិញ្ចឹមលក្ខណៈគ្រួសារនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF បន្ទាប់ពីការដឹកជញ្ជូន | ព័ត៌មានអំពីរយៈពេលដឹកជញ្ជូន អត្រាជ្រូកស្លាប់ ។ល។ រយៈពេលលូតលាស់នៃ ASFV ការរស់រានមានជីវិតនៃជ្រូកឆ្លងមេរោគ ការធ្វើតេស្តរោគវិនិច្ឆ័យ និងវិធានការចត្តាឡីស័កក្នុងពេលដឹកជញ្ជូន | ខ្ពស់ | ជាធម្មតាមានអត្រាស្លាប់ទាបបំផុតក្នុងអំឡុងពេលដឹកជញ្ជូន មិនមានការធ្វើតេស្តរោគវិនិច្ឆ័យទេ។ | Low<br>* High<br>= Low |
| ជ្រូកដែលឆ្លងមេរោគ ASFV ចម្លងមេរោគទៅជ្រូកដទៃនៅក្នុងកសិដ្ឋានគោលដៅ | រយៈពេលលូតលាស់នៃASFV ការបញ្ចេញមេរោគ កម្រិតឆ្លង ការរស់រានមានជីវិតនៃជ្រូកដែលឆ្លងរោគ ការរស់រានមានជីវិតនៃមេរោគនៅក្នុងបរិស្ថាន | ខ្ពស់ | ជ្រូកដែលឆ្លងទំនងជាបញ្ចេញមេរោគក្នុងបរិមាណច្រើន ASFV អាចរស់បានពីច្រើនថ្ងៃទៅច្រើនសប្តាហ៍ក្នុងបរិស្ថាន | ទាប<br>* ខ្ពស់<br>= ទាប |

| | |
|---|---|
| តើការនាំចូលជ្រូករស់តាមរយៈការធ្វើពាណិជ្ជកម្មស្របច្បាប់ពីកសិដ្ឋាននៅខាងក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF នឹងមានលទ្ធភាពកម្រិតណាក្នុងការធ្វើឱ្យយ៉ាងហោចណាស់ជ្រូកមួយក្បាល ក្នុងកសិដ្ឋានចិញ្ចឹមលក្ខណៈគ្រួសារមួយនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ឆ្លងមេរោគ ASFV ក្នុងមួយឆ្នាំៗ? | ទាប |

គេក៏ចាំបាច់ត្រូវបញ្ចូលគ្នានូវភាពមិនប្រាកដប្រជានៃលទ្ធភាព នៅតាមគន្លងហានិភ័យផងដែរ។ វិធានសមហេតុផលតម្រូវឱ្យកំណត់តួលេខខ្ពស់បំផុតនៃការប៉ាន់ប្រមាណភាពមិនប្រាកដប្រជានីមួយៗ នៅក្នុងការប៉ាន់ប្រមាណទាំងមូល។ ក្នុងឧទាហរណ៍របស់យើង ភាពមិនប្រាកដប្រជានៃវិធានលទ្ធភាពត្រូវមានកម្រិត 'មធ្យម'

## ២.៣.៤ ការប៉ាន់ប្រមាណហានិភ័យ ផ្នែកទី ៥ – ការបញ្ចូលកម្រិតប៉ាន់ប្រមាណហានិភ័យនានាសម្រាប់សំណួរហានិភ័យដាច់គ្នាជាច្រើន

ការប៉ាន់ប្រមាណហានិភ័យជារួមនៅទូទាំងសំណួរហានិភ័យដាច់គ្នាជាច្រើន អាចជួបការលំបាក ដោយសារវាមានភាពអត្តនោមតិខ្លាំងពេក ប៉ុន្តែវាគួរតែអាចមានការឯកភាពគ្នាក្នុងចំណោមដៃគូលើការបកស្រាយនេះ។ ប្រសិនបើសំណួរហានិភ័យនីមួយៗនៅក្នុងឧទាហរណ៍ពី A ដល់ C នាំឱ្យមានការប៉ាន់ប្រមាណហានិភ័យមានកម្រិត'ទាប' នេះមានន័យថា យោងតាមនិយមន័យក្នុងតារាង A3 ព្រឹត្តិការណ៍ដែលយ៉ាងហោចណាស់ជ្រូកមួយក្បាល ក្នុងកសិដ្ឋានចិញ្ចឹមលក្ខណៈគ្រួសារមួយ នៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF បានឆ្លងមេរោគ ASFV ក្នុងមួយឆ្នាំៗក្នុងអត្រា 'កម្រ ប៉ុន្តែកើតឡើង'។ វាកើតឡើងបែបនេះសម្រាប់គន្លងនីមួយៗនៃហានិភ័យក្នុងចំណោមគន្លងហានិភ័យទាំងបី ដែលបង្ហាញថា ការប៉ាន់ប្រមាណហានិភ័យទាំងមូល នៅទូទាំងគន្លងហានិភ័យទាំងបី ត្រូវមានកម្រិតខ្ពស់ជាង 'ទាប'។ លទ្ធផលនេះអាចនឹងអាចជឿបាន បើហានិភ័យទាំងមូលមានកម្រិត 'មធ្យម' ពោលគឺ 'ព្រឹត្តិការណ៍កើតឡើងជាប្រចាំ'។ វាមិនសមហេតុផលទេ ក្នុងការចាត់ទុកថាវាមានអត្រា 'ខ្ពស់' ពោលគឺ 'ព្រឹត្តិការណ៍កើតឡើងញឹកញាប់ណាស់' ។ ប៉ុន្តែ ជាឧទាហរណ៍ ប្រសិនបើមានសំណួរហានិភ័យតែពីរ គេអាចសន្និដ្ឋានបានថា ហានិភ័យទាំងមូលនៅតែមានកម្រិត'ទាប'។ ទោះជាការបកស្រាយបែបនេះគួរតែបានធ្វើឡើងតាមរយៈការពិភាក្សាក្នុងចំណោមដៃគូក៏ដោយ ហានិភ័យទាំងមូលមិនគួរទាបជាងការប៉ាន់ស្មានហានិភ័យសម្រាប់សំណួរហានិភ័យដាក់លាក់ណាមួយឡើយ។ តាមពិតទៅ គេអាចចាត់ទុកថាមានប្រយោជន៍ បើការធ្វើបែបនេះតាមគោលការណ៍មូលមតិ ជាងតាមរយៈការបង្កើតវិធានតឹងរ៉ឹងសម្រាប់រួមបញ្ចូលគ្នានូវការប៉ាន់ប្រមាណហានិភ័យបែបគុណភាពទាំងនេះ ព្រោះវានឹងតម្រូវឱ្យដៃគូយល់ពីលក្ខណៈបន្ថែមនៃហានិភ័យដែលទាក់ទងនឹងគន្លងហានិភ័យផ្សេងៗគ្នា។ ប៉ុន្តែ គេក៏អាចចាត់ទុកថាគ្រប់គ្រាន់ផងដែរ ដើម្បីគ្រាន់តែបង្ហាញការប៉ាន់ប្រមាណហានិភ័យ និងភាពមិនប្រាកដប្រជា សម្រាប់សំណួរហានិភ័យនីមួយៗ ដូចជានៅក្នុងតារាង A8 ដូចដែលបានធ្វើនៅក្នុង EFSA (2005, 2006)។

**តារាង A8.** តារាងសង្ខេបនៃការប៉ាន់ប្រមាណហានិភ័យសម្មតិកម្ម និងភាពមិនប្រាកដប្រជានៃការប៉ាន់ប្រមាណទាំងនោះ សម្រាប់សំណួរហានិភ័យ ចំនួនបីក្នុងឧទាហរណ៍ដើម្បីបញ្ចូល ASFV ទៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត បូករួមទាំងការប៉ាន់ប្រមាណហានិភ័យសរុបដែលអាចកើតមាន

| សំណួរហានិភ័យ | ការប៉ាន់ប្រមាណហានិភ័យ | ភាពមិនប្រាកដប្រជា |
|---|---|---|
| **A:** តើការនាំចូលជ្រូករស់ តាមរយៈការធ្វើពាណិជ្ជកម្មស្របច្បាប់ពីកសិដ្ឋាននៅខាងក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF នឹងមានលទ្ធភាពកម្រិតណា ក្នុងការធ្វើឱ្យយ៉ាងហោចណាស់ជ្រូកមួយក្បាលក្នុងកសិដ្ឋានលក្ខណៈគ្រួសារមួយ នៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ឆ្លងមេរោគ ASFV ក្នុងមួយឆ្នាំៗ? | | |
| **B:** តើយានជំនិះដែលប្រើសម្រាប់ដឹកជញ្ជូនជ្រូករស់ទៅកាន់សត្តឃាតដ្ឋាននៅក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF នឹងមានលទ្ធភាពកម្រិតណា ក្នុងការធ្វើឱ្យយ៉ាងហោចណាស់ជ្រូកមួយក្បាលក្នុងកសិដ្ឋានចិញ្ចឹមលក្ខណៈគ្រួសារមួយនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ឆ្លងមេរោគ ASFV ក្នុងមួយឆ្នាំៗ? | | |
| **C:** តើចំណីជ្រូកដែលទិញមកពីខាងក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF នឹងមានលទ្ធភាពកម្រិតណា ក្នុងការធ្វើឱ្យយ៉ាងហោចណាស់ជ្រូកមួយក្បាល ក្នុងកសិដ្ឋានចិញ្ចឹមលក្ខណៈគ្រួសារមួយនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ឆ្លងមេរោគ ASFV ក្នុងមួយឆ្នាំៗ? | | |
| **ការប៉ាន់ប្រមាណហានិភ័យទាំងមូល** | ទាប ទៅ មធ្យម | មធ្យម |

## ៣. ការគ្រប់គ្រងបរិបទហានិភ័យ ASF

### ៣.១ ការប្រៀបធៀបហានិភ័យដែលអាចទទួលយកបាន ជាមួយលទ្ធផលនៃការវាយតម្លៃហានិភ័យ

ដៃគូនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF គួរតែបានព្រមព្រៀងគ្នាលើកម្រិតដែលអាចទទួលយកបាននៃហានិភ័យ ASF ដូចដែលបានរៀបរាប់នៅក្នុងផ្នែក ៣.៣.២។ ដូចដែលស្នើនៅទីនោះ ហានិភ័យដែលអាចទទួលយកបានទាំងមូល ទំនងជាមានកម្រិត ‘ទាបណាស់’ ឬ ‘ទាប’ នៅក្នុងប្រព័ន្ធសង្វាក់ស្អាតភាគច្រើន។

ដោយសន្មតថាដៃគូបានព្រមព្រៀងគ្នាអំពីហានិភ័យទាបខ្លាំង ដែលជាហានិភ័យដែលអាចទទួលយកបាន ហានិភ័យទាំងមូលដែលមានកម្រិតទាប ឬមធ្យម ដូចដែលបានបង្ហាញនៅក្នុងឧទាហរណ៍របស់ ក្នុងតារាង A8 មានន័យថា វិធានការកាត់បន្ថយហានិភ័យ ត្រូវតែអនុវត្តតាមគន្លងហានិភ័យទាំងបី ដើម្បីកាត់បន្ថយហានិភ័យជារួម មកត្រឹម ឬក្រោមកម្រិត ‘ទាបណាស់’ ។

ឥឡូវនេះ ដៃគូនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ត្រូវប្រើការយល់ដឹងរបស់ពួកគេអំពីបរិយាកាសហានិភ័យ ASF ដែលពួកគេបានបង្កើតក្នុងអំឡុងពេលដំណើរការវាយតម្លៃហានិភ័យ ដើម្បីព្រមព្រៀងគ្នាលើវិធានការកាត់បន្ថយហានិភ័យដែលសមរម្យសម្រាប់សំណួរហានិភ័យនីមួយៗ ដែលកម្រិតហានិភ័យរៀងៗខ្លួនបានរួមចំណែកទៅក្នុងហានិភ័យទាំងមូលលើសកម្រិតហានិភ័យដែលអាចទទួលយកបាន។ ក្នុងឧទាហរណ៍របស់យើង នេះជាករណីសម្រាប់សំណួរហានិភ័យទាំងបីដែលបង្ហាញក្នុងតារាង A8។

#### ៣.១.១ ការវិភាគដ្យាក្រាមគន្លងហានិភ័យ ដើម្បីកំណត់ផ្នែកដែលមានសក្តានុពលសម្រាប់កាត់បន្ថយហានិភ័យ

គួរពិនិត្យដ្យាក្រាមគន្លងហានិភ័យសម្រាប់សំណួរហានិភ័យនីមួយៗ ដើម្បីកំណត់ថាតើជំហានណាដែលមានសារៈសំខាន់ជាពិសេសសម្រាប់ការប៉ាន់ប្រមាណហានិភ័យទាំងមូល។ យើងនឹងប្រើសំណួរហានិភ័យ A "តើការនាំចូលជ្រូករស់ តាមរយៈការជួញដូរស្របច្បាប់ពីកសិដ្ឋាននៅខាងក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF នឹងមានលទ្ធភាពកម្រិតណា ក្នុងការធ្វើឱ្យយ៉ាងហោចណាស់ជ្រូកមួយក្បាល ក្នុងកសិដ្ឋានចិញ្ចឹមលក្ខណៈគ្រួសារមួយនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ឆ្លងមេរោគ ASFV ក្នុងមួយឆ្នាំ? ជាឧទាហរណ៍។

ការត្រួតពិនិត្យលទ្ធភាពដែលជាប់ទាក់ទងនឹងជំហាននីមួយៗនៅតាមគន្លងហានិភ័យបង្ហាញថា សុពលភាពនៃការប៉ាន់ប្រមាណហានិភ័យទាំងមូលដែលមានកម្រិត ‘ទាប’ ត្រូវពឹងផ្អែកជាចម្បងលើប្រសិទ្ធភាពនៃវិធានការជីវសុវត្ថិភាពនៅកសិដ្ឋានដើម។ ប្រសិនបើ ស្ថានភាពនេះត្រូវបានចាត់ទុកថាពុំមានប្រសិទ្ធភាពគ្រប់គ្រាន់ ហានិភ័យទាំងមូលគួរតែមានកម្រិត

‘មធ្យម’ ពីព្រោះនៅក្នុងជំហានជាបន្តបន្ទាប់ គេពុំអាចកាត់បន្ថយហានិភ័យនៃការរីករាលដាល ASFV ឡើយ។ ស្ថានភាពនេះបានផ្អែកលើការ សន្មតថា នៅពេលនាំចូល ASFV ទៅក្នុងកសិដ្ឋានចិញ្ចឹមលក្ខណៈគ្រួសារណាមួយ មេរោគសឹងតែរីករាលដាលក្នុងចំណោមជ្រូកទាំងអស់ក្នុងកសិដ្ឋាននោះ ដោយសារអវត្តមាន ឬកម្រិតទាបនៃជីវសុវត្ថិភាពនៅក្នុងកសិដ្ឋាននោះ។ ចំណុចនេះបង្ហាញថា ការបន្ថយហានិភ័យបន្ថែមទៀត គួរតែបានអនុវត្តមុនពេលជ្រូកមកដល់កសិដ្ឋានគោលដៅ ដែលជាផ្នែកមួយនៃប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF។

## ៣.១.២ ការកំណត់អត្តសញ្ញាណវិធានសមស្របសម្រាប់កាត់បន្ថយហានិភ័យ

ឥឡូវនេះ យើងបានកំណត់អត្តសញ្ញាណផ្នែកសំខាន់ៗដែលត្រូវកាត់បន្ថយហានិភ័យ ASF រួចហើយពោលគឺ ការនាំចូលទៅក្នុង និងការចាកចេញពីកសិដ្ឋានដើម និងការនាំចូលទៅក្នុងកសិដ្ឋានគោលដៅ ដៃគូនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ត្រូវពិចារណាថា តើវិធានការកាត់បន្ថយហានិភ័យណាខ្លះមានប្រសិទ្ធភាព ជាក់ស្តែង និងនិរន្តរភាព។ នេះគឺជាផ្នែកសំខាន់នៃដំណើរការប្រាស្រ័យទាក់ទង ដែលពាក់ព័ន្ធនឹងការបង្កើតប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ។

សម្រាប់គន្លងហានិភ័យនេះ មានវិធានការកាត់បន្ថយហានិភ័យមួយចំនួនដែលអាចអនុវត្តបាន។ វិធានការដំបូង គួរតែជាការធ្វើតេស្តរោគវិនិច្ឆ័យ និង/ឬ ការធ្វើចត្តាឡីស័ក សម្រាប់ជ្រូកថ្មីៗ ដែលត្រូវនាំចូល មកពីហ្វូងផ្សេងទៀត និងមុនបញ្ជូនជ្រូកទៅកសិដ្ឋានផ្សេងទៀត។ ចំណុចនេះមានបង្ហាញក្នុងរូបភាព A2។ សំណួរថា តើត្រូវពិចារណាជំហានកាត់បន្ថយហានិភ័យទាំងបី (មុនពេលចូលទៅកសិដ្ឋានដើម មុនចេញពីកសិដ្ឋានដើម និងមុនពេលចូលកសិដ្ឋានគោលដៅ)ឬទេ គឺជាប្រធានបទដែលចាំបាច់ត្រូវពិភាក្សាក្នុងចំណោមដៃគូ និងអ្នកពាក់ព័ន្ធខាងក្រៅ ដូចជាម្ចាស់កសិដ្ឋានដើមជាដើម។ ប៉ុន្តែក្នុងកម្រិតអប្បបរមា ការបំបែកសត្វជ្រូកឱ្យនៅដាច់ពីគេ នៅពេលដែលពួកវាជាកម្មវត្ថុនៃការឆ្លងមេរោគ ឬការតាមដានឃ្លាំមើលជំងឺតាមវិធីគ្លីនិក មុនពេលចូលដល់កសិដ្ឋានគោលដៅ គឺជាលក្ខខណ្ឌតម្រូវមួយ។ ការពិចារណាវិធានការកាត់បន្ថយហានិភ័យផ្សេងទៀត ដូចជាការពង្រឹង ជីវសុវត្ថិភាពនៅកសិដ្ឋានដើម និងសម្រាប់យានជំនិះដឹកជញ្ជូន ក៏មានប្រយោជន៍ផងដែរ។

**រូបភាព A2.** ដ្យាក្រាមគន្លងហានិភ័យ សម្រាប់សំណួរហានិភ័យ A ជាមួយវិធានដែលមាន សក្តានុពលក្នុងការកាត់បន្ថយហានិភ័យ



ចាំបាច់ត្រូវធ្វើការពិនិត្យផលប៉ះពាល់នៃវិធានការទាំងនេះ មកលើការប៉ាន់ប្រមាណហានិភ័យរួមសម្រាប់គន្លងនេះ។ ការធ្វើបែបនេះ ទាមទារឱ្យមានការពិនិត្យមើលផលប៉ះពាល់នៃវិធានការទាំងនោះមកលើលទ្ធភាពនីមួយៗ និងថាតើវិធានការទាំងនោះ ត្រូវបានអនុវត្តដោយភាពជឿជាក់ដែរឬទេ។ ចំណុចចុងក្រោយនេះសំខាន់ណាស់ ហើយវិធានការកាត់បន្ថយហានិភ័យណាមួយដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ដៃគូដែលពាក់ព័ន្ធនឹងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF អាចត្រូវបានចាត់ទុកថាអាចទុកចិត្តបាន ជាងការអនុវត្តដោយភាគីពាក់ព័ន្ធខាងក្រៅ។ នៅក្នុងឧទាហរណ៍របស់យើងអំពីសំណួរហានិភ័យ ចត្តាឡីស័កដែលបានអនុវត្តក្រោយការមកដល់កសិដ្ឋានជាគោលដៅ ដែលជាផ្នែកមួយនៃប្រព័ន្ធសង្វាក់ស្អាត ASF អាចចាត់ទុកថាគួរឱ្យទុកចិត្តបានបំផុត (តារាង A9)។ នេះមានន័យថា ដើម្បីកាត់បន្ថយហានិភ័យ ASF ដែលពាក់ព័ន្ធនឹងការនាំចូលជ្រូកមកពីខាងក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF គេត្រូវមានវិធានការកាត់បន្ថយហានិភ័យពិសេសនេះ។ ប៉ុន្តែលើសពីនេះ កសិដ្ឋានដើម គួរតែអនុវត្តចត្តាឡីស័ក សម្រាប់ជ្រូកចូល និងចេញពីកសិដ្ឋានរបស់ខ្លួន ដូចបង្ហាញក្នុងរូបភាព A2។

**តារាង A9.** ផលប៉ះពាល់នៃវិធានការកាត់បន្ថយហានិភ័យមកលើលទ្ធភាពនៃជំហាននីមួយៗ និងការប៉ាន់ប្រមាណហានិភ័យទាំងមូល

| ជំហាននានានៅតាមគន្លងហានិភ័យ | តម្រូវការប្រមូលទិន្នន័យ | ការប៉ាន់ប្រមាណលទ្ធភាព | អំណះអំណាង | លទ្ធភាពសរុប |
|---|---|---|---|---|
| ជ្រូកឆ្លង ASFV មានវត្តមាននៅក្នុងប្រទេស/តំបន់/តំបន់រដ្ឋបាល ដែលកសិដ្ឋានដើមស្ថិតនៅ | ស្ថានភាពឆ្លងមេរោគ ASFV នៃតំបន់ភូមិសាស្ត្រដែលកសិដ្ឋានដើមស្ថិតនៅ | មធ្យម | កសិដ្ឋានដើមមានទីតាំងនៅក្នុងខេត្តជិតខាងដែលមានការផ្ទុះជំងឺASFជាប្រចាំ | |
| ជ្រូកដែលឆ្លងមេរោគ ASFV មិនត្រូវបានរកឃើញក្នុងអំឡុងពេលចត្តាឡីស័កមុនពេលបញ្ចូលក្នុងកសិដ្ឋានដើម | ភាពរួសនៃតេស្តរោគវិនិច្ឆ័យ (ភាពសាំនិងគ្លីនិក) អំឡុងពេលចត្តាឡីស័ក | ទាបណាស់ | ភាពរួសកម្រិតខ្ពស់នៃតេស្តចត្តាឡីស័កយ៉ាងតិច ២០ ថ្ងៃ។ | មធ្យម<br>* ទាបណាស់<br>= ទាបណាស់ |

**តារាង A9.** ផលប៉ះពាល់នៃវិធានការកាត់បន្ថយហានិភ័យមកលើលទ្ធភាពនៃជំហាននីមួយៗ និងការប៉ាន់ប្រមាណហានិភ័យទាំងមូល(ត)

| ជំហាននានានៅតាមគន្លងហានិភ័យ | តម្រូវការប្រមូលទិន្នន័យ | ការប៉ាន់ប្រមាណលទ្ធភាព | អំណះអំណាង | លទ្ធភាពសរុប |
|---|---|---|---|---|
| ជ្រូកដែលមានមេរោគ ASFV មានវត្តមាននៅក្នុងកសិដ្ឋានដើម | កម្រិតរាលដាលនៃកសិដ្ឋានដែលមានមេរោគ ASFV នៅក្នុងតំបន់ភូមិសាស្ត្រនៃប្រភពដើម និងភាពខុសគ្នាដែលអាចកើតមាននៃកម្រិតរាលដាលរវាងប្រភេទកសិដ្ឋាន វិធានការជីវសុវត្ថិភាពក្នុងកសិដ្ឋានដើម | ទាប | កសិដ្ឋានដើមពុំធ្លាប់ជួបប្រទះ៖ ការផ្ទុះជំងឺ ASF និងមានជីវសុវត្ថិភាពល្អ | ទាបណាស់ * ទាប =ទាបណាស់ |
| ជ្រូកមានមេរោគ ASFV ត្រូវបានជ្រើសរើសសម្រាប់ពាណិជ្ជកម្ម | កម្រិតរាលដាល ASFV នៅក្នុងកសិដ្ឋានដែលឆ្លងមេរោគ | មធ្យម | នៅពេលដែល ASFV ត្រូវបាននាំចូលទៅក្នុងកសិដ្ឋានវាទំនងជារីករាលដាលយ៉ាងទូលំទូលាយនៅក្នុងកសិដ្ឋាននោះ | ទាបណាស់ * មធ្យម = ទាបណាស់ |

**តារាង A9.** ផលប៉ះពាល់នៃវិធានការកាត់បន្ថយហានិភ័យមកលើលទ្ធភាពនៃដំហាននីមួយៗ និងការប៉ាន់ប្រមាណហានិភ័យទាំងមូល (ត)

| ជំហាននានានៅតាមគន្លងហានិភ័យ | តម្រូវការប្រមូលទិន្នន័យ | ការប៉ាន់ប្រមាណលទ្ធភាព | អំណះអំណាង | លទ្ធភាពសរុប |
|---|---|---|---|---|
| ជ្រូកដែលឆ្លងមេរោគ ASFV មិនត្រូវបានរកឃើញក្នុងអំឡុងពេលចត្តាឡីស័កមុនពេលដឹកជញ្ជូនពីប្រភពទៅកសិដ្ឋានគោលដៅ | ភាពរួសនៃតេស្តរោគវិនិច្ឆ័យ (ភាពស៊ាំនិងគ្លីនិក) រយៈពេលចត្តាឡីស័ក | ទាបណាស់ | ភាពរួសខ្ពស់នៃចត្តាឡីស័កយ៉ាងតិច ២០ ថ្ងៃ។ | ទាបណាស់ * ទាបណាស់ = ទាបណាស់ |
| ជ្រូកឆ្លងមេរោគ ASFV មកដល់កសិដ្ឋានចិញ្ចឹមលក្ខណៈគ្រួសារនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF បន្ទាប់ពីការដឹកជញ្ជូន | ព័ត៌មានអំពីរយៈពេលដឹកជញ្ជូន អត្រាជ្រូកស្លាប់ជាដើម និងការធ្វើតេស្តរោគវិនិច្ឆ័យ និងវិធានការចត្តាឡីស័កក្នុងអំឡុងពេលដឹកជញ្ជូន | ខ្ពស់ | ជាធម្មតា មានអត្រាស្លាប់ទាបបំផុតក្នុងអំឡុងពេលដឹកជញ្ជូន គ្មានការធ្វើតេស្តរោគវិនិច្ឆ័យទេ | ទាបណាស់ * ខ្ពស់ = ទាបណាស់ |
| ជ្រូកដែលឆ្លងមេរោគ ASF មិនត្រូវបានរកឃើញក្នុងអំឡុងពេលចត្តាឡីស័ក បន្ទាប់ពីការនាំចូលទៅក្នុងកសិដ្ឋានគោលដៅ | ភាពរួសនៃតេស្តរោគវិនិច្ឆ័យ (ភាពស៊ាំនិងគ្លីនិក) រយៈពេលចត្តាឡីស័ក | ទាបណាស់ | ភាពរួសខ្ពស់ណាស់ចត្តាឡីស័កយ៉ាងតិច២០ថ្ងៃ | ទាបណាស់ * ទាបណាស់ = ទាបណាស់ |

**តារាង A9.** ផលប៉ះពាល់នៃវិធានការកាត់បន្ថយហានិភ័យមកលើលទ្ធភាពនៃជំហាននីមួយៗ និងការប៉ាន់ប្រមាណហានិភ័យទាំងមូល (ត)

| ជំហាននានានៅតាមគន្លងហានិភ័យ | តម្រូវការប្រមូលទិន្នន័យ | ការប៉ាន់ប្រមាណលទ្ធភាព | អំណះអំណាង | លទ្ធភាពសរុប |
|---|---|---|---|---|
| ជ្រូកមានមេរោគ ASFV ចម្លងមេរោគទៅជ្រូកដទៃទៀតក្នុងកសិដ្ឋានគោលដៅ | រយៈពេលលូតលាស់នៃ ASFV ការបញ្ចេញមេរោគ ការឆ្លង ការរស់រានមានជីវិតនៃជ្រូកដែលមានមេរោគ ការរស់រានមានជីវិតនៃមេរោគនៅក្នុងបរិស្ថាន | ខ្ពស់ | ជ្រូកដែលឆ្លងទំនងជាបញ្ចេញមេរោគក្នុងបរិមាណច្រើន ASFV អាចរស់ក្នុងបរិស្ថានបានពីច្រើនថ្ងៃទៅច្រើនសប្តាហ៍ | ទាបណាស់ * ខ្ពស់ = ទាបណាស់ |
| តើការនាំចូលជ្រូករស់តាមរយៈការធ្វើពាណិជ្ជកម្មស្របច្បាប់ពីកសិដ្ឋាននៅខាងក្រៅប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF នឹងមានលទ្ធភាពកម្រិតណា ក្នុងការធ្វើឱ្យយ៉ាងហោចណាស់ជ្រូកមួយក្បាល ក្នុងកសិដ្ឋានចិញ្ចឹមលក្ខណៈគ្រួសារមួយនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ឆ្លងមេរោគ ASFV ក្នុងមួយឆ្នាំ? | | | | ទាបណាស់ |

## ៣.២ ការគ្រប់គ្រងហានិភ័យ និងការតាមដានឃ្លាំមើលដែលផ្អែកលើហានិភ័យ

របកគំឃើញពីការវាយតម្លៃហានិភ័យ នឹងប្រាប់ឱ្យដឹងពីជំហានសំខាន់ៗនៅតាមគន្លងហានិភ័យ ដែលគួរតែមានការបញ្ចូលជាតុផ្សំនៃការតាមដានឃ្លាំមើល។ ការធ្វើបែបនេះ នឹងអនុញ្ញាតឱ្យមានចំណាត់ការការតាមដានឃ្លាំមើលផ្អែកលើហានិភ័យ ដែលគួរអាចបង្កើនប្រសិទ្ធភាពចំណាយ (OIE 2015; Backx et al., 2016)។ ឧទាហរណ៍មួយគឺ ការប្រើប្រាស់ជាយុទ្ធសាស្ត្រនូវបត្តាឡីស័ក វិធានការជីវសុវត្ថិភាព ដែលរួមបញ្ចូលជាមួយធាតុផ្សំនៃប្រព័ន្ធតាមដានឃ្លាំមើលដែលមានគោលដៅរកមើលជំងឺ ASFV និង/ឬ ASF។ គួរផ្ដោតលើជំហាននានានៅតាមគន្លងហានិភ័យ ដែលជាកន្លែងអាចធ្វើបាន និងមានផលប៉ះពាល់តាមការចង់បានមកលើហានិភ័យទាំងមូល។

រូបភាព A3 បង្ហាញគន្លងហានិភ័យសម្រាប់ពាណិជ្ជកម្មរវាងកសិដ្ឋានចិញ្ចឹមជ្រូកនៅខាងក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ។ ដៃគូនៅក្នុងប្រព័ន្ធខ្សែសង្វាក់ផ្គត់ផ្គង់ស្អាត ASF ត្រូវសម្រេចចិត្តថា តើការមានជំហានដាច់ដោយឡែកមួយ (សម្រាប់តែនៅកសិដ្ឋានគោលដៅ) ឬជំហានដាច់ដោយឡែកពីរ (ទាំងនៅកសិដ្ឋានដើម និងគោលដៅ) មានប្រសិទ្ធភាពចំណាយឬទេ។ ការពិចារណាថា តើការប្រើប្រាស់រួមគ្នានូវមធ្យោបាយចត្តាឡីស័ក រវាងកសិដ្ឋានដែលពាក់ព័ន្ធនឹងប្រព័ន្ធខ្សែ សង្វាក់ផ្គត់ផ្គង់ស្អាត ASF អាចធ្វើទៅបានដែរឬទេ ក៏មានប្រយោជន៍ផងដែរ។

**រូបភាព A3.** ដ្យាក្រាមគន្លងហានិភ័យ សម្រាប់សំណួរហានិភ័យ D ជាមួយវិធានការដែលមានសក្តានុពលក្នុងការកាត់បន្ថយហានិភ័យ



# ឯកសារយោង

**Advisory Committee on the Microbiological Safety of Food (ACMSF). 2019.** ***ACMSF approaches to microbiological risk assessment: Discussion paper*** – Update from the ACMSF subgroup on representation of risks. Food Standards Agency UK London, UK. p.21.

**Alarcon, L.V., Allepuz, A. & Mateu, E.** 2021. Biosecurity in pig farms: a review. Porcine Health Management 7, (5).

**Backx, A., Calistri, P., Comin, A., Delabouglise, A., Dorea, F., Goutard, F., Häsler, B.** ***(et al)*** **2016.** ***Best practices for risk-based and cost effective animal health surveillance in the European Union.*** RISKSUR Consortium. pp. 109pp. (also available at www.fp7-risksur.eu/sites/default/files/ documents/publications/riskbasedsurv_BPdoc_FINAL_formatted_03.pdf).

**Baltenweck, L., Thinh, N.T., Nga, N.T.D., Hung, P.V., Nhuan, N.H., Huyen, N.T.T., Lapar, M.L. & Teufel, N. 2018.** ***Assessing competitiveness of smallholder pig farming in the changing landscape of Northwest Vietnam.*** International Livestock Research Institute (ILRI) Nairobi, Kenya. (also available at https://cgspace.cgiar.org/bitstream/handle/10568/98904/RR52.pdf).

**Berthe, F.** 2020. The global economic impact of ASF. Bulletin de l'OIE 2020, 1–2.

**Cardona, C., Culhane, M., Goldsmith, T., Iglesias, I., Soininen, R., Patterson, G., & Sampedro, F.,** ***(et al).*** **2020.** ***An assessment of the risk associated with the movement of weaned pigs within, into, and outside of a control area during a foot-and-mouth disease outbreak in the United States.*** USDA:APHIS:VS and University of Minnesota Fort Collins. 179.

**Collineau, L. & Stärk, K.D.C.** 2019. How to motivate farmers to implement biosecurity measures. In: Dewulf, J., Van Immerseel, F. (Eds.), ***Biosecurity in animal production and veterinary medicine: from principles to practice.*** CABI, Wallingford, UK, pp. 66–72.

**Cowled, B., Cameron, A., Meyer, A., Dagg, P. & Howden, K. 2019.** ***Business Continuity in the Face of African Swine Fever:*** Compartmentalisation and Company Biosecurity.

**Dewulf, J., Postma, M., Vanbeselaere, B., Maes, D. & Filippitzi, M.E.** 2019. Transmission of pig diseases and biosecuirty in pig production. In: Dewulf, J., Van Immerseel, F. (Eds.), ***Biosecurity in animal production and veterinary medicine: from principles to practice.*** CABI, Wallingford, UK,pp. 153–170.

**Dixon, L.K., Stahl, K., Jori, F., Vial, L., Pfeiffer, D.U.** 2020. African Swine Fever Epidemiology and Control. ***Annual Review of Animal Bio sciences*** 8, pp. 221–246.

**European Food Safety Authority (EFSA).** 2005. Opinion of the Scientific Panel on Animal Health and Welfare (AHAW) on a request from the Commission related to "The Risk of a Rift Valley Fever Incursion and its Persistence within the Community". ***European Food Safety Authority Journal*** 3, p. 238.

**European Food Safety Authority (EFSA).** 2006. Opinion of the Scientific Panel Animal Health and Welfare (AHAW) related with the Migratory Birds and their Possible Role in the Spread of Highly Pathogenic Avian Influenza. ***European Food Safety Authority Journal*** 4, p. 357.

**FAO.** 2011. ***A value chain approach to animal diseases risk management – Technical foundations and practical framwork for field application.*** Food and Agriculture Organization of the United Nations Rome, Italy. 123 (also available at www.fao.org/3/i2198e/i2198e00.htm).

**Fournié, G., Jones, B.A., Beauvais, W., Lubroth, J., Njeumi, F., Cameron, A. & Pfeiffer, D.U.** 2014. The risk of rinderpest re-introduction in post-eradication era. ***Preventive Veterinary Medicine*** 113,pp. 175–184.

**Gale, P., Brouwer, A., Ramnial, V., Kelly, L., Kosmider, R., Fooks, A.R. & Snary, E.L.** 2010. Assessing the impact of climate change on vector -borne viruses in the EU through the elicitation of expert opinion. ***Epidemiology and Infection*** 138, pp. 214–225.

**Guinat, C., Gogin, A., Blome, S., Keil, G., Pollin, R., Pfeiffer, D.U., Dixon, L.,** 2016. Transmission routes of African swine fever virus to domestic pigs: current knowledge and future research directions. ***Vet Rec*** 178, 262–267.

**Guinat, C., Gubbins, S., Vergne, T., Gonzales, J.L., Dixon, L. & Pfeiffer, D.U** 2015. Experimental pig-to-pig transmission dynamics for African swine fever virus, Georgia 2007/1 strain.

***Epidemiology and Infection***, 1–10. **ILO.** 2019. Start-COOP. ***A step-by-step tool to start-up a cooperative.*** International Labour Office Geneva. (also available at www.ilo.org/wcmsp5/groups/public/---ed_emp/---emp_ent/---coop/documents/publication/wcms_644711.pdf).

**ILO.** 2020a. Start-COOP. ***Module 1 – Identifying Core Members and Business Ideas.*** International Labour Office Geneva. (also available at www.ilo.org/wcmsp5/groups/public/---ed_emp/--- emp_ent/---coop/documents/instructionalmaterial/wcms_644706.pdf).

**ILO.** 2020b. Start-COOP. ***Module 2 – Researching the Feasibility of the Business Ideas.*** International Labour Office Geneva. (also available at www.ilo.org/wcmsp5/groups/public/--- ed_emp/---emp_ent/---coop/documents/instructionalmaterial/wcms_644707.pdf).

**ILO.** 2020c. Start-COOP. ***Module 3 – Preparing the Business Plan.*** International Labour Office Geneva. (also available at www.ilo.org/wcmsp5/groups/public/---ed_emp/---emp_ent/---coop/documents/instructionalmaterial/wcms_644708.pdf).

**ILO.** 2020d. Start-COOP. ***Module 4 – Organizational Setup***. International Labour Office Geneva. (also available at www.ilo.org/wcmsp5/groups/public/---ed_emp/---emp_ent/---coop/documents/instructionalmaterial/wcms_644709.pdf).

**Patterson, G.R., Mohr, A.H., Snider, T.P., Lindsay, T.A., Davies, P.R., Goldsmith, T.J., & Sampedro,F.** 2016. Prioritization of Managed Pork Supply Movements during a FMD Outbreak in the US.***Frontiers in Veterinary Science*** 3, 97.

**Peeler, E.J., Reese, R.A., & Thrush, M.A.** 2015. Animal Disease Import Risk Analysis: a Review of Current Methods and Practice. ***Transboundary and Emerging Diseases*** 62, pp. 480–490.

**Pfeiffer, D.U., Ho, H.P.J., Bremang, A., Kim, Y. & Team,** O. 2021. ***Compartmentalization guidelines – African swine fever.*** World Organisation for Animal Health (OIE) Paris, France. P. 148.

**Pudenz, C.C., Schulz, L.L., & Tonsor, G.T.** 2019. Adoption of Secure Pork Supply Plan Biosecurity by U.S. Swine ***Producers. Frontiers in Veterinary Science*** 6, p. 146.

**Qiu, Y., Weber-Vintzel, L., Abila,** R. 2020. Pig value chain in South-East Asia and the challenges to disease management. ***Bulletin de l'OIE 2020,*** 1–2.

**Ramirez, A. & Zaabel, P.** 2012. Swine biological risk management. ***Veterinary Diagnostic and Production Animal Medicine Publications*** 3. Iowa State University, Iowa.

**Sanchez-Vizcaino, J.M., Laddomada, A.** & Arias, M. 2019. African swine fever virus. In: Zimmerman, J.L., Karriker, L.A., Ramirez, A., Schwartz, K.J., Stevenson, G.W., Zhang, J. (Eds.), ***Diseases of swine.*** John Wiley & Sons, pp.443–452.

**Scott, A., Zepeda, C., Garber, L., Smith, J., Swayne, D., Rhorer, A., Kellar, J., Shimshony, A., Batho, H., Caporale, V. & Giovannini, A.** 2006. The concept of compartmentalisation. ***Revue scientifique et technique*** 25, pp 873–879, pp 881–877, pp 889–895.

**Smith, D., Cooper, T., Pereira, A. & Jong, J.** 2019. Counting the cost: The potential impact of African Swine Fever on smallholders in Timor -Leste. ***One Health*** 8, 100109.

**Umber, J., Culhane, M., Cardona, C. & Goldsmith,** T. 2019. A Risk-Based Permitting Process for the Managed Movement of Animals and Products of Animal Origin as a Tool for Disease Management. ***Frontiers in Veterinary Science*** 6, p. 433.

**USDA.** 2016. ***FAD PReP/NAHEMS GUIDELINES:*** Continuity of business. USDA, Riverdale, Maryland.

**OIE.** 2010. ***Handbook on import risk analysis for animals and animal products: Introduction and qualitative risk analysis.*** OIE Publications Paris, France. 88.

**OIE.** 2015. ***Guide to Terrestrial Animal Health Surveillance.*** World Ogranisation for Animal Health Paris, France.

**OIE.** 2019a. Chapter 4.2 General principles on identification and traceability of live animals.

**OIE.** 2019b. ***Technical disease cards: African swine fever.*** World Organisation for Animal Health, Paris, France.

**Yoo, D.S., Kim, Y., Lee, E.S., Lim, J.S., Hong, S.K., Lee, I.S., Jung, C.S, Yoon, H.C., Pfeiffer, D.U., & Fournié,** G. 2021. Transmission dynamics of African swine fever virus, South Korea, 2019.

***Emerging Infectious Diseases*** 27, pp. 1909–1018.




ការិយាល័យប្រចាំតំបន់អាស៊ី និងប៉ាស៊ីភិច

FAO-RAP@fao.org
fao.org/asiapacific

**Food and Agriculture Organization of the United Nations**

ភ្នំពេញ កម្ពុជា

ISBN 978-92-5-137980-6

9 789251 379806

CB9114KM/1/07.23